# ការសិក្សាបែបសហការៈ ទ្រឹស្តី និងការអនុវត្ត

## ឯកសារណែនាំថ្មីសម្រាប់គ្រូបង្រៀន

### កម្មវិធីសាលារៀនដើម្បីជីវិត



USAID | CAMBODIA
FROM THE AMERICAN PEOPLE


ផលិតដោយ:

អង្គការអប់រំពិភពលោក(WEI), ផ្លូវ ៤៤ FARNSWORTH, រដ្ឋ BOSTON MA ០២២១០, សហរដ្ឋអាមេរិក,
ទូរស័ព្ទលេខ: (១) ៦១៧-៤៨២-៩៤៨៥, វេបសាយ: WWW.WORLDED.ORG

សហការជាមួយ:

អង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា (KAPE), ប្រអប់សំបុត្រលេខ: ១៦២១, ទីក្រុងភ្នំពេញ, ប្រទេសកម្ពុជា,
វេបសាយ: WWW.KAPEKH.ORG

# បញ្ជីមាតិកា

*អារម្ភកថា*

*សេចក្តីថ្លែងអំណរគុណ*

**<u>ផ្នែកទី១</u> - ឯកសារស្វ័យសិក្សា**

១. អ្វីទៅដែលហៅថាការសិក្សាបែបសហការ? ២

២. គោលបំណងការសិក្សាបែបសហការ ៤

*២.១ មូលហេតុចំនួនបួនដែលនាំឱ្យមានការសិក្សាអំពីការសិក្សាបែបសហការ*

*២.២ គំហើញពីការស្រាវជ្រាវអំពីការសិក្សាបែបសហការ*

៣. ធាតុសំខាន់៧នៃការសិក្សាបែបសហការ ៦

*៣.១ ការពឹងពាក់អាស្រ័យគ្នាទៅវិញទៅមកដោយភាពវិជ្ជមាន*

*៣.២ បំណិនសហការ (បំណិនសង្គម)*

*៣.៣ ដំណើរការអន្តរកម្មរវាងក្រុម*

*៣.៤ ការរៀបចំក្រុមចម្រុះ*

*៣.៥ ទំនួលខុសត្រូវបុគ្គល*

៤. របៀបនៃការប្រើប្រាស់ការសិក្សាបែបសហការនៅក្នុងថ្នាក់រៀន *១០*

*៤.១ ការរៀបចំចាត់ចែងក្រុម*

*៤.២ តួនាទីរបស់គ្រូក្នុងការសិក្សាបែបសហការ*

៥. ការរៀបចំថ្នាក់រៀនដើម្បីជួយដល់ការសិក្សាបែបសហការ *១៣*

៦. ការអនុវត្តការសិក្សាបែបសហការនៅក្នុងថ្នាក់រៀន *១៥*

*៦.១ ការអនុវត្តនៅក្នុងថ្នាក់ទី១*

*៦.២ ការអនុវត្តនៅក្នុងថ្នាក់ទី២*

*៦.៣ ការអនុវត្តនៅក្នុងថ្នាក់ទី៣*

*៦.៤ ការអនុវត្តនៅក្នុងថ្នាក់ទី៤*

*៦.៥ ការអនុវត្តនៅក្នុងថ្នាក់ទី៥*

៧. សេចក្តីសន្និដ្ឋាន *២២*

**<u>ផ្នែកទី២</u> - សកម្មភាពចំប៉ីន**

១. ការបង្ហាញបច្ចេកទេសការសិក្សាបែបសហការដោយការអនុវត្តផ្ទាល់
របៀបបង្កើតបទបញ្ហាផ្ទៃក្នុងសម្រាប់ថ្នាក់រៀន ២៥

*ឯកសារចែក ក*

២. ការកំណត់បញ្ហា ២៨

*ឯកសារចែក ខ*

៣. គោលការណ៍សំខាន់ៗនៃការសិក្សាបែបសហការ ៣២

*ឯកសារចែក គ*

៤. បច្ចេកទេសការសិក្សាបែបសហការនៅក្នុងការអនុវត្តជាក់ស្តែង ៣៧

*ឯកសារចែក ឃ*

៥. បច្ចេកទេសការសិក្សាបែបសហការនៅក្នុងការសរសេរកិច្ចតែងការបង្រៀន ៤៣

*ឯកសារចែក ង*

*ឯកសារចែក ច*

៦. បច្ចេកទេសការសិក្សាបែបសហការផ្សេងទៀត, យុទ្ធវិធីៈ គិត-ដៃគូ-ចែករំលែក ៥៤

*ឯកសារចែក ឆ*

៧. បញ្ហារួមទូទៅដែលកើតមានឡើងនៅពេលប្រើប្រាស់ការសិក្សាបែបសហការ ៥៨

*ឯកសារចែក ជ*

*ឯកសារយោង*

# អារម្ភកថា

នៅក្នុងសៀវភៅនេះបែងចែកជាពីរផ្នែក។ **ផ្នែកទី១** គឺផ្តល់ជាឯកសារស្វ័យសិក្សា ដែលបង្ហាញពីផ្ទៃរឿងទាំងមូលនៃវិធីសាស្ត្រ ទ្រឹស្តី និងការអនុវត្តនៃការសិក្សាបែបសហការ និងអាចយកមកប្រើប្រាស់នៅក្នុងពេលបំប៉ន និងទុកជាឯកសារយោងសម្រាប់ប្រើប្រាស់នាពេលអនាគតផងដែរ។ **ផ្នែកទី២** គឺផ្តល់នូវម៉ូឌុលសកម្មភាពបំប៉នជាច្រើន ដែលភាគច្រើនអាចយកមកប្រើប្រាស់ដោយឯករាជ្យរវាងសកម្មភាពនីមួយៗដោយពឹងផ្អែកទៅតាមតម្រូវការមូលដ្ឋាន។ នៅក្នុងសៀវភៅនេះមានបញ្ចូលនូវវីដេអូឌីវីឌី ដែលផ្តល់នូវឧទាហរណ៍ដែលមានប្រយោជន៍នៃការសិក្សាបែបសហការតាមកម្រិតថ្នាក់ផ្សេងៗគ្នា (ពោលគឺមានថ្នាក់ទី២ ទី៥ និង ទី៨)នៅក្នុងមុខវិជ្ជាខុសៗគ្នា។ អ្វីដែលគួរឱ្យចាប់អារម្មណ៍នោះគឺនៅក្នុងវីដេអូឌីវីឌីមានបង្ហាញពីឧទាហរណ៍នៃការអនុវត្តការសិក្សាបែបសហការ នៅក្នុងកម្រិតមធ្យមសិក្សាបឋមភូមិ ដើម្បីឆ្លើយតបទៅនឹងការយល់ខុសជាទូទៅដែលថាវិធីសាស្ត្រការសិក្សាបែបសហការអាចប្រើប្រាស់បានតែនៅកម្រិតបឋមសិក្សាប៉ុណ្ណោះ។ នៅក្នុងឯកសារនេះមានម៉ូឌុលមួយដែលផ្តល់នូវសកម្មភាពបំប៉នបែបរចនាសម្ព័ន្ធដើម្បីប្រើប្រាស់នៅពេលមើលវីដេអូឌីវីឌី ដើម្បីឱ្យវាមានការប្រើប្រាស់កាន់តែមានប្រសិទ្ធភាពបំផុត។ ទោះបីជាយ៉ាង.ណាក៏ដោយ គ្រូបង្រៀន និងគរុសិស្សនឹងនៅតែអាចទទួលបាននូវចំណេះដឹងជាច្រើនអំពីការសិក្សាបែបសហការដោយងាយបំផុតតាមរយៈការមើលវីដេអូឌីវីឌី បើទោះបីជាពេលវេលាសម្រាប់ការពិភាក្សា និងបំប៉នមានកំណត់ក៏ដោយ។

ជាធម្មតាក្នុងខណៈដែលគេយល់ថាការសិក្សាបែបសហការ ត្រូវបង្ហាញបច្ចេកទេសតាមលំដាប់លំដោយឱ្យបានទូលំទូលាយ ដែលសង្កត់ធ្ងន់លើការបង្កើនឱកាសការគិតដោយវិភាគ និងច្នៃប្រឌិត ឯកសារបំប៉ននេះបានផ្តោតជាបឋមតែទៅលើការរំពឹងទុកមួយចំនួនប៉ុណ្ណោះ ដល់គ្រូបង្រៀន និងគរុសិស្ស។ ដោយយោងទៅលើការលំបាកជាច្រើននៅក្នុងសាលារៀនតាមមូលដ្ឋាន (ឧទាហរណ៍ ថ្នាក់រៀនមានសិស្សច្រើន គ្រឿងបរិក្ខាមានកម្រិតអន់ គ្រូបង្រៀនពុំមានសមត្ថភាពគ្រប់គ្រាន់ ។ល។) អ្នកនិពន្ធបានផ្តោតទៅលើអន្តរាគមន៍បែបយុទ្ធសាស្ត្រនៅក្នុងថ្នាក់រៀនដែលមើលទៅមានលក្ខណៈបែបសហការ និង ដែលជម្រុញឱ្យសិស្សចំណាយពេលវេលាច្រើនលើកិច្ចការ ជាជាងការប្រើប្រាស់បច្ចេកទេសបង្រៀនបែបបុរាណ។ ដោយសារតែលទ្ធផលការសិក្សារបស់សិស្សជាធម្មតាមានទំនាក់ទំនងទៅវិញទៅមកជាមួយនឹងពេលវេលាសម្រាប់ធ្វើកិច្ចការ គេសង្ឃឹមថាលក្ខណៈអន្តរាគមន៍បែបនេះនឹងជួយកាត់បន្ថយអត្រាត្រួតថ្នាក់របស់សិស្ស ការសិក្សាមានភាពរីកចម្រើន បរិស្ថានសិក្សាកាន់តែមានភាពមេត្រី ព្រមទាំងបណ្តុះនូវតម្លៃការងារក្រុម និងជួយកែតម្រូវឥរិយាបថរបស់កុមារ។

# សេចក្តីថ្លែងអំណរគុណ

អង្គការអប់រំពិភពលោកសូមថ្លែងអំណរគុណដល់ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍអន្តរជាតិ USAID ដែលបានជួយឧបត្ថម្ភលើការកែសម្រួលឱ្យកាន់តែប្រសើរលើសៀវភៅការសិក្សាបែបសហការនេះ ដើម្បីធ្វើជាមធ្យោបាយសម្រាប់បង្កើនសមត្ថភាពបំណិនជីវិតបែបគិតដោយវិភាគ និងច្នៃប្រឌិតនៅក្នុងថ្នាក់រៀន។ អង្គការអប់រំពិភពលោកក៏សូមថ្លែងអំណរគុណផងដែរចំពោះអង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា ដែលបានអនុញ្ញាតឱ្យប្រើប្រាស់ឯកសារដែលមានស្រាប់សម្រាប់កែសម្រួលឡើងវិញធ្វើជាសៀវភៅការសិក្សាបែបសហការថ្មីនេះ។ ជាទីបញ្ចប់ អង្គការអប់រំពិភពលោកក៏សូមថ្លែងអំណរគុណផងដែរចំពោះលោកគ្រូ អ្នកគ្រូ និងអ្នកអប់រំមូលដ្ឋាននៅសាលាគរុកោសល្យ និងវិក្រឹតការ ការិយាល័យ និងមន្ទីរអប់រំយុវជននិងកីឡាខេត្តកំពង់ចាម និងជាពិសេសសាលារៀនទាំងឡាយក្នុងខេត្តកំពង់ចាមដែលបានផ្តល់ពេលវេលា និងគំនិតដោយភាពសប្បុរសក្នុងការរៀបចំសៀវភៅនេះឱ្យបានសម្រេចជាស្ថាពរ។

*គង់ សុនថារ៉ា*

*ប្រធានអង្គការអប់រំពិភពលោក ប្រទេសកម្ពុជា*

*ខែកក្កដា ឆ្នាំ២០០៩*

*សៅ វណ្ណា*

*ប្រធានអង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា*

*ខែកក្កដា ឆ្នាំ២០០៩*

# ផ្នែកទី១: ឯកសារស្វ័យសិក្សា

## សៀវភៅការសិក្សាបែបសហការ

កម្មវិធីសាលារៀនដើម្បីជីវិត

### ជំពូក


១. អ្វីទៅដែលហៅថាការសិក្សាបែបសហការ?

២. គោលបំណងនៃការសិក្សាបែបសហការ

៣. ធាតុសំខាន់ៗនៃការសិក្សាបែបសហការ

៤. របៀបនៃការប្រើប្រាស់ការសិក្សាបែបសហការនៅក្នុងថ្នាក់រៀន

៥. ការរៀបចំថ្នាក់រៀនដើម្បីជួយដល់ការសិក្សាបែបសហការ

៦. ការអនុវត្តការសិក្សាបែបសហការនៅក្នុងថ្នាក់រៀន

៧. សេចក្តីសន្និដ្ឋាន

# ជំពូក ១

## អ្វីទៅដែលហៅថាការសិក្សាបែបសហការ?

ការអនុវត្តការបង្រៀនដែលផ្តល់ឱកាសឱ្យសិស្សរៀនរួមគ្នាជាក្រុមតូច គេហៅថា "*ការសិក្សាបែបសហការ* "។ ការសិក្សាបែបសហការគឺកុមារកំពុងរៀនជាមួយគ្នាក្នុងក្រុម ដែលត្រូវបានគេរៀបចំជារចនាសម្ព័ន្ធដើម្បីឱ្យសមាជិកក្រុមសហការគ្នាធ្វើកិច្ចការឱ្យបានជោគជ័យ។ សិស្សធ្វើការរួមគ្នាដើម្បីរៀន និងទទួលខុសត្រូវចំពោះការសិក្សារបស់សមាជិកក្រុម ព្រមទាំងការសិក្សាផ្ទាល់ខ្លួនរបស់ពួកគេ។ នៅបច្ចុប្បន្ននេះគ្រូបង្រៀននៅក្នុងប្រទេសកម្ពុជាភាគច្រើនកំពុងពិចារណាឡើងវិញលើការអនុវត្តការបង្រៀនបែបបុរាណ ដែលសង្កត់ធ្ងន់ទៅលើការប្រកួតប្រជែងជាងការសហការនៅក្នុងថ្នាក់រៀន។ គ្រូបង្រៀនកំពុងគិតឡើងវិញ ថាតើវាសមហេតុផលឬទេក្នុងការលើកទឹកចិត្តសិស្សឱ្យធ្វើការដោយខ្លួនឯងដែលជារឿយៗ ពួកគេលាក់បាំងអ្វីដែលបានដឹងពីសិស្សផ្សេងៗទៀតដើម្បីការពារកុំឱ្យពួកនោះទាញយកប្រយោជន៍ពីខ្លួន។ ពួកគេរកឃើញថាការសិក្សាបែបសហការអនុញ្ញាតឱ្យមានសិស្សច្រើននាក់ចូលរួមការសិក្សាយ៉ាងសកម្ម។

ថ្នាក់រៀនត្រូវគេចាត់ទុកថាជាទីកន្លែងទំនាក់ទំនងបែបសង្គម ប៉ុន្តែជារឿយៗនៅពេលគ្រូបង្រៀនគិតអំពីការសិក្សា ពួកគេផ្តោតតែទៅលើការសិក្សាបែបបុគ្គលម្នាក់ៗ ហើយគេយល់ថាទិដ្ឋភាពទំនាក់ទំនងបែបសង្គមគឺជាការរំខាន ឬការងាកចេញពីការសិក្សាទៅវិញ។ ទោះបីជាយ៉ាងណាក៏ដោយប្រសិនបើគ្រូបង្រៀនចេះប្រើប្រាស់ទិដ្ឋភាពទំនាក់ទំនងបែបសង្គមប្រកបដោយភាពវិជ្ជមាននិងការចេះរៀបចំថ្នាក់បែបជម្រុញទំនាក់ទំនងសង្គម នោះនឹងកើតមានសកម្មភាពសិក្សាយ៉ាងច្រើន។ ការសិក្សាបែបសហការជួយអភិវឌ្ឍបំណិនប្រាស្រ័យទាក់ទង និងបង្កើនសមត្ថភាពរបស់ពួកគេឱ្យទទួលបានជោគជ័យនៅក្នុងពិភពការងារ និងការចេះរស់នៅក្នុងសង្គមមនុស្សទៀតផង។

*ការសិក្សាបែបសហការដែលមានប្រសិទ្ធភាព* គឺពឹងផ្អែកលើការពិភាក្សាដែលកើតនៅក្នុងក្រុមរវាងសិស្សនិងសិស្ស។ ការពិភាក្សាអំពីសំណួរជួយបង្កើតអត្ថន័យនិងការយល់ដឹង។ មនុស្សលោកបង្កើតឬកំណត់អត្ថន័យទៅលើវត្ថុអ្វីមួយតាមរយៈការពិភាក្សា។ ការសិក្សាស្រាវជ្រាវជាច្រើនបានបង្ហាញថា ការឱ្យសិស្សពន្យល់ចម្លើយនៃបញ្ហាទៅកាន់មិត្តភក្តិបែបឆ្លុះបង្ហាញ និងប្រាស្រ័យទាក់ទង ពិតជាជម្រុញឱ្យសិស្សមានការយល់ដឹងនៅក្នុងការសន្ទនាទាំងនេះ វាបង្ហាញនូវដំណើរការពិភាក្សាដ៏មានសារៈសំខាន់ បើទោះបីជាចម្លើយដែលផ្តល់ទាំងនោះខុសឬត្រូវក៏ដោយ។

*តាម លោកវីហ្គត់ស្គី "ចំណេះដឹង និងគំនិតថ្មីៗ កើតឡើងពីបរិបទនៃការពិភាក្សាគ្នា"។*

នៅក្នុងអំឡុងពេលធ្វើសកម្មភាពសិក្សាបែបសហការ សមាជិកនីមួយៗក្នុងក្រុមមិនមែនទទួលខុសត្រូវតែលើការសិក្សាដែលគ្រូបានបង្រៀនប៉ុណ្ណោះទេ ប៉ុន្តែត្រូវជួយមិត្តភក្តិក្នុងក្រុមឱ្យពួកគេរៀនផងដែរ ដូច្នោះវាបង្កើតបាននូវបរិយាកាសសម្រេចបាននូវសមិទ្ធិផលសិក្សា។ សិស្សធ្វើការលើកិច្ចការរហូតដល់សមាជិកក្រុមទាំងអស់បានយល់ដឹង និងបំពេញកិច្ចការដោយជោគជ័យ ។ នៅក្នុងការសិក្សាបែបសហការសិស្សនឹងៈ

- ទទួលបានចំណេះដឹងតាមរយៈការខិតខំប្រឹងប្រែងពីគ្នាទៅវិញទៅមក ។
- ភាពជោគជ័យរបស់អ្នកផ្តល់ផលប្រយោជន៍ដល់ខ្ញុំ ហើយភាពជោគជ័យរបស់ខ្ញុំផ្តល់ផលប្រយោជន៍ដល់អ្នក ។
- យល់ដឹងថាសមាជិកក្រុមទាំងអស់ត្រូវចេះចែករំលែកលទ្ធផលគ្នា ។
- យើងទាំងអស់គ្នាលិច ឬហែលលើទឹករួមគ្នា ។
- ដឹងថាលទ្ធផលល្អដែលទទួលបានគឺកើតពីសមាជិកម្នាក់ៗ និងក្រុម ។
- យើងមិនអាចធ្វើកិច្ចការនេះដោយគ្មានអ្នកបានឡើយ ។
- មានអារម្មណ៍មោទនភាព និងប្រារព្ធពិធីអបអររួមគ្នានៅពេលគេទទួលស្គាល់ថាសមាជិកក្រុមសម្រេចបាននូវសមិទ្ធិផល ។
- យើងទាំងអស់គ្នាសូមសម្តែងការអបអរដល់អ្នកចំពោះការសម្រេចបាននូវស្នាដៃនេះ ។



# ជំពូក ២

## គោលបំណងនៃការសិក្សាបែបសហការ

### ២.១ មូលហេតុចំនួនបួនដែលនាំឱ្យមានការសិក្សាអំពីវិធីសាស្ត្រការសិក្សាបែបសហការ

ចំណុចដ៏ល្អបំផុតដើម្បីចាប់ផ្តើមសាកល្បងប្រើប្រាស់ការសិក្សាបែបសហការឱ្យបានប្រសិទ្ធភាពនោះគឺជាបឋមត្រូវយល់ដឹងពីគោលបំណងនៃវិធីសាស្ត្រនេះ ។ ជាមូលដ្ឋានមានមូលហេតុចំនួនបួនដែលនាំឱ្យមានការសិក្សាបែបសហការៈ

#### ១. សិស្សភាគច្រើនសិក្សាយ៉ាងសកម្ម

ការសិក្សាបែបសហការជួយឱ្យសិស្សភាគច្រើនចូលរួមក្នុងការសិក្សាច្រើនជាងវិធីសាស្ត្រគ្រូមជ្ឈមណ្ឌល ឬ ការឧទ្ទេសបង្ហាញពីគ្រូ ។ ក្នុងការប្រើប្រាស់កន្លងមកថ្មីៗនេះ មានតែសិស្សដែលមានសមត្ថភាពម្នាក់ឬពីរនាក់ប៉ុណ្ណោះដែលមានភាពសកម្មលើការសិក្សាក្នុងពេលដំណាលគ្នា ។ តាមរយៈការប្រើប្រាស់វិធីសាស្ត្រសិក្សាបែបសហការឱ្យបានច្រើនដោយឱ្យសិស្សធ្វើការរួមគ្នាជាក្រុម សិស្សទាំងអស់ចូលរួមយ៉ាងសកម្មក្នុងកិច្ចការសិក្សា សិស្សនឹងក្លាយជាអ្នកចូលរួមយ៉ាងសកម្មច្រើនឡើងៗទៅក្នុងការសិក្សាផ្ទាល់ខ្លួន ដែលផ្ទុយនឹងការរៀនបែបអសកម្មដោយសិស្សចាំតែទទួលចំណេះដឹងពីគ្រូ ពោលគឺគេចាំតែស្តាប់ សង្កេត និងកត់ត្រាតែប៉ុណ្ណោះ ។

#### ២. សិស្សរៀនជួយគ្នាទៅវិញទៅមក

ការសិក្សាបែបសហការលើកទឹកចិត្តសិស្សឱ្យចេះគាំទ្រមិត្តរួមថ្នាក់នៅក្នុងក្រុម ជាជាងការប្រជែងគ្នាទៅវិញទៅមក ។ ការសិក្សាតាមរបៀបនេះ សិស្សអាចរួមផ្សំជំនាញ ឬ កោសល្យរបស់ពួកគេ និងជួយគ្នាទៅវិញទៅមក ។

#### ៣. ការគាំទ្របែបបណ្តាញកុមារជួយកុមារ

ការសិក្សាបែបសហការផ្តល់នូវឱកាសឱ្យសិស្សដែលមានសមត្ថភាពខ្ពស់ជួយសិស្សដែលជាអ្នករៀនយឺត ។ សិស្សដែលមានសមត្ថភាពខ្ពស់ទាំងនេះប្រហែលជាអាចប្រាស្រ័យទាក់ទងជាមួយមិត្តភក្តិរបស់ពួកគេបានយ៉ាងងាយស្រួលជាងគ្រូបង្រៀនរបស់ពួកគេ ។ ការជួយគាំទ្រពីសិស្សទាំងអស់នេះអាចបង្កើនបរិមាណនៃការពន្យល់នៅក្នុងថ្នាក់រៀនផងដែរ ។

#### ៤. កម្លាំងទឹកចិត្តកើនឡើងតាមរយៈភាពជោគជ័យ

ការសិក្សាបែបសហការជួយបង្កើនកម្លាំងទឹកចិត្តជាច្រើនតាមរយៈការផ្តល់ឱកាសឱ្យសិស្សភាគច្រើនទទួលបានភាពរីករាយពីជ័យជំនះ( ក្នុងករណីសកម្មភាពការសិក្សាបែបសហការដែលប្រើល្បែងសិក្សា) និងជោគជ័យពីការសិក្សា ។ នៅក្នុងថ្នាក់រៀនដែលអនុញ្ញាតឱ្យសិស្សបំពេញកិច្ចការជាបុគ្គល នោះមានសិស្សតែពីរបីនាក់ដែលមានសមត្ថភាពទើបអាចទទួលបានបទពិសោធន៍ពីការសិក្សាបែបនេះ ។ នៅក្នុងថ្នាក់រៀនដែលមានបែងចែកសិស្សជាក្រុមបែបសហការដែលមានទាំងសិស្សសមត្ថភាពខ្ពស់ និងទាបនៅជាមួយគ្នានោះឱកាសទទួលបានជោគជ័យនឹងអាចកើតមានសម្រាប់សិស្ស

គ្រប់គ្នា។

## ២.២ គំហើញពីការស្រាវជ្រាវអំពីការសិក្សាបែបសហការ

ការអនុវត្តការសិក្សាបែបសង្គមនៅក្នុងថ្នាក់រៀនបានចាប់ផ្តើមមុនគេនៅដើមទសវត្សឆ្នាំ១៩៧០។ ចាប់តាំងពីពេលនោះមកគេបានហៅថា "ការសិក្សាបែបសហការ" ដែលជាគំហើញពីការស្រាវជ្រាវមួយក្នុងចំណោមការស្រាវជ្រាវជាច្រើនអំពីវិធីសាស្ត្របង្រៀននៅក្នុងថ្នាក់រៀន។ លទ្ធផលស្រាវជ្រាវជាច្រើនបានសន្និដ្ឋានថា យុទ្ធសាស្ត្រការសិក្សាបែបសហការនៅក្នុងថ្នាក់រៀនផ្តល់នូវជោគជ័យយ៉ាងខ្លាំងទាំងផ្នែកសមិទ្ធិផលការសិក្សា ព្រមទាំងការអភិវឌ្ឍសីលធម៌ និងតម្លៃ។

ការស្រាវជ្រាវជាលក្ខណៈអន្តរជាតិ (Johnson & Johnson,date) បានរកឃើញថាការសិក្សាបែបសហការបានអភិវឌ្ឍ មិនត្រឹមតែការសិក្សារបស់សិស្សប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបណ្តុះបំណិនអភិវឌ្ឍន៍សង្គម និងការប្រាស្រ័យទាក់ទងគ្នាទៀតផង។

*សូមមើលអត្ថប្រយោជន៍មួយចំនួនដែលអ្នកស្រាវជ្រាវបានរកឃើញនៅពេលធ្វើការសិក្សាអំពីការសិក្សាបែបសហការ។*

**អត្ថប្រយោជន៍ដែលទទួលបានពីការប្រើប្រាស់ការសិក្សាបែបសហការ**

**ការសិក្សា**

- ការសិក្សាកើនឡើង
- សមត្ថភាពគិតដោយវិភាគកើនឡើង
- ពេលវេលាត្រូវបានគេចំណាយច្រើនទៅលើកិច្ចការសិក្សា (ការសុបិន្តពេលថ្ងៃរបស់សិស្សមានតិច)
- អត្រាគង់វង្សសិស្សកើនឡើង
- កម្លាំងទឹកចិត្តក្នុងការសិក្សារបស់សិស្សកើនឡើង
- បង្កើនភាពពេញចិត្តលើបទពិសោធន៍សិក្សារបស់ពួកគេ

**ការអភិវឌ្ឍបំណិនសង្គម**

- កាត់បន្ថយអាកប្បកិរិយា (ការប្រព្រឹត្ត) ឆាឆៅ ឬរំខាន
- អភិវឌ្ឍទំនាក់ទំនងភាពជាមិត្តភក្តិ
- អភិវឌ្ឍការចេះគោរពខ្លួនឯង
- សិស្សចេះប្រើប្រាស់បំណិនសង្គមបានសមស្រប
- អភិវឌ្ឍឥរិយាបទ (ការយល់ឃើញ) ចំពោះសាលារៀន

**ការប្រាស្រ័យទាក់ទងគ្នា**

- សិស្សចេះរៀនចែករំលែកព័ត៌មានគ្នា
- ជួយឱ្យសិស្សចេះពិចារណាពីមតិយោបល់អ្នកផ្សេងៗទៀត
- ជួយសិស្សអភិវឌ្ឍបំណិនប្រាស្រ័យទាក់ទងគ្នាខាងនិយាយស្តី

# ជំពូក ៣

## ធាតុសំខាន់ៗនៃការសិក្សាបែបសហការ

បើសិនជាធាតុសំខាន់ៗនៃការសិក្សាបែបសហការត្រូវបានគេប្រើប្រាស់នៅក្នុងមេរៀន នោះកិច្ចខំប្រឹងប្រែងលើលទ្ធផលរំពឹងទុកនឹងទទួលបាននូវផ្លែផ្កាច្រើនជាងការខិតខំបែបប្រកួតប្រជែង និងបែបបុគ្គល។ ធាតុសំខាន់ៗនៃការសិក្សាបែបសហការមានៈ

| |
|---|
| ១. ការពឹងពាក់អាស្រ័យគ្នាដោយភាពវិជ្ជមាន |
| ២. បំណិនសហការ (បំណិនសង្គម) |
| ៣. ដំណើរការអន្តរកម្មរវាងក្រុម |
| ៤. ការរៀបចំក្រុមចម្រុះ |
| ៥. ទំនួលខុសត្រូវបុគ្គល |

*"ការសិក្សាបែបសហការគឺជាការរៀបចំការសិក្សាក្រុមតូចបែបមានរចនាសម្ព័ន្ធ។ ការរៀបចំនេះធ្វើឡើងដោយផ្អែកលើការសន្និដ្ឋានសំខាន់ៗពីរគឺ ការពឹងពាក់អាស្រ័យគ្នាដោយភាពវិជ្ជមាន និងទំនួលខុសត្រូវបុគ្គល"*

*(Cottell & Millis, 1994)* ។

### ៣.១ ការពឹងពាក់អាស្រ័យគ្នាទៅវិញទៅមកដោយភាពវិជ្ជមាន

សិស្សដឹងថាពួកគេត្រូវការគ្នាទៅវិញទៅមកដើម្បីបំពេញកិច្ចការក្រុម។ ចំណុចសំខាន់ដើម្បីសម្រេចកិច្ចការនេះឱ្យបានជោគជ័យគឺត្រូវបង្កើតរចនាសម្ព័ន្ធក្រុមដើម្បីឱ្យសមាជិកក្រុមម្នាក់ៗដឹងថា "ខ្ញុំអាចទទួលជោគជ័យ និងធ្វើកិច្ចការឱ្យល្អបានដោយសារសមាជិកផ្សេងៗទៀតក្នុងក្រុមរបស់ខ្ញុំទទួលបានជោគជ័យ និងធ្វើកិច្ចការបានល្អផងដែរ"។

**៣.១.១ គ្រូបង្រៀនអាចអភិវឌ្ឍការពឹងពាក់អាស្រ័យគ្នាទៅវិញទៅមកដោយភាពវិជ្ជមានបានតាមរយៈ**

- បង្កើតគោលបំណងការសិក្សាសមស្រប (ការសិក្សាមួយដែលធានាថាសមាជិកក្រុមផ្សេងៗទៀតក៏ទទួលបានការសិក្សាផងដែរ)។
- ប្រើប្រាស់វិធីផ្តល់រង្វាន់រួមគ្នា(បើសមាជិកក្នុងក្រុមទាំងអស់ទទួលបានលទ្ធផលល្អលើសពីលក្ខណៈវិនិច្ឆ័យ សមាជិកម្នាក់ៗក៏ត្រូវទទួលបានពិន្ទុបន្ថែមស្មើៗគ្នាផងដែរ)។
- ផ្តល់នូវធនធានសម្ភារដែលសមាជិកម្នាក់ៗត្រូវធ្វើការរួមគ្នា
- បង្កើតតួនាទីសម្រាប់សមាជិកម្នាក់ៗ
- ពង្រឹងនូវចំណាប់អារម្មណ៍នៃ "ការដាក់ឈ្មោះក្រុមរួមគ្នា" (ដោយសុំឱ្យក្រុមនីមួយៗដាក់ឈ្មោះក្រុមដោយខ្លួនឯង)។
- ការខិតខំប្រឹងប្រែងពីសមាជិកក្រុមនីមួយៗគឺត្រូវតែមាន និងមិនអាចខ្វះបានទេសម្រាប់ភាពជោគជ័យរបស់ក្រុម។



- សមាជិកក្រុមនីមួយៗផ្តល់នូវការរួមចំណែកដើម្បីធ្វើការខិតខំរួមគ្នាដោយប្រើប្រាស់ធនធាន តួនាទី និងការទទួលខុសត្រូវលើកិច្ចការរៀងៗខ្លួន ។

### ៣.១.២ ការបង្កើតតួនាទីក្រុមៈ

តួនាទីរបស់ក្រុមនឹងមានលក្ខណៈផ្សេងៗគ្នាទៅតាមប្រភេទកិច្ចការ ។ ខាងក្រោមនេះបង្ហាញនូវតួនាទីមួយចំនួនដែលអាចកើតមានៈ

- អ្នកសម្របសម្រួលៈ ជាអ្នកដឹកនាំការពិភាក្សា និងលើកទឹកចិត្តសមាជិកគ្រប់គ្នាក្នុងក្រុមឱ្យចូលរួមធ្វើកិច្ចការ ។
- អ្នកសរសេរ/កត់ត្រាៈ កត់ត្រារាល់ការពិភាក្សារបស់ក្រុម ។
- អ្នកផ្ទៀងផ្ទាត់/រក្សាពេលវេលាៈ ត្រូវធានាថាក្រុមនឹងបញ្ចប់ការងារទាន់ពេលវេលាដែលកំណត់ដោយគ្រូ ។
- អ្នករាយការណ៍ៈ រាយការណ៍គំនិតរបស់ក្រុមទៅកាន់សិស្សផ្សេងៗទៀតនៅក្នុងថ្នាក់ដោយប្រើប្រាស់កំណត់ត្រារបស់អ្នកសរសេរ ។
- អ្នកបកស្រាយបង្ហាញៈ គូសរូបភាព ឬដ្យាក្រាមដែលចាំបាច់ ។
- អ្នកនាំសារ/អ្នកប្រមូលៈ ការបញ្ជូន ឬការរត់បណ្តាក់ព័ត៌មានជាមួយគ្រូទៅកាន់សិស្សក្រុមផ្សេងៗ និងទុកដាក់ ឬប្រគល់សម្ភារទាំងនោះទៅកាន់គ្រូវិញ ។

## *៣.២ បំណិនសហការ (បំណិនសង្គម)*

បំណិនសង្គមចាំបាច់ដើម្បីធ្វើឱ្យសកម្មភាពសិក្សាបែបសហការទទួលបានជោគជ័យគឺ មិនអាចកើតឡើងបែបលក្ខណៈធម្មជាតិបានឡើយ ។ គ្រូបង្រៀនត្រូវរៀបចំកិច្ចតែងការបង្រៀនដើម្បីផ្តល់ឱកាសឱ្យបំណិនខាងក្រោមមានការអភិវឌ្ឍឡើង ។

- ការលើកសរសើរគ្នា ការជម្រុញឱ្យអ្នកដទៃទទួលបានជោគជ័យ
- ការចេះស្តាប់គ្នា
- ការបង្ហាញភាពអត់ធ្មត់
- ការចេះរក្សាឱ្យអ្នកគ្រប់គ្នាផ្តោតលើកិច្ចការ
- ការពន្យល់ដោយផ្ទាល់មាត់អំពីរបៀបដោះស្រាយបញ្ហា
- ការបង្រៀនចំណេះដឹងរបស់ខ្លួនទៅឱ្យអ្នកដទៃ
- ចេះសាកសួរដើម្បីឱ្យដឹងថាខ្លួនបានយល់ដឹង ឬមិនទាន់យល់
- ការពិភាក្សាលើបញ្ញត្តិដែលបានរៀនរួចហើយ
- ចេះផ្សារភ្ជាប់ការសិក្សានាពេលបច្ចុប្បន្នជាមួយការសិក្សាពីអតីតកាល

*នៅពេលសិស្សធំមានការយល់ដឹងច្រើនអំពីសកម្មភាពការសិក្សាបែបសហការ គ្រូបង្រៀនអាចលើកទឹកចិត្តឱ្យគេមានបំណិនសង្គមបន្ថែមទៀតដូចជាៈ*

- *ភាពជាអ្នកដឹកនាំ*
- *ការសម្រេចចិត្ត*
- *ការសាងជំនឿចិត្ត*
- *ការប្រាស្រ័យទាក់ទងគ្នា*
- *បំណិនគ្រប់គ្រងជំលោះ*

### ៣.៣ ដំណើរការអន្តរកម្មរវាងក្រុម

ដើម្បីអភិវឌ្ឍសកម្មភាពការសិក្សាបែបសហការគ្រូបង្រៀនគួរលើកទឹកចិត្តសិស្សដោយៈ

- អនុញ្ញាតឱ្យកុមារឆ្លុះបញ្ចាំងលើដំណើរការរៀន (តើល្អកម្រិតណា? បញ្ហាអ្វី?...) ដែលពួកគេបានធ្វើការជាមួយគ្នា
- សមាជិកក្រុមពិភាក្សាលើរបៀបដែលពួកគេសម្រេចបាននូវគោលបំណង និងការរក្សាបាននូវទំនាក់ទំនងការងារប្រកបដោយប្រសិទ្ធភាព។
- សមាជិកក្រុមពិភាក្សាសកម្មភាពដែលធ្វើឱ្យមានប្រយោជន៍ និងគ្មានប្រយោជន៍។
- ឱ្យសិស្សធ្វើការសម្រេចចិត្តលើសកម្មភាពក្នុងក្រុម (អាកប្បកិរិយា) អ្វីខ្លះដែលត្រូវបន្តអនុវត្ត ឬ អ្វីខ្លះដែលត្រូវផ្លាស់ប្តូរចេញ។

### ៣.៤ ការរៀបចំក្រុមចម្រុះ (ការរៀបចំសិស្សចម្រុះ)

ការរៀបចំក្រុមមិនត្រូវរក្សាទុកសិស្សដដែលៗសម្រាប់គ្រប់សកម្មភាពសិក្សានោះទេ។ ការផ្លាស់ប្តូរក្រុមនឹងជួយបង្កើនបំណិនសង្គម ដោយការរៀបចំសិស្សទៅក្នុងបរិស្ថានមួយដែលពួកគេបានជួបនូវមិត្តភក្តិថ្មី និងស្ថានភាពថ្មី។ ការរៀបចំក្រុមអាចធ្វើឡើងតាមរបៀបរាប់លេខបែបចៃដន្យ ឬប្រើប្រាស់កត្តាខាងក្រោមក្នុងការរៀបចំក្រុមៈ



- ស្នាដៃដែលធ្លាប់មានពីមុន
- ភាពឧស្សាហ៍/ព្យាយាម
- ភេទ
- អាយុ
- សាសនា
- ជនជាតិ

### ៣.៥ ទំនួលខុសត្រូវបុគ្គល

បញ្ហាមួយដែលយើងបានឮជាទូទៅក្នុងចំណោមបញ្ហាផ្សេងៗទៀតនៃការរៀបចំក្រុមសិស្សនោះគឺសមាជិកមួយចំនួននឹងធ្វើកិច្ចការ ឬធ្វើសកម្មភាពសិក្សាតែឯង ក្នុងខណៈដែលសិស្សផ្សេងៗទៀតអង្គុយស្ងៀម ឬជាអ្នកឆាឆៅអ្នកដទៃ។ បញ្ហានេះអាចកើតឡើងដោយសារសិស្សមួយចំនួនជៀសវាងមិនព្រមធ្វើកិច្ចការ ឬ ដោយសារសិស្សផ្សេងទៀតចង់ធ្វើកិច្ចការអ្វីៗគ្រប់យ៉ាងតែម្នាក់ឯង។ សកម្មភាពមួយចំនួនដើម្បីបង្កើនទំនួលខុសត្រូវបុគ្គល និងរក្សាឱ្យសិស្សទាំងអស់ចូលរួមធ្វើសកម្មភាពមានៈ

- សិស្សម្នាក់ៗបង្កើតសំណួរ (ចេះសួរ) បំពេញកិច្ចការ ឬសរសេរបទនិពន្ធខ្លីៗនៅពេលសិក្សាលើអ្វីមួយ។

- សមាជិកក្រុមត្រូវបានគ្រូហៅឈ្មោះដោយចៃដន្យដើម្បីឆ្លើយសំណួរ។
- សមាជិកក្រុមនីមួយៗទទួលបាននូវតួនាទីជាក់លាក់ដើម្បីអនុវត្ត ហើយតួនាទីទាំងនេះអាចធ្វើការផ្លាស់ប្ដូរគ្នាបាន។
- សមាជិកនីមួយៗមានការទទួលខុសត្រូវខុសៗគ្នា ដើម្បីបំពេញចំណែកកិច្ចការផ្សេងៗគ្នាក្នុងគម្រោងផែនការរបស់ក្រុម។ ឧទាហរណ៍ បើសិនជាក្រុមមួយត្រូវធ្វើការបង្ហាញអំពីទីក្រុងភ្នំពេញ សមាជិកម្នាក់នឹងសរសេរអំពីប្រវត្តិសាស្ត្ររបស់ទីក្រុង សមាជិកម្នាក់ទៀតត្រូវសរសេរអំពីភូមិសាស្ត្រ សមាជិកម្នាក់ទៀតសរសេរអំពីសេដ្ឋកិច្ច និងសមាជិកម្នាក់ផ្សេងទៀតសរសេរអំពីសំណង់អាគារសំខាន់ៗព្រមទាំងផ្លាកសញ្ញាសំគាល់ទីកន្លែងទាំងនោះ។







*នៅក្នុងការសិក្សាបែបសហការ សិស្សនៅតែអាចមានឱកាសធ្វើកិច្ចការមួយចំនួនជាលក្ខណៈបុគ្គលបានផងដែរ។*

# ជំពូក ៤

## របៀបនៃការប្រើប្រាស់ការសិក្សាបែបសហការនៅក្នុងថ្នាក់រៀន

ការបង្ហាញចំណុចខាងក្រោមនឹងជួយឱ្យគ្រូបង្រៀនចេះរៀបចំសកម្មភាពការសិក្សាបែបសហការនៅក្នុងថ្នាក់រៀនតាមរបៀបមួយដែលនឹងជួយរួមចំណែកដល់បរិស្ថានសិក្សាក្នុងថ្នាក់ទាំងមូល ។

*ការសិក្សាបែបសហការគឺជាការងារក្រុម ប៉ុន្តែ ការងារក្រុម អាចមិនមែនជាការសិក្សាបែបសហការ ។*

### *៤.១ ការរៀបចំក្រុម*

- ត្រូវធានាថាវត្ថុបំណង និងវិធីសាស្ត្រធ្វើការរួមគ្នាក្នុងក្រុមមានភាពច្បាស់ លាស់ ។
- ការរៀបចំក្រុមបានល្អមិនមែនគ្រាន់តែឱ្យពួកគេអង្គុយជាមួយគ្នា ហើយប្រាប់ថា "សូមធ្វើការរួមគ្នា" ប៉ុណ្ណោះទេ ។
- សូមកំណត់ឱ្យច្បាស់នូវអ្វីដែលរំពឹងចង់បានពីសិស្ស និងរបៀបដែលពួកគេត្រូវរៀបចំចាត់ចែងដោយខ្លួនឯង ។
- ត្រូវធានាថាមានការបែងចែកតួនាទីច្បាស់លាស់ក្នុងក្រុមនីមួយៗ ។ សមាជិកម្នាក់ៗត្រូវដឹងច្បាស់ថាគេត្រូវធ្វើអ្វីខ្លះ ។
- ព្យាយាមរៀបចំសិស្សក្នុងក្រុមដោយមានចម្រុះសមត្ថភាព ។
- ព្យាយាមកំណត់ទំហំចំនួនសិស្សក្នុងក្រុមក្រោមប្រាំបីនាក់ ។ ចំនួនសមាជិកក្រុមដែលល្អបំផុតគឺមានពីប្រាំនាក់ទៅប្រាំមួយនាក់ (៥-៦នាក់) ។
- ធ្វើការផ្លាស់ប្តូរទៅផ្នែកខាងមុខ និងខាងក្រោយថ្នាក់រៀនពេលឱ្យសិស្សធ្វើការបង្ហាញជាក្រុមធំ និងក្រុមតូចឱ្យបានច្រើនដងក្នុងអំឡុងមេរៀន (ក្នុងជំហានទី៣ និង៤តាមប្លង់កិច្ចតែងការរបស់ក្រសួងអប់រំយុវជន និងកីឡា) ។ ការបង្រៀនតាមរបៀបនេះនឹងជួយបង្កើនកម្រិតអតិបរមានៃចំនួនសិស្សធ្វើកិច្ចការក្នុងពេលតែមួយ ។
- ព្យាយាមបង្កើតអារម្មណ៍បែបមោទនភាពចំពោះក្រុមដល់សិស្សម្នាក់ៗ ។ ការពង្រឹងអារម្មណ៍បែបនេះអាចជួយបង្កើនការសហការក្នុងក្រុម និងជួយឱ្យសិស្សធ្វើការរួមគ្នាកាន់តែប្រសើរឡើងអារម្មណ៍បែបមោទនភាពចំពោះក្រុមអាចសម្រេចបាន តាមរយៈការព្យាយាមថែរក្សាសមាជិកភាពក្រុមប្រកបដោយស្ថេរ-

*ការបែងចែកភារកិច្ចជាក់លាក់សម្រាប់ក្រុមនីមួយៗ គឺជាវិធានការសម្រាប់ធ្វើឱ្យសមាជិកម្នាក់ៗចូលរួមធ្វើសកម្មភាពទាំងអស់គ្នា ។*



ភាព និងអនុញ្ញាតឱ្យសិស្សដាក់ឈ្មោះក្រុមដោយខ្លួនឯងដូចជា "ក្រុមពណ៌ខៀវ" ឬ " ក្រុមតោ" ជាដើម ។

- ត្រូវធានាថាសិស្សមានការទទួលខុសត្រូវចំពោះការសិក្សារបស់ខ្លួន ។ *ការសិក្សាបែបសហការមិនមែនមានន័យថាមិត្តភក្តិរបស់អ្នកធ្វើការជំនួសអ្នកឡើយ ។* សិស្សត្រូវយល់ដឹងថាពួកគេនឹងត្រូវធ្វើតេស្ត និងកម្រិតឱ្យឡើងថ្នាក់ដោយផ្អែកលើសមត្ថភាពបុគ្គលម្នាក់ៗនៅចុងមេរៀន ខែ ឬឆ្នាំសិក្សា ។

## *៤.២ តួនាទីរបស់គ្រូបង្រៀននៅក្នុងការសិក្សាបែបសហការ*

គ្រូបង្រៀនដើរតួនាទីសំខាន់ណាស់ក្នុងការសម្របសម្រួល និងត្រួតពិនិត្យមើលសកម្មភាពក្រុមឱ្យកើតឡើងទៅតាមផែនការ ។ នៅក្នុងករណីជាច្រើន គ្រូបង្រៀនត្រូវធានាថាខ្លួនមានភាពមាំទាំ និងហ្មត់ចត់នៅក្នុងថ្នាក់រៀន ប៉ុន្តែមិនមែនជាភាពមាំទាំដែលមានឥទ្ធិពលគ្របសង្កត់ទៅលើសិស្សនោះទេ ។ នៅក្នុងការសិក្សាបែបសហការគ្រូបង្រៀនក៏មានភារកិច្ចទទួលខុសត្រូវផងដែរ ។ ចូរពិចារណាទៅលើការទទួលខុសត្រូវសំខាន់ៗដែលបង្ហាញខាងក្រោមៈ

| តួនាទីសំខាន់ៗរបស់គ្រូបង្រៀននៅក្នុងការសិក្សាបែបសហការ |
|---|
| • កំណត់ឱ្យច្បាស់នូវវត្ថុបំណងសិក្សា |
| • កំណត់ឱ្យច្បាស់នូវបំណិនសហការ |
| • សម្រេចចិត្តលើចំនួនសមាជិកក្រុម |
| • រៀបចំសិស្សឱ្យធ្វើការជាក្រុម |
| • រៀបចំចាត់ចែងថ្នាក់រៀន |
| • រៀបចំផែនការលើសម្ភារនានា |
| • រៀបចំបែងចែកតួនាទីដល់សិស្ស ( អ្នកអាន អ្នកកត់ត្រា អ្នកគិតលេខ អ្នកត្រួតពិនិត្យ អ្នករាយការណ៍ អ្នកផ្តល់សម្ភារ ។ល ។) |
| • ពន្យល់កិច្ចការដល់សិស្ស ( ពន្យល់ពីរបៀបដំណើរការ ផ្តល់ឧទាហរណ៍គំរូ សួរសំណួរត្រួតពិនិត្យការយល់ដឹងរបស់សិស្ស) |
| • ធ្វើតេស្ត និងសួរសំណួរសិស្សជាបុគ្គល ( ដើម្បីបង្កើនទំនួលខុសត្រូវបុគ្គល) |
| • ជម្រុញការសហការឆ្លងក្រុម ( អនុញ្ញាតឱ្យក្រុមត្រួតពិនិត្យកែកិច្ចការគ្នា និងជួយគ្នាទៅវិញទៅមក) ។ |
| • ត្រួតពិនិត្យអាកប្បកិរិយា ( ការប្រព្រឹត្ត) សិស្ស ( ក្នុងពេលសិស្សកំពុងធ្វើកិច្ចការ គ្រូត្រាច់ចរចុះឡើងដើម្បីពិនិត្យមើលថាតើសិស្សយល់កិច្ចការ និងសម្ភារឬទេ និងផ្តល់ព័ត៌មានត្រឡប់ឱ្យសិស្សភ្លាមៗ ។ល ។) |
| • លើកសរសើរក្រុមសិស្សដែលប្រើប្រាស់បំណិនក្រុមបានល្អ ។ |
| • ផ្តល់ជំនួយដល់សិស្សដើម្បីឱ្យគេយល់របៀបធ្វើកិច្ចការ ។ |

- ផ្តល់ជំនួយដល់សិស្សអំពីរបៀបដែលធ្វើឱ្យក្រុមចេះធ្វើការរួមគ្នាប្រកបដោយប្រសិទ្ធភាព។
- សួរសិស្សដើម្បីឱ្យពួកគេចេះឆ្លុះបញ្ចាំងពីដំណើរការល្អរបស់ក្រុម (មុខងារដំណើរការក្រុម) ដោយសួរឱ្យសិស្សនិយាយសង្ខេបឡើងវិញ។



# ជំពូក ៥

## ការរៀបចំថ្នាក់រៀនដើម្បីជួយដល់ការសិក្សាបែបសហការ

ជាការសំខាន់បំផុតសម្រាប់គ្រូដែលត្រូវយល់ឱ្យឃើញពីឥទ្ធិពលនៃការរៀបចំតុសិស្សផ្អែកលើវិធីដែលគេត្រូវបង្រៀន និងរៀន។ ជាការពិតទំនៀមទម្លាប់មួយចែងថា "ការរៀបចំតុសិស្សគឺដើម្បីជម្រុញដល់វិធីសាស្ត្របង្រៀន " នោះជាកត្តាមូលដ្ឋានគ្រឹះមួយនៃការយល់ដឹងរបស់យើងពីគរុកោសល្យនោះឯង។ ដូច្នេះបើគេរៀបចំតុសិស្សជាជួរៗបែរមុខទៅរកក្តារខៀនទាំងអស់គ្នាវិញនោះ មានន័យថាវាដឹកនាំវិធីរបស់យើងឆ្ពោះទៅរកការបង្រៀនមួយ ដែលគ្រូដើរតួតែឯងយ៉ាងផ្តាច់មុខ (Highly teacher-centered instructional approach)។ និយាយឱ្យចំទៅគឺថាគេដាក់ឱ្យសិស្សសម្លឹងមករកគ្រូរបស់ខ្លួនជាប់ជានិច្ច និងមិនឱ្យបែរមុខមករកគូកនសិស្សគ្នាឯងឡើយ។

ដូចនេះ ក្នុងការប្រតិបត្តិតាមវិធីសិក្សាបែបសហការនៅក្នុងការបង្រៀននេះ សំខាន់ស្ថិតនៅត្រង់គ្រូចេះណែនាំប្រាប់សិស្សអំពីរបៀប ហើយរៀបចំតុសិស្សទៅតាមរូបភាពខាងលើនេះ ជាកំហិត ដោយខានមិនបាន។ បើអាចលៃលកបាន តុសិស្សដែលតូចខ្លី គួរយកមកផ្គុំគ្នាជាក្រុមតូចៗ មានពាតុដែលអាច ឱ្យសិស្សទាំងអស់អង្គុយបែរមុខរកគ្នា ដោយសំឡឹងមកចំកណ្តាលក្រុមរបស់គេ។ បើពុំមានតុខ្លីទេ តុវែងក៏អាចប្រើបានដោយប្រសិទ្ធភាពដែរ។

> *គ្រូប្តូរពីអ្នកដឹកនាំនៅខាងមុខ មកជាទីប្រឹក្សានៅក្បែរ។*
>
> **(King Alison(1993)**




*គំនិតមួយចំនួននៃការរៀបចំតុនៅក្នុងថ្នាក់រៀន នៅប្រទេសកម្ពុជា*



ក្នុងការរៀបចំសិស្សជាក្រុមៗ ដូចមានបង្ហាញក្នុងរូបខាងលើនេះសិស្សអាចធ្វើសកម្មភាពរួមគ្នាបានយ៉ាងងាយស្រួលដោយរៀបចំឡើងដោយគ្រូបន្ទុក (ឬដោយសិស្សខ្លួនឯងក៏បាន)។ គ្រូគប្បីធ្វើការកត់សំគាល់ផងដែរថា ផ្ទៃកណ្តាលនៃថ្នាក់រៀនត្រូវរក្សាទុកឱ្យទំនេរ និងស្រឡះដើម្បីបង្កភាពងាយស្រួល ដល់ការត្រួតពិនិត្យ និងការស្រាយបំភ្លឺដល់ក្រុមទាំងឡាយ។ ជាការពិតណាស់ ការរៀបចំតុបែបនេះបានបម្រើឱ្យគោលបំណងល្អបំផុតសម្រាប់ត្រួតពិនិត្យសកម្មភាពសិស្ស ជាងការរៀបចំតុជាជួរៗ។ គួរកត់សំគាល់ថា ការរៀបចំតុត្រូវធ្វើយ៉ាងណាឱ្យសិស្សមានលទ្ធភាពសំឡឹងមើលមកក្តារខៀនបាន ដោយកុំឱ្យហួសកម្រិត៩០ដឺក្រេ។ ការរៀបចំតុបែបនេះមានប្រសិទ្ធភាពខ្ពស់បានលុះណាតែគ្រូយកពេលវេលាបង្រៀនតាមរបៀបរ៉ាយរ៉ាប់សុទ្ធសាធ កុំឱ្យហួសពី១០នាទី។ ការងារក្រុមតូចបែបនេះគប្បីប្រើពេលវេលាឱ្យច្រើនបំផុតនៅក្នុងការបង្រៀន និងរៀនតាមបែបសហការ។

# ជំពូក ៦

## ការអនុវត្តការសិក្សាបែបសហការនៅក្នុងថ្នាក់រៀន

នៅខាងក្រោមមានឧទាហរណ៍ខ្លះៗសម្រាប់គ្រប់កម្រិតថ្នាក់ ដែលបង្ហាញពីការបង្រៀនតាមវិធីបែបបុរាណ និងបែបសហការ ។

### *៦.១ ការអនុវត្តនៅក្នុងថ្នាក់ទី ១*

មួយផ្នែកធំនៃកម្មវិធីសិក្សាថ្នាក់ទី១ គឺរៀនឱ្យស្គាល់អក្សរនិងសម្លេងរបស់តួអក្សរនោះ។ តាមការបង្រៀនបែបបុរាណគ្រូពន្យល់សិស្សទាំងអស់គ្នានៅក្នុងថ្នាក់រៀនជាក្រុមធំអំពីរូបរាងនិងសូររបស់តួអក្សរ "ក" និង "ត"។ បន្ទាប់មកគ្រូហៅសិស្សខ្លះឱ្យឡើងមកកាន់ក្តារខៀនហើយឱ្យចង្អុលប្រាប់សិស្សដទៃនិងគ្រូ នូវពាក្យដែលផ្តើមដោយអក្សរ "ក" និង "ត" ដែលកំពុងបង្រៀននោះ។

សិស្សថ្នាក់ទី១គួរសង្កត់ធ្ងន់ទៅលើការចុះសម្រុងគ្នា (Socialization) ជាបទពិសោធន៍សំខាន់មួយក្នុងការសិក្សា ដូច្នោះជាធម្មតា គេត្រូវបញ្ចូលកុមារឱ្យទៅក្នុងក្រុមសហការនៅដើមវ័យសិក្សារបស់គេ។ មេរៀនអក្សរ "ក" និង "ត" ដែលបានពណ៌នាខាងលើអាចកែសម្រួលទៅជាការបង្រៀនតាមបែបសហការបានយ៉ាងងាយស្រួល។ ក្រោយពីបង្រៀនរូបរាងនិងសូររបស់តួអក្សររួច ជំនួសឱ្យការហៅសិស្សឱ្យឡើងមកកាន់ក្តារខៀន គ្រូអាចឱ្យសិស្សធ្វើការនៅលើតុជាក្រុមតូចៗដើម្បីពង្រឹងចំណេះដឹងដោយក្តីសប្បាយរីករាយ។ គ្រូអាចយកសម្ភារសំណង់អក្សរ (ខ្ទាច់លើ . . . ) មកចែកឱ្យសិស្សផ្គុំជាតួអក្សរ "ក" និង "ត"។ ក្រោយមកទៀតគ្រូប្រាប់សិស្សឱ្យយកប័ណ្ណជារូបសត្វ ឬរូបភាពផ្សេងៗមួយចំនួនទៀតដែលគ្រូបានផ្តល់ឱ្យមកបិទជុំវិញតួអក្សរទៅតាមសូរព្យញ្ជនៈ។ ក្នុងសកម្មភាពបែបនេះ គ្រូត្រូវបែងចែកភារកិច្ចសិស្សនីមួយៗឱ្យបានច្បាស់លាស់។ សិស្សខ្លះបង្កើតតួអក្សរ ហើយសិស្សខ្លះទៀតយកប័ណ្ណរូបភាពទៅតាមសូរ និងសិស្សម្នាក់ ឬច្រើននាក់ទៀតដាក់រូបភាពជុំវិញព្យញ្ជនៈនោះដែលមើលទៅដូចឧទាហរណ៍នៅខាងក្រោម ÷

*ឧទាហរណ៍* : វត្ថុដែលចាប់ផ្តើមដោយអក្សរ ក



### *៦.២ ការអនុវត្តនៅក្នុងថ្នាក់ទី ២*

នៅថ្នាក់ទី២សិស្សចាប់ផ្តើមរៀនពាក្យជ្រៅៗជាងមុន ។ សិស្សត្រូវចេះកំណត់ន័យរបស់ពាក្យដោយប្រើប្រាស់និយមន័យលើសពីពាក្យមួយ (ដូចថ្នាក់ទី១) សិស្សស្គាល់ថ្នាក់ពាក្យ ដូចជា នាម គុណនាម ឬកិរិយាស័ព្ទ និងអាចតែងល្បះដោយប្រើពាក្យនោះទៀតផង។ ការពន្យល់ពាក្យដែលបានបង្រៀនតាមរបៀបបុរាណគឺ សិស្សសូត្រពីនិយមន័យ ឬ អត្ថន័យរបស់ពាក្យហើយប្រាប់ពីថ្នាក់ពាក្យតែម្តង។

*ដោយសារតែការសិក្សានៅថ្នាក់បឋមសិក្សាកម្រិតទាប បញ្ជាក់លើការឱ្យកុមារចេះចុះសម្រុងគ្នា (បំណិនសង្គម) ធ្វើជាបទពិសោធន៍សំខាន់ក្នុងការសិក្សានោះ វាជាការធម្មតាទេដែលយើងត្រូវបញ្ចូលការសិក្សាបែបសហការដល់កុមារតាំងពីវ័យសិក្សាដំបូង។*

រីឯបច្ចេកទេសតាមការសិក្សាបែបសហការវិញ គេអាចណែនាំសកម្មភាពក្រុមសិស្សឱ្យកាន់តែចូលរួមយ៉ាងកុះករ និងជួយឱ្យគេបានយល់អត្ថន័យរបស់ពាក្យបានល្អប្រសើរច្រើនជាងមុន តាមរយៈការប្រើពាក្យ ឬ ភាសាដោយជាក់ស្តែង។ គេអាចប្រើក្រដាសរ៉ាមច្រើនសន្លឹកដោយកាត់ចេញជា ៤ចម្រៀកតូចៗ គ្រូអាចធ្វើប័ណ្ណអក្សរពី ១៥ ទៅ ២០ពាក្យបាន៥ឈុតឱ្យដូចគ្នានឹងពាក្យដែលសិស្សទើបបានរៀនរួច និងតាមរយៈមេរៀនជាច្រើនពីមុនៗមក។ ក្រោយពីបានធ្វើការត្រួតពិនិត្យមើលពាក្យនីមួយៗឡើងវិញជាមួយនឹងសិស្សរួចរាល់ហើយ គ្រូចែកឈុតប័ណ្ណអក្សរទាំងអស់ឱ្យដល់ក្រុមនីមួយៗហើយឱ្យគេរៀបចំប័ណ្ណពាក្យនោះជា៤ប្រភេទៈ

| ការរៀបចំថ្នាក់ពាក្យជាក្រុម |
|---|
| * ពាក្យទាំងឡាយណាជានាម |
| * ពាក្យទាំងឡាយណាជាកិរិយាស័ព្ទ |
| * ពាក្យទាំងឡាយណាជាគុណនាម |
| * ពាក្យទាំងឡាយណាដែលមិនស្ថិតក្នុងថ្នាក់ពាក្យទាំង៣ខាងលើ ។ |

នៅពេលដែល ក្រុមទាំងអស់បានបញ្ចប់ការកំណត់ថ្នាក់ពាក្យរួចហើយ ត្រូវមានសិស្សម្នាក់នៅក្នុងក្រុមសរសេរពាក្យទាំងនោះ នៅលើក្រដាសសម្រាប់ទុកជាឯកសារ។ ជាមួយគ្នានោះដែរ សិស្សដែលនៅសល់ក្នុងក្រុមនីមួយៗត្រូវនាំគ្នារៀបចំពាក្យឱ្យទៅជាល្បះ ដែលមានន័យគ្រប់គ្រាន់តាមគេអាចធ្វើទៅបាន។ នៅទន្ទឹមពេលសិស្សក្នុងក្រុមនីមួយៗធ្វើកិច្ចការនេះ គ្រូដើរតាមដានពិនិត្យដំណើរការរីកចំរើនរបស់សិស្ស។ ជាថ្មីម្តងទៀត យើងអាចមើលឃើញពីសារៈសំខាន់នៃការបែងចែកភារកិច្ច (Division of Labor) ច្បាស់លាស់នៅក្នុងក្រុមនីមួយៗ ថាជាវិធានការមួយធ្វើឱ្យសិស្សទាំងអស់សកម្មចូលរួមក្នុងការងារ។ សមាជិកម្នាក់ត្រូវចាត់ឱ្យរកពាក្យជាកិរិយាស័ព្ទ ម្នាក់ផ្សេងទៀតឱ្យរកពាក្យជានាម ជាដើម។ ដូចគ្នានេះដែរ សិស្សម្នាក់សរសេរថ្នាក់ពាក្យលើក្រដាស ឯសិស្សផ្សេងទៀតនាំគ្នារៀបពាក្យ



ជាល្បះ។

កាលណាគ្រូរៀបចំការប្រកួតក្រុមសិស្សបានត្រឹមត្រូវដែលផ្ទុយនឹងការប្រជែងគ្នារវាងបុគ្គល និងបុគ្គល សកម្មភាពបែបនេះអាចជួយពង្រឹងការចូលរួមរបស់សិស្សនៅក្នុងសកម្មភាពសិក្សា ព្រមទាំងបង្កើនស្មារតីសាមគ្គីភាព នៅក្នុងរង្វង់ក្រុមជាមួយគ្នាផងដែរ។ ឧទាហរណ៍នៃការសិក្សាពាក្យដែលបានពណ៌នាខាងលើនេះ គ្រូអាចប្រាប់សិស្សឱ្យ រៀបចំប័ណ្ណពាក្យឱ្យទៅជាល្បះមួយចំនួនដែលចាត់ទុកជាការប្រឡងប្រណាំងមួយដែរ ក្រុមណាមួយមានសមត្ថភាព បង្កើតល្បះបានច្រើនជាងគេបំផុតត្រូវចាត់ទុកជាក្រុមឈ្នះគេ។

## *៦.៣ ការអនុវត្តនៅក្នុងថ្នាក់ទី៣*

ពេលសិស្សរៀនដល់ថ្នាក់ទី៣ សិស្សកំពុងតែចាប់ផ្តើមអានយ៉ាងប៉ិនប្រសប់ខ្លាំងជាងមុន។ ដូចនេះការអាន លឿនព្រមទាំងយល់អត្ថន័យស្ទើរតែទាំងអស់ក្នុងល្បះ ឬអត្ថបទ សន្មតថាសិស្សអាចសម្រេចគោលបំណងសំខាន់មួយ នៅក្នុងកម្មវិធីសិក្សា។ ពេលគ្រូបង្រៀនអំណានដល់សិស្សទាំងអស់ក្នុងថ្នាក់ គ្រូមានបញ្ហាក្នុងការត្រួតពិនិត្យមើល អំណានរបស់សិស្សមួយចំនួនក្នុងពេលបង្រៀន។ ជាធម្មតាគ្រូឱ្យសិស្សម្នាក់អានអត្ថបទក្នុងរយៈពេលដ៏ខ្លីមួយ សិស្ស ឯទៀតត្រូវតែអានតាមដោយស្ងាត់ស្ងៀមជាមួយដែរ។ បន្ទាប់មកគ្រូហៅសិស្សម្នាក់ផ្សេងទៀតឱ្យអានបន្តពីសិស្ស មុន។ ភាគច្រើនគ្រូផ្តល់ការប្រតិបត្តិជាសកម្មភាពដល់សិស្សបានត្រឹមតែ១០ ទៅ១២នាក់យ៉ាងច្រើនក្នុង១ថ្នាក់ ក្នុងរយៈពេល៤០នាទី។ ឯសិស្ស២ភាគ៣ ផ្សេងទៀត អាច ឬ មិនអាចបានចូលរួមនៅក្នុងការរៀនមេរៀន អំណាននេះនឹងគេទេ។ ដូច្នេះគេមិនអាចស្តីបន្ទោសដល់សិស្សបានឡើយ កាលបើសិស្សនោះមិនបានចូលរួម ឬ អានតាមគេដោយស្ងាត់ៗ ពីព្រោះអំណានបែបនេះធ្វើឱ្យសិស្សមានការធុញទ្រាន់ខ្លាំងណាស់។ ការអានបែបនេះហាក់ ដូចជាគ្មានគោលបំណងអ្វីទាំងអស់ ក្រៅអំពីការដាក់ទណ្ឌកម្មដល់សិស្ស។

*ក្នុងការសិក្សាបែបសហការ បានផ្តល់ឱកាសច្រើនដល់ សិស្សឱ្យសិស្សចូលរួមយ៉ាងសកម្មក្នុងបទពិសោធន៍ ការអានប្រកបដោយគោលបំណងថែមទាំង បានបង្កើនទាំងល្បឿននៃការអាន និងការយល់ដឹងទៀតផង។*

វិធីផ្សេងក្នុងការអានដោយប្រើប្រាស់បច្ចេកទេសការសិក្សាបែបសហការអាចមានឧទាហរណ៍ដូចជា លំហាត់ អំណានជាក្រុមៗទាក់ទងនឹងអំណានសារព័ត៌មាន។ អំណានសារព័ត៌មានជាវិធីដ៏មានសារៈប្រយោជន៍យ៉ាងធំធេងដោយ សារធ្វើឱ្យសិស្សបានចូលរួមយ៉ាងសកម្មនៅក្នុងអំណាន។ ពេលនេះសិស្សជក់ភ្នែកនឹងសារព័ត៌មានដោយចេះតែបង្កើន ល្បឿនអានបន្តិចម្តងៗ និងហាក់ដូចជាមានការចាប់អារម្មណ៍ជាខ្លាំង ច្រើនជាងពួកគេអានអត្ថបទមួយក្នុងសៀវភៅ អំណានទៅទៀត។

នៅក្នុងលំហាត់អំណានតាមបែបសហការនេះ គ្រូម្នាក់ៗអាចចែកសារព័ត៌មានលេខដូចគ្នាឱ្យសិស្ស៥ឬ៦ក្រុម នៅក្នុងថ្នាក់។ ក្រុមនីមួយៗបានទទួលសារព័ត៌មាន១ច្បាប់ដែលអាចមានចំនួន៤ឬ៥សន្លឹក។ បន្ទាប់មកគ្រូឱ្យសេចក្តី

សង្ខេបអត្ថបទ១យ៉ាងខ្លី ឬ អត្ថបទផ្សាយដំណឹង ឬ រូបភាពថ្លុកកំប្លែងមួយណាក៏បានហើយឱ្យក្រុមសិស្សនីមួយៗរកអត្ថបទក្នុងសារព័ត៌មាននោះ។ ក្នុងការប្រតិបត្តិសកម្មភាពនេះសិស្សម្នាក់ៗអាចយកសារព័ត៌មានមួយសន្លឹក(មួយទំព័រ) ម្នាក់ និងអានចុះឡើង វិភាគអត្ថបទដែលគ្រូបានពណ៌នារួចហើយ។ បើជាក្រុមធំល្មមវិញសិស្ស២នាក់អាចមើលតែមួយទំព័ររួមគ្នា ដោយសារសារព័ត៌មានជាធម្មតាមានសន្លឹកទំព័រធំ។ ពេលក្រុមសិស្សណាមួយនាំគ្នារកឃើញអត្ថបទនោះរួចហើយ ពួកគេត្រូវលើកដៃទាំងអស់គ្នា។ បើគ្រូរៀបចំសកម្មភាពនេះជាការប្រឡងប្រណាំងដែរនោះគ្រូអាចឱ្យ១ពិន្ទុដល់ក្រុមណាដែលរកឃើញអត្ថបទនោះមុនគេ។ បន្ទាប់មកទៀត វិធីឬល្បិចបង្រៀននេះត្រូវធ្វើឡើងវិញសម្រាប់អត្ថបទផ្សេងៗក្នុងសារព័ត៌មាននោះបន្ថែមទៀត។



សកម្មភាពដូចមានរៀបរាប់ខាងលើនេះជួយបន្តឱ្យមានភាពងាយស្រួល នៅក្នុងទម្លាប់អានបានលឿន ព្រមទាំងយល់អត្ថន័យរបស់អត្ថបទទាំងមូលផង ដោយគ្រូបានផ្តល់គោលបំណង សម្រាប់ការអាន។ ព្រោះតែឯកសារអំណានសារព័ត៌មាន មានទំនាក់ទំនងគ្នា ជាមួយជីវភាពរស់នៅក្នុងសង្គម(មិនដូចអំណានក្នុងសៀវភៅសិក្សា) នាំឱ្យសិស្សទាំងអស់ បានចូលរួមយ៉ាងសកម្ម។ ម្យ៉ាងទៀត កិច្ចការដែលមានលក្ខណៈជាការប្រឡងប្រណាំងគ្នា បានផ្តល់ប្រយោជន៍លើល្បឿនអំណានព្រមទាំងការយល់បាននូវអត្ថន័យដែលគ្រូចង់បាន។ សមាជិកម្នាក់ៗនៅក្នុងក្រុមអានត្រួសៗនូវសារព័ត៌មាន ដើម្បីស្វែងរកអត្ថបទជួយឱ្យក្រុមទាំងមូលរបស់គេទទួលបានពិន្ទុ។ ដូចនេះជាថ្មីម្តងទៀត ស្មារតីនៃសកម្មភាពជាក្រុមមានសារៈសំខាន់នៅក្នុងការសម្រួលឱ្យមានការចូលរួមយ៉ាងកុះករពីសំណាក់សិស្សគ្នាឯង។ ជាការពិតណាស់ សិស្សទាំងអស់នៅក្នុងក្រុមនីមួយៗ (ដោយមិនគិតដល់កម្រិតសមត្ថភាព) នឹងទទួលបានបទពិសោធន៍ក្នុងការដណ្តើមជោគជ័យដ៏គួរឱ្យរំភើបចិត្ត នៅពេលដែលអត្ថបទក្នុងសារព័ត៌មានជាទីប្រាថ្នានោះត្រូវពួកគេបានរកឃើញ។

### *៦.៤ ការអនុវត្តនៅក្នុងថ្នាក់ទី៤*

ភូមិវិទ្យា និង ប្រវត្តិវិទ្យាជាមុខវិជ្ជា២ដែលគេមិនមានការយកចិត្តទុកដាក់ ហើយគ្រាន់តែបង្រៀនឱ្យសិស្សចេះត្រឹមតែទីកន្លែង កាលបរិច្ឆេទ និង ឈ្មោះប៉ុណ្ណោះ។ នៅប្រទេសកម្ពុជាការបង្រៀនមុខវិជ្ជាទាំង២នេះភាគច្រើន

សាលារៀនសង្កត់ធ្ងន់ ឬផ្អែកលើអំណានតាមសៀវភៅសិក្សាសុទ្ធសាធ (អានអត្ថបទសរសេរលើក្តារខៀន បើសិស្សគ្មានសៀវភៅសិក្សានឹងគេ) បន្ទាប់មកទៀតគឺការចោទជាសំណួរខ្លះៗដែលគ្រូដឹកនាំសិស្សទាំងមូលនៅក្នុងថ្នាក់រៀន។ ដូចថ្នាក់ដទៃទៀតដែរមានសិស្សតែ១នាក់ឬ២នាក់ប៉ុណ្ណោះ ដែលចូលរួមយ៉ាងសកម្មក្នុងមេរៀនទាំង២មុខវិជ្ជានេះក្នុងពេលរៀនម្តងៗ។ យើងគួរគិតមើល ថាតើការធុញទ្រាន់មានដល់កម្រិតណាទៅ បើយើងបង្រៀនរបៀបនេះ? នោះហើយជាមូលហេតុដែលសិស្សជាច្រើនចង់បោះបង់ចោលសាលានៅមុនពេលគេត្រូវចូលរៀនថ្នាក់ទី៥ទៅទៀត។

វិធីសិក្សាតាមបែបសហការជួយបង្កើនការចូលរួមរបស់សិស្ស និងមានការយកចិត្តទុកដាក់មកលើមេរៀនភូមិវិទ្យា និងប្រវត្តិវិទ្យា ព្រមទាំងនាំឱ្យការសិក្សានេះមានកម្រិតកាន់តែខ្ពស់ឡើងៗ។ ឧទាហរណ៍ៈ ការឱ្យសិស្សនាំគ្នាធ្វើតារាង និងដ្យាក្រាមជាសកម្មភាពសិក្សាយ៉ាងសកម្មនៅក្នុងមេរៀនស្តីពីរបៀបរស់នៅរបស់ប្រជារាស្ត្រទូទៅ នៅក្នុងមេរៀនបែបនេះ គ្រូអាចរៀបចំសិស្សប្រាំក្រុមនៅក្នុងថ្នាក់រៀន ហើយឱ្យក្រុមនីមួយៗបង្កើតតារាងដែលសង្ខេបពីរបៀបរស់នៅខុសៗគ្នារបស់ប្រជាជននៅតាមទីកន្លែងនីមួយៗដែលសិស្សធ្លាប់រៀន និងធ្លាប់ដឹងរួចមកហើយ ដូចជាៈ ភូមិ ឃុំ ស្រុក ខេត្ត និង ក្រុង . . . ជាដើម។ ប្រភេទ ឬព័ត៌មានទាំងឡាយនៅក្នុងតារាងគ្រូអាចធ្វើដោយខ្លួនឯង ឬមួយសិស្សធ្វើដោយខ្លួនឯងបើគេមានលទ្ធភាព។ ដើម្បីឱ្យក្រុមទាំងអស់ធ្វើតារាងព័ត៌មានដែលត្រូវស្រង់ពីមេរៀន គ្រូត្រូវចែកឱ្យក្រុមសិស្សនីមួយៗនូវខ្មៅដៃពណ៌២ឬ៣ដើម និងក្រដាសផ្ទាំងធំ១សន្លឹកដើម្បីឱ្យក្រុមទាំងអស់ធ្វើតារាងព័ត៌មានដែលត្រូវស្រង់ពីមេរៀន។ វិធីធ្វើឱ្យសិស្សចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពបែបនេះ គ្រូអាចផ្តល់យោបល់ណែនាំសិស្ស១នាក់ឬ២នាក់ទទួលខុសត្រូវរៀងៗខ្លួន ក្នុងការស្រាវជ្រាវព័ត៌មានសម្រាប់ឱ្យក្រុមរបស់គេយកមកបំពេញតារាងនីមួយៗ។ នៅពេលដែលព័ត៌មានសព្វបែបយ៉ាងបានប្រមូលរួចរាល់ហើយ សិស្សនឹងនាំគ្នាធ្វើការពិភាក្សាលំអិតលើព័ត៌មាននោះ ហើយស្រង់បានព័ត៌មានថ្មីសរសេរបំពេញនៅក្នុងតារាងទៅតាមប្រភេទព័ត៌មាននីមួយៗ (សូមមើលតារាងខាងក្រោម)។

***គម្រោងសិក្សាតាមវិធីសាស្ត្រសិក្សាបែបសហការមុខវិជ្ជាសិក្សាសង្គមនៅក្នុងថ្នាក់ទី៤***

| របៀបរស់នៅរបស់ប្រជាជននៅក្នុងតំបន់ផ្សេងៗ | | | |
|---|---|---|---|
| ក្រុម | ទីកន្លែងរស់នៅរបស់ប្រជាជន | សម្ភារពួកគេប្រើប្រាស់ | មុខរបរសំខាន់ៗ |
| អ្នកភូមិ | ជនបទ | ចាស់បុរាណ | កសិករ |
| អ្នកព្រៃភ្នំ | ភ្នំ | ចាស់បុរាណ | ចញ្ចឹមសត្វ អ្នកចំការ បរបាញ់សត្វ |
| អ្នកសមុទ្រ | ឆ្នេរសមុទ្រ | ចាស់បុរាណ | អ្នកនេសាទ |
| អ្នកទីក្រុង | ប្រជុំជន ក្រុងធំ-តូច | ទាន់សម័យ | កម្មកររោងចក្រ អ្នករាជការ |

ការគូសតារាង និងដ្យាក្រាមចាត់ទៅតាមប្រភេទព័តិមានដូចពណ៌នាខាងលើនេះ ជាកិច្ចការរៀនសូត្រមួយដែលទាមទារឱ្យមានការប្រៀបធៀបនឹងព័តិមាន ដែលបានរៀនក្នុងមេរៀន។ នៅពេលសិស្សនាំគ្នាធ្វើកិច្ចការប្រៀបធៀបរបៀបនេះ មានន័យថាសិស្សទាំងអស់នោះកំពុងតែនាំគ្នាចូលរួមមិនត្រឹមតែថាតាមគ្រូប៉ុណ្ណោះទេ ថែមទាំងចេះវិភាគព័តិមាន ដែលមានទំនាក់ទំនងគ្នារវាងសង្គមរស់នៅទីមួយៗទៀតផង។ ដូចនេះកិច្ចការរបៀបនេះ ក្រៅពីដឹកនាំឱ្យសិស្សទាំងអស់បានចូលរួមយ៉ាងសកម្មក្នុងការសិក្សាមេរៀននោះ វាថែមទាំងជួយនាំយកការយល់មេរៀនមួយដែលមានកម្រិតកាន់តែខ្ពស់ឡើងថែមទៀត។

*បច្ចេកទេសការសិក្សាបែបសហការជម្រុញដល់ការសិក្សាដែលពាក់ព័ន្ធនឹងបំណិនគិតកម្រិតខ្ពស់ ដូចជាបច្ចេកទេសរៀបចំចំណាត់ថ្នាក់ និងការរៀបចំលំដាប់លំដោយជាដើម។*

### *៦.៥ ការអនុវត្តនៅក្នុងថ្នាក់ទី៥*

សាលារៀនភាគច្រើននៅប្រទេសកម្ពុជាបច្ចុប្បន្ននេះ ការបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រអនុវត្តពឹងផ្អែកតែលើការអានសៀវភៅសិក្សា ការធ្វើសកម្មភាពចោទសួរ និងឆ្លើយខ្លះៗដែលគេបានផ្តោតត្រឹមតែការចងចាំ និងមានការការបង្ហាញពីគ្រូតែម្តងម្កាលប៉ុណ្ណោះ។ ប៉ុន្តែថ្មីៗនេះ កម្មវិធីសិក្សាវិទ្យាសាស្ត្រអនុវត្តកំពុងតែពិនិត្យមើលឡើងវិញដើម្បីឱ្យមានការចូលរួមសកម្មភាពរបស់សិស្សថែមទៀតនៅក្នុងការសិក្សាពីបញ្ញត្តិកម្មវិទ្យាសាស្ត្រ។ ជាការពិត ការសិក្សាបែបសហការនេះ ជាវិធីដ៏សមស្របទៅនឹងលទ្ធភាពនៃការចូលរួមរបស់សិស្សនៅក្នុងការសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រអនុវត្ត។

បច្ចេកទេសថ្មីនៃការបង្រៀនបានធ្វើឱ្យសិស្សមានការចូលរួមរៀនវិទ្យាសាស្ត្រអនុវត្តដោយសង្កត់ធ្ងន់លើបំណិនប្រសប់ជាច្រើនយ៉ាងដូចជាការសង្កេតពិនិត្យ ការកត់ត្រាទុកព័តិមាន ការធ្វើចំណាត់ថ្នាក់ ការវាស់វែង និងការធ្វើសម្មតិកម្មជាដើម។ បំណិនប្រសប់នីមួយៗនេះអាចឱ្យគេយកមកលៃលកប្រើប្រាស់បានយ៉ាងល្អដោយមានការបែងចែងការងារគ្នាធ្វើច្បាស់លាស់ដែលគេអាចបង្កើតបាននៅក្នុងក្រុមសិក្សាតាមថ្នាក់រៀននីមួយៗ។ ឧទាហរណ៍ក្នុងមេរៀនមួយស្តីពី "សិលា" គ្រូអាចសុំឱ្យសិស្សម្នាក់ៗយកដុំថ្ម២ឬ៣ដុំពីផ្ទះមកជាស្រេចដើម្បីបង្រៀន។ នៅក្នុងក្រុមនីមួយៗគ្រូអាចឱ្យសិស្សបង្កើតប្រព័ន្ធចំណាត់ថ្នាក់ដោយផ្អែកលើលក្ខណៈសំគាល់មួយចំនួនរបស់ថ្មដែលបានប្រមូលពីផ្ទះ។ សិស្ស១នាក់ឬ២នាក់នៅក្នុងក្រុមនីមួយៗអាចចាប់ផ្តើមធ្វើប្រព័ន្ធចំណាត់ថ្នាក់របស់ថ្មទាំងនោះ ដោយផ្អែកលើវាយនភាព (Texture) (គគ្រាត រលោង ស្អិត ពណ៌ និង កំហាប់ ( Hardhess ) ទន់ ជ្រាយ រឹង ស្រួយ ផុយ . . .)។ សិស្ស២នាក់ផ្សេងទៀតរៀបចំថ្មដែលមានតាមផ្អែកលើប្រព័ន្ធនេះ។ ឯសិស្សដែលនៅសល់ធ្វើការកត់ត្រាពីចំណាត់ថ្នាក់លើផ្ទាំងក្រដាសធំ១សន្លឹក (សូមមើលតារាងខាងក្រោម)។




*ការសិក្សាបែបសហការគឺជាវិធីសាស្ត្រមួយដែលមានលក្ខណៈសមស្របបំផុតសម្រាប់សម្របសម្រួលដល់ការចូលរួមរបស់សិស្សទៅក្នុងសកម្មភាពសិក្សានៅក្នុងមុខវិជ្ជាវិទ្យាសាស្ត្រអនុវត្ត ។*

មេរៀនវិទ្យាសាស្ត្រអនុវត្តដទៃទៀត គ្រូអាចធ្វើឱ្យដូចខាងលើដែរ ។ ឧទាហរណ៍ៈ សិស្សធ្វើសកម្មភាពជាក្រុមអំពីការធ្វើក្រាបតំណាងឱ្យអាយុសិស្សទាំងអស់ក្នុងថ្នាក់រៀន ឬអំពីជម្ងឺដែលគេធ្លាប់មាន នេះជាលំហាត់ចំណាត់ថ្នាក់ដែរ ។ ម៉្យាងទៀត សិស្សធ្វើការពិសោធ តាមរបៀបសង្កេតស្រាវជ្រាវធម្មតាមួយ រួមជាក្រុម១មានដូចជា ការដាក់វត្ថុទាំងឡាយចូលក្នុងកំប៉ុងទឹក ហើយនាំគ្នាសង្កេត ថាតើមានវត្ថុណាខ្លះលិចឬអណ្តែត ។ សិស្សទាំងអស់នៅក្នុងក្រុមនីមួយ១ត្រូវនាំគ្នាធ្វើកំណត់ត្រាពីអ្វី១ ដែលពួកគេសង្កេតឃើញ និងនាំគ្នាពិភាក្សារកសេចក្តីសន្និដ្ឋានអ្វីខ្លះដែលគេអាចធ្វើបានក្នុងការរកដង់ស៊ីតេស្រាល ឬ ធ្ងន់របស់វត្ថុនីមួយ១។ សិស្សគប្បីធ្វើការសន្និដ្ឋានវត្ថុទាំងឡាយណាដែលអណ្តែតលើទឹក (ស្លឹកឈើ គម្របប៊ិច . . .)មានដង់ស៊ីតេស្រាល មានវត្ថុខ្លះលិចក្នុងទឹក (ដុំថ្មដែក . . . ) មានដង់ស៊ីតេធ្ងន់។ ការបែងចែកការងារគ្នាយ៉ាងច្បាស់លាស់មួយត្រូវតែប្រព្រឹត្តឡើងនៅក្នុងក្រុមនីមួយ១។ សិស្សម្នាក់ទទួលខុសត្រូវប្រមូលវត្ថុពិសោធន៍ សិស្សម្នាក់ទៀតត្រូវដាក់វត្ថុទាំងនោះនៅក្នុងទឹក ហើយសិស្សដែលនៅសល់ទាំងប៉ុន្មានធ្វើការកត់ត្រាលទ្ធផលជាក់ស្តែង ។

# ជំពូក ៧

## សេចក្តីសន្និដ្ឋាន

នៅក្នុងអំឡុងពេល១០ឆ្នាំនេះ មានការស្រាវជ្រាវជាច្រើនបានធ្វើការសិក្សាទៅលើប្រសិទ្ធភាពនៃវិធីសាស្រ្តការសិក្សាបែបសហការ។ លទ្ធផលនៃការស្រាវជ្រាវស្ទើរតែទាំងអស់បានបង្ហាញថាវិធីសាស្រ្តនេះមានប្រសិទ្ធភាពយ៉ាងច្រើនក្នុងការឱ្យសិស្សទទួលបានសមិទ្ធិផលសិក្សាកម្រិតខ្ពស់ ជាងវិធីសាស្រ្តប្រកួតប្រជែងបែបបុរាណ។ ជាពិសេសទៅទៀតនោះ ការសិក្សាទាំងនេះបានបង្ហាញថាវិធីសាស្រ្តសិក្សាបែបសហការបានជួយជម្រុញលើកទឹកចិត្តយ៉ាងខ្លាំងដល់សិស្សដែលមានសមត្ថភាពកម្រិតទាប និងមធ្យម។ ជាទូទៅគេយល់ថា វិធីសាស្រ្តសិក្សាបែបសហការមិនត្រឹមតែអភិវឌ្ឍលទ្ធផលសិក្សាសិស្សប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់នូវប្រសិទ្ធខ្ពស់ក្នុងការជម្រុញការអភិវឌ្ឍសង្គម និងផ្សាំបណ្តុះតម្លៃនៃការសហការគ្នា និងអាកប្បកិរិយាចេះជួយគ្នា។ ដូច្នោះ វិធីសាស្រ្តនេះមិនត្រឹមតែជាឧបករណ៍មានប្រយោជន៍សម្រាប់**ការអភិវឌ្ឍពុទ្ធិ** (Cognitive development) ប៉ុន្តែថែមទាំងជួយ**អភិវឌ្ឍផ្នែកឥរិយាបថ** (Affective Competencies) ទៀតផង។

គ្រូជាច្រើននៅក្នុងប្រទេសកម្ពុជា មានទំនោរទៅរកការប្រើប្រាស់សកម្មភាពក្នុងថ្នាក់រៀនដែលសង្កត់ធ្ងន់ទៅលើការប្រកួតប្រជែងក្នុងចំណោមសិស្ស ដែលពួកគេយល់ថាជាមធ្យោបាយចម្បងមួយសម្រាប់លើកទឹកចិត្តសិស្ស។ ក្នុងខណៈដែលវិធីសាស្រ្តទាំងនេះមានប្រសិទ្ធភាពតែលើក្រុមសិស្សឆ្លាតៗមួយចំនួនតូច ពួកគេបានផ្តល់ឥទ្ធិពលអាក្រក់ (បង្ខិនបង្ខោច)ដល់សមត្ថភាពសិស្សរៀនយឺតជាច្រើន។ លក្ខណៈនៃកាផ្តល់រង្វាន់ និងគ្រឿងលើកទឹកចិត្ត បែបប្រកួតប្រជែងជាសាធារណៈ នឹងនាំទៅដល់ភាពខ្មាសអៀន និងក្តីកង្វល់សម្រាប់សិស្សដែលទទួលបានបរាជ័យ។នៅពេលក្តីកង្វល់ និងភាពខ្មាសអៀនកើនកម្រិតខ្ពស់ពេក ជាទីបញ្ចប់កុមារ នឹងបោះបង់សកម្មភាពរៀនបែបសកម្ម ពីព្រោះពួកគេដឹងថាខ្លួនគេនឹងមិនអាចទទួលបានជ័យជំនះឡើយ ទោះបីជាពួកគេព្យាយាមយ៉ាងណាក៏ដោយ។

*វិធីសាស្រ្តការសិក្សាបែបសហការជួយបង្កើនកម្លាំងទឹកចិត្តយ៉ាងខ្លាំងដល់កុមារដែលមានសមត្ថភាពសិក្សាកម្រិតទាប និងមធ្យម។*



តាមរយៈការសង្កេតឃើញ បើសិនជាគ្រូព្យាយាមបង្រៀនសិស្សក្នុងថ្នាក់រៀនតែអំពីបំណិនលេខ និងអក្សរ នោះក៏នឹងនាំឱ្យសិស្សមានការបារម្ភយ៉ាងខ្លាំងផងដែរ។ ការប្រកួតប្រជែងរវាងក្រុមសិស្ស តាមរយៈការប្រើប្រាស់វិធីសិក្សាបែបសហការនេះបានផ្តល់អត្ថប្រយោជន៍យ៉ាងច្រើន ក្នុងការជម្រុញទឹកចិត្តសិស្សដែលមានសមត្ថភាពកម្រិតទាប និងមធ្យម ដែលផ្ទុយនឹងការប្រកួតប្រជែងបែបបុគ្គល ដែលសិស្សប្រភេទនេះពុំទទួលបានភាពរីកចម្រើនអ្វីឡើយ។ តាមរយៈការរៀបចំសិស្សជាក្រុមចម្រុះសមត្ថភាព ដែលបានលើកឡើងនៅក្នុងវិធីសាស្ត្រសិក្សាបែបសហការបានផ្តល់នូវភាពរីករាយ និងជោគជ័យដល់សិស្សភាគច្រើននៅក្នុងថ្នាក់រៀន។

# ផ្នែកទី២ៈ សកម្មភាពបំប៉ន

## ការសិក្សាបែបសហការៈ ទ្រឹស្តី និងការអនុវត្ត

កម្មវិធីសាលារៀនដើម្បីជីវិត

## សកម្មភាព និងឯកសារចែក

១. ការណែនាំបង្ហាញបច្ចេកទេសមួយក្នុងការសិក្សាបែបសហការ

២. ការកំណត់បញ្ហា

៣. គោលការណ៍សំខាន់ៗនៃការសិក្សាបែបសហការ

៤. បច្ចេកទេសការសិក្សាបែបសហការក្នុងការអនុវត្តជាក់ស្តែង

៥. ការសិក្សាបែបសហការនៅក្នុងការសរសេរកិច្ចតែងការបង្រៀន

៦. បច្ចេកទេសការសិក្សាបែបសហការផ្សេងៗទៀត យុទ្ធវិធីៈ គិត-ដៃគូ-ចែករំលែក

៧. បញ្ហាទូទៅដែលកើតមានឡើងនៅពេលប្រើប្រាស់ការសិក្សាបែបសហការ

# សកម្មភាពបំប៉នទី១

## ការបង្ហាញវិធីសាស្ត្រការសិក្សាបែបសហការតាមរយៈការអនុវត្តបង្កើតបទបញ្ជាសម្រាប់ថ្នាក់រៀន ( ៣០នាទី)

សកម្មភាពនេះគួរប្រើជាមួយនឹងសិក្ខាកាមដើម្បីចាប់ផ្តើមសិក្ខាសាលាអំពីការសិក្សាបែបសហការ ដែលជាការចាប់ផ្តើមបង្ហាញវិធីសាស្ត្រខ្លះៗ។ អ្នកសម្របសម្រួលគួរពន្យល់ថា គាត់នឹងធ្វើការបង្ហាញអំពីវិធីសាស្ត្រការសិក្សាបែបសហការទៅតាមបែបបទនៃការបង្កើតបទបញ្ជាផ្ទៃក្នុង។ យើងត្រូវការបទបញ្ជាផ្ទៃក្នុងសម្រាប់សិក្ខាសាលា និងថ្នាក់រៀន ហើយវាជាបទបញ្ជាដែលសមាជិកគ្រប់គ្នាឯកភាពថាមានសារប្រយោជន៍។ ខាងក្រោមនេះគឺជាវិធីសាស្ត្រមួយក្នុងការសម្រេចចិត្តបង្កើតបទបញ្ជាផ្ទៃក្នុងៈ

### របៀបក្នុងការបង្កើតបទបញ្ជាផ្ទៃក្នុងសម្រាប់សិក្ខាសាលា

**១. ពិភាក្សាអំពីតម្រូវការសម្រាប់បទបញ្ជាផ្ទៃក្នុង**

ឱ្យសិក្ខាកាមធ្វើការជាគូ ពិភាក្សាសំណួរៈ "ហេតុអ្វីបានជាយើងត្រូវការបទបញ្ជាផ្ទៃក្នុងនៅក្នុងថ្នាក់រៀន?" បន្ទាប់មកផ្តល់ព័ត៌មានត្រឡប់ទៅកាន់ក្រុមធំ។

**២. បង្កើតបញ្ជីបទបញ្ជាផ្ទៃក្នុង**

ឱ្យសិក្ខាកាមធ្វើការជាក្រុម។ ក្រុមនីមួយៗអាចបែងចែកអាស្រ័យទៅលើសាលារៀន ស្រុក តួនាទី។ល។ ទៅតាមទីកន្លែងដែលសិក្ខាកាមមក ឬអាចឱ្យសិក្ខាកាមអង្គុយចម្រុះគ្នាក្នុងក្រុមតែមួយក៏បាន។ អ្នកសម្របសម្រួលគួរតែធ្វើការសម្រេចចិត្តទុកជាមុនក្នុងការបែងចែកសមាសភាពក្នុងក្រុមនេះ។ ចែកក្រដាសផ្ទាំងធំឱ្យក្រុមនីមួយៗដើម្បីឱ្យពួកគេសរសេរបទបញ្ជាផ្ទៃក្នុងណាដែលពួកគេគិតថាសំខាន់។ (អ្នកសម្របសម្រួលលើកទឹកចិត្តសិក្ខាកាមឱ្យសរសេរផ្តើមនូវអ្វីដែលវិជ្ជមាន ចៀសវាងឱ្យពួកគេផ្តើមដោយពាក្យ "កុំ")។

**៣. ជ្រើសរើសបទបញ្ជាណាដែលល្អជាងគេ**

អ្នកអាននៅក្នុងក្រុមនីមួយៗអាននូវបទបញ្ជាទៅកាន់ក្រុម។ នៅក្នុងការពិភាក្សាក្រុម សិក្ខាកាមជ្រើសរើសយកបទបញ្ជាជាអាទិភាពចំនួន៣ ហើយពន្យល់អំពីអត្ថន័យនៃបទបញ្ជាទាំងនោះ។

**៤. ប្រមូលផ្តុំបទបញ្ជាផ្ទៃក្នុង**

ក្នុងក្រុមនីមួយៗជ្រើសរើសអ្នកឡើងរាយការណ៍ទុកជាមុន។ ឱ្យសិក្ខាកាមធ្វើការចែករំលែកនូវបទបញ្ជាជាអាទិភាពរបស់ពួកគេទៅកាន់ក្រុមធំ។ សរសេររាល់បទបញ្ជាដែលបានលើកឡើងដោយអ្នករាយការណ៍នៅតាមក្រុមនីមួយៗនៅលើក្តារខៀន។

**៥. បោះឆ្នោតជ្រើសរើសយកបទបញ្ហាចំនួន ៦**

ឱ្យសិក្ខាកាមធ្វើការបោះឆ្នោតដើម្បីជ្រើសរើសយកបទបញ្ហាចំនួន៦ដែលសំខាន់ជាងគេ។

**៦. បិទបទបញ្ហាផ្ទៃក្នុង**

សរសេរនូវបទបញ្ហាចុងក្រោយ នៅលើប៉ូស្ទ័រហើយដាក់តាំងនៅកន្លែងណាដែលសមរម្យសម្រាប់វគ្គសិក្ខាសាលា។

*អ្នកសម្របសម្រួលគួរតែបញ្ចប់ផ្នែកនេះដោយពន្យល់សិក្ខាកាមថាៈ យើងអនុវត្តទៅតាមវិធីសាស្ត្រដូចគ្នា នៅពេលដែលយើងបង្កើតបទបញ្ហាផ្ទៃក្នុងសម្រាប់ថ្នាក់រៀន ហើយសិស្សអាចប្រើប៊ិចពណ៌សរសេរលើប៉ូស្ទ័រផងដែរ។ អ្នកសម្របសម្រួលផ្តល់**ឯកសារចែក ក** ។*

# ឯកសារចែក ក

## របៀបក្នុងការបង្កើតបទបញ្ជាផ្ទៃក្នុងសម្រាប់ថ្នាក់រៀន

**1. ពិភាក្សាអំពីតម្រូវការសម្រាប់បទបញ្ជាផ្ទៃក្នុង**

ឱ្យសិស្សធ្វើការជាគូដើម្បីពិភាក្សាសំណួរៈ "ហេតុអ្វីបានជាយើងត្រូវការបទបញ្ជាផ្ទៃក្នុងនៅក្នុងថ្នាក់រៀន?" បន្ទាប់មកផ្តល់ព័ត៌មានត្រឡប់ទៅកាន់ក្រុមធំ ។

**2. បង្កើតបញ្ជីបទបញ្ជាផ្ទៃក្នុង**

ឱ្យសិស្សធ្វើការជាក្រុម ។

ផ្តល់ឱ្យក្រុមនីមួយៗនូវក្រដាសរ៉ាមធំ ហើយផ្តល់ឱ្យសិស្សម្នាក់ៗបានសរសេរគ្រប់គ្នាអំពីបទបញ្ជាក្នុងថ្នាក់រៀនដែលគេគិតថាសំខាន់ ។ (លើកទឹកចិត្តសិស្សឱ្យសរសេរផ្តើមនូវអ្វីដែលវិជ្ជមាន ចៀសវាងឱ្យពួកគេចាប់ផ្តើមដោយប្រើពាក្យ "កុំ") ។

**3. ជ្រើសរើសបទបញ្ជាណាដែលល្អជាងគេ**

អ្នកអាននៅក្នុងក្រុមនីមួយៗអាននូវបទបញ្ជាទៅកាន់ក្រុម ។ នៅក្នុងការពិភាក្សាក្រុម សិស្សជ្រើសរើសយកបទបញ្ជាជាអាទិភាពចំនួន៣ ហើយពន្យល់អំពីអត្ថន័យនៃបទបញ្ជាទាំងនោះ ។

**4. ប្រមូលផ្តុំបទបញ្ជាផ្ទៃក្នុង**

ក្នុងក្រុមនីមួយៗជ្រើសរើសអ្នកឡើងរាយការណ៍ទុកជាមុន ។ ឱ្យក្រុមសិស្សនីមួយៗផ្តល់នូវបទបញ្ជាជាអាទិភាពរបស់ពួកគេទៅកាន់ក្រុមធំ ។ សរសេររាល់បទបញ្ជាថ្មីដែលបានលើកឡើងនៅលើក្តារខៀន ខណៈពេលដែលអ្នករាយការណ៍តាមក្រុមនីមួយៗផ្តល់ចម្លើយ ។

**5. បោះឆ្នោតជ្រើសរើសយកបទបញ្ជាចំនួន ៦**

ឱ្យសិស្សធ្វើការបោះឆ្នោតដើម្បីជ្រើសរើសយកបទបញ្ជាចំនួន ៦ ដែលសំខាន់ជាងគេ ។

**6. បិទបទបញ្ជាផ្ទៃក្នុង**

ដាក់តាំងបទបញ្ជានៅកន្លែងណាដែលសមរម្យ ។

*កម្មវិធីសាលារៀនដើម្បីជីវិត*

# សកម្មភាពបំប៉នទី២

**ការកំណត់បញ្ហានៅក្នុងថ្នាក់រៀន ( ១ម៉ោង)**

## ***១. វត្ថុបំណង***

- សិក្ខាកាមផ្តោះបញ្ចាំងលើការអនុវត្តទូទៅនៅក្នុងថ្នាក់រៀន និង ឪណាមិចខាងចិត្តវិទ្យាដែលមានភាពអវិជ្ជមានដែលតែងតែកើតមាននៅក្នុងវិធីបង្រៀនបែបបុរាណភាគច្រើន។
- សិក្ខាកាមចាប់ផ្តើមយល់ដឹងពីតម្រូវការដែលត្រូវប្រើប្រាស់បច្ចេកទេសបង្រៀនផ្សេងៗទៀត។

## ***២. លំនាំបង្រៀន***

- អ្នកសម្របសម្រួលគួរចាប់ផ្តើមបង្រៀន ដោយព្យាយាមវាយតម្លៃលើប្រសិទ្ធភាពវិធីសាស្ត្របង្រៀនទាពេលបច្ចុប្បន្នដែលផ្តោតជាពិសេសទៅលើបុគ្គលភាពទិដ្ឋភាពរៀនបែបប្រកួតប្រជែង។ ទិដ្ឋភាពទាំងនេះនឹងបង្ហាញឡើងតាមរយៈការអានករណីសិក្សា។
- អ្នកសម្របសម្រួលផ្តល់ឯកសារដែលមានចំណងជើងថា *"ករណីសិក្សា និងសំណួរពិភាក្សា"* ទៅឱ្យសិក្ខាកាមម្នាក់ៗ (**មើលឯកសារចែក ខ**)។
- បន្ទាប់ពីការអានឯកសារករណីសិក្សា អ្នកសម្របសម្រួលឱ្យពួកគេឆ្លើយសំណួរនៅខាងក្រោមឯកសារជាក្រុមតូច។ អ្នកសម្របសម្រួលត្រូវផ្តល់ផ្ទាំងក្រដាសធំ និងហ្វឺតដើម្បីឱ្យសិក្ខាកាមកត់ត្រាចម្លើយពិភាក្សាសម្រាប់ធ្វើការរាយការណ៍។
- អ្នកសម្របសម្រួលសួរដកស្រង់ចម្លើយក្រុម។ សកម្មភាពនេះអាចធ្វើតាមរយៈឱ្យក្រុមនីមួយៗឡើងរាយការណ៍ (៥នាទីសម្រាប់ក្រុមនីមួយៗ) ឬអាចបើកជាវេទិកាពិភាក្សាជាក្រុមធំក៏បាន។ បើសិនជាចំណុចខាងក្រោមមិនត្រូវបានលើកឡើងពីការពិភាក្សាទេ អ្នកសម្របសម្រួលត្រូវសួរយ៉ាងណាឱ្យពួកគេលើកឡើង។

**ចំណុចសំខាន់ៗសម្រាប់ដឹកនាំការពិភាក្សា ( ក្រុមធំ)**

**ស្ថានភាពពិពណ៌នាដែលធ្វើឱ្យមានការពេញចិត្តៈ**

ស្ថានភាពប្រឡងប្រណាំងបានកើតឡើងនៅក្នុងថ្នាក់រៀន។ មតិមួយចំនួនអះអាងថា ស្ថានភាពបែបនេះជារង្វាន់សម្រាប់សិស្សពូកែ ហើយអាចជំរុញឱ្យសិស្សខ្សោយកាន់តែខិតខំប្រឹងរៀនខ្លាំងឡើង។ ឯមតិមួយចំនួនទៀតគិតថាសិស្សខ្សោយលែងមានការជិតស្និទ្ធដោយសារបទពិសោធន៍នេះ ហើយវាអាចនាំឱ្យមានអវត្តមានច្រើន ឬរហូតដល់បោះបង់ចោលសាលារៀនតែម្តង។ ការបោះបង់ការសិក្សាដោយសារមូលហេតុខាងលើនេះជាអំពើមួយដែលគ្រូបង្រៀនចង់ការពារមិនឱ្យមានបញ្ហានោះកើតឡើងទៀត។

**ឥទ្ធិពលនៃវិធីសាស្ត្របង្រៀនពិពណ៌នាអំពីការអភិវឌ្ឍទឹកចិត្តរបស់សិស្សផ្នែកសីលធម៌:**

ដូចបានកត់សំគាល់ខាងលើរួចមកហើយថា បរិយាកាសសិក្សាដែលកើតមាននៅក្នុងថ្នាក់រៀនគឺការប្រឡងប្រណាំង ។ប៉ុន្តែយើងគួរពិចារណា ថាតើយើងគួរតែមានការពង្រឹងអាកប្បកិរិយា "សហការ" "ការជួយគ្នា" នៅក្នុងថ្នាក់រៀនដែរឬទេ? តើយើងចង់បានអាកប្បកិរិយាជួយគ្នាទៅវិញទៅមកក្នុងសង្គមរបស់យើងដែរឬទេ? វាជាការពិតណាស់ អាកប្បកិរិយាបែបនេះដែលយើងចង់បាន។ ប៉ុន្តែសិស្សមិនអាចចេះជួយគ្នាទៅវិញទៅមកទេ ប្រសិនបើគេចេះតែជួបប្រទះនូវស្ថានភាពប្រកួតប្រជែងគ្នាដូចមានរៀបរាប់នៅក្នុងករណីសិក្សាដែលបានអានរួចមកនោះ។ ជាការពិត ស្ថានភាពបែបនេះវានឹងជំរុញឱ្យមានអាកប្បកិរិយាយកខ្លួនឯងជាមូលដ្ឋាន ភាពឃោរឃៅគ្មានមេត្តាហើយនឹងគ្មានខ្វល់ដល់អ្នកដទៃ។

**សំណួរ:**

តើសុភាពពិតជាមានចិត្តចង់ជួយសុខាឬទេ?: ប្រាកដណាស់ សុភាពគ្មានចិត្តចង់ជួយសុខាទេ។ គ្រូមានវិធីជាច្រើនដែលអាចដោះស្រាយស្ថានភាពដែលបានកើតឡើងក្នុងករណីសិក្សានេះ ដោយមិនបានធ្វើទណ្ឌកម្មដល់សុខា។ សុភាពគឺគ្រាន់តែឆ្លើយនឹងសំណួរ មិនបានជួយសុខាទេ ប៉ុន្តែគេចង់បានការសរសើរពីគ្រូតែប៉ុណ្ណោះ។ ដូចនេះការលើកទឹកចិត្តដែលនាំឱ្យសុខភាពឆ្លើយសំណួរនោះគឺដើម្បីខ្លួនឯង ហើយជាការសំខាន់ជាងនេះទៀតនោះគឺអ្នកគ្រូបានជំរុញឱ្យសុភាពមានគំនិតបែបនេះ។

**ជម្រើសក្នុងការឆ្លើយតប:**

តាមយោបល់អ្នក តើអ្នកគួរប្រែប្រួលរបៀបបង្រៀនក្នុងករណីសិក្សានេះយ៉ាងណា? មានវិធីផ្សេងៗជាច្រើនដែលគ្រូអាចជួយដោះស្រាយស្ថានភាពនេះឱ្យកាន់តែមានភាពមេត្រី និងសណ្តោសប្រណីច្រើនឡើង។ អ្នកគ្រូឱ្យសិស្សដទៃទៀតដាក់ដៃចុះ ហើយព្យាយាមសួរសំណួរបំផុសដល់សុខាថែមទៀតដើម្បីរកចម្លើយមួយត្រឹមត្រូវឬក៏ប្រហែលជាគ្រូរៀបចំសិស្សជាក្រុម ហើយសិស្សផ្តល់ចម្លើយជាក្រុម។ នៅក្នុងវិធីរៀបជាក្រុមសុខាទទួលបានចម្លើយត្រឹមត្រូវពីមិត្តភក្តិ។ ប្រសិនបើសុខានៅតែឆ្លើយខុសទៀត ពេលនោះក្រុមទាំងមូលជាអ្នករួមចំណែកជាមួយសុខាក្នុងការទទួលខុសត្រូវ។ កុមារក៏ដូចជាមនុស្សចាស់ដែរគេមានអារម្មណ៍ថាមានសុវត្ថិភាព ប្រសិនបើគេទទួលខុសត្រូវជាក្រុម។ វិធីចុងក្រោយដើម្បីដោះស្រាយស្ថានភាពនេះគឺត្រូវបានគេហៅថា "ការសិក្សាបែបសហការ"។

# ឯកសារចែក ២

### ***ការកំណត់បញ្ហា***

***សេចក្តីណែនាំ:*** *ចូរអានករណីសិក្សា និងពិចារណាលើសំណួរខាងក្រោមតាមក្រុម ។ ចូរកត់ត្រាចម្លើយរបស់អ្នកនៅក្នុងក្រដាសផ្ទាំងធំសម្រាប់រាយការណ៍ទៅកាន់ក្រុមផ្សេងៗ ។*

| **ករណីសិក្សា និងសំណួរពិភាក្សា** | |
|---|---|
| អ្នកគ្រូថ្នាក់ទីពាម្នាក់បានចាប់ផ្តើមមេរៀនរបស់គាត់ដោយត្រួតពិនិត្យចំណុចមួយចំនួនអំពីវេយ្យាករណ៍ដែលជាមេរៀនចាស់ពីថ្ងៃមុនដូចខាងក្រោមនេះ: | |
| <u>អ្នកគ្រូ</u>: | តើកូនៗមានអ្នកណាចាំបានទេថា ពាក្យថា ផ្លែ ឆ្មា និង ភូមិ មាននៅក្នុងថ្នាក់ពាក្យអ្វី ? |
| *( មានសិស្ស២០នាក់បានលើកដៃយ៉ាងរហ័ស និងមានសិស្ស១០នាក់ទៀតមិនបានលើកដៃហើយព្យាយាមលាក់ខ្លួន ក្នុងចំណោមមិត្តភក្តិរបស់គេ ហើយសង្ឃឹមថាប្រហែលជាគ្រូមិនហៅចំពួកគេទេមើលទៅ! ពេលនោះអ្នកគ្រូហៅសុខា) ។* | |
| <u>សុខា</u>: | ជាសុភាសិត ។ |
| *(សិស្សទាំងអស់ក្នុងថ្នាក់សើចគិល )* | |
| <u>អ្នកគ្រូ</u>: | ទេ ! ដូចជាមិនទាន់ត្រឹមត្រូវទេ ។ |
| *( មុខសុខាឡើងក្រហម ហើយសិស្សដទៃទៀតបានលើកដៃម្តងទៀត ។ សិស្សខ្លះកំពុងតែក្រោកឈរចេញពីតុរបស់ខ្លួនហើយស្រែកថា...) ។* | |
| <u>អ្នកគ្រូ</u>: | តើមានអ្នកណាផ្សេងដឹងឬទេ? |
| *(សិស្សជាច្រើនបានស្រែក)* | |
| <u>សិស្ស</u> : | ខ្ញុំ ខ្ញុំ ខ្ញុំ ខ្ញុំ |
| *( អ្នកគ្រូបានងាកទៅរកសិស្សម្នាក់ទៀតដែលមានឈ្មោះថា សុភាព)* | |
| <u>អ្នកគ្រូ</u>: | មើលសុភាព កូនអាចជួយសុខាឆ្លើយសំណួរនេះបានទេ ? |

*<u>ប្រភពមកពី</u> :* Slavin. R.E. (1993 ) *ការសិក្សាបែបសហការៈ ទ្រឹស្តីស្រាវជ្រាវ និង អនុវត្តន៍ ។*

## <u>សំណួរពិភាក្សា</u>

1. តាមយោបល់របស់អ្នក តើស្ថានភាពថ្នាក់រៀនបានបង្ហាញខាងលើក្នុងការបង្រៀនបានល្អឬទេ? ពីព្រោះអ្វី ?

2. តើអ្នកគិតថាមានការប៉ះពាល់អ្វីទេ ចំពោះការប្រឡងប្រជែងសំណួរបែបនេះ ចំពោះការអភិវឌ្ឍផ្នែកសីលធម៌របស់កុមារ? ( តើវាធ្វើឱ្យកុមារគិតជួយគ្នាដែរឬទេ ? តើវាធ្វើឱ្យកុមារចូលចិត្តរៀនដែរឬទេ ? )

3. សូមពិចារណាសំណួរដែលអ្នកគ្រូសួរផ្ទាល់ទៅសុភាព ( ឧ.មើលសុភាព កូនអាចជួយសុខាក្នុងការឆ្លើយសំណួរនេះបានទេ ? ) តាមស្ថានភាពដែលបានកើតឡើង តើអ្នកគិតថា សុភាពពិតជាមានចិត្តចង់ជួយសុខាឬទេ ? ហេតុអ្វី?

4. ប្រសិនបើអ្នកជាអ្នកគ្រូខាងលើនេះវិញ តើអ្នកគួរតែផ្លាស់ប្តូរវិធីបង្រៀនបែបណា?

# សកម្មភាពបំប៉នទី៣

**គោលការណ៍សំខាន់ៗនៃការសិក្សាបែបសហការ ( ១ម៉ោង១៥នាទី)**

## ១. *វត្ថុបំណង*

- សិក្ខាកាមនឹងអាចពិពណ៌នានូវគោលការណ៍មូលដ្ឋាន និងលក្ខណៈមួយចំនួននៃការសិក្សាបែបសហការ។ ការពិពណ៌នាគួរតែបញ្ចូលនូវគោលបំណង អត្ថប្រយោជន៍ និងវិធីសាស្ត្រមូលដ្ឋានមួយចំនួនក្នុងការអនុវត្តជាក់ស្ដែង ។

## ២. *លំនាំបង្រៀន*

- អ្នកសម្របសម្រួលចែកជូននូវ *ឯកសារណែនាំអំពីការសិក្សាបែបសហការ* និងឱ្យសិក្ខាកាមអានខ្លឹមសារនៅទំព័រទី២ដល់ទី១៤ ដោយភាពស្ងៀមស្ងាត់។
- បន្ទាប់ពីសិក្ខាកាមបានអាន ឯកសារណែនាំរួចហើយចែកសិក្ខាកាមជាក្រុមតូចៗចំនួន៤ក្រុម ហើយចែកជូននូវសំណួរខាងក្រោមដើម្បីពិភាក្សា និងរាយការណ៍ត្រឡប់វិញ។

| **សំណួរពិភាក្សា** |
|---|
| **១.** តើការសិក្សាបែបសហការលើកកម្ពស់អាកប្បកិរិយាជួយគ្នាយ៉ាងដូចម្ដេច? |
| *( ចម្លើយៈ តាមរយៈការបង្កើតស្ថានភាពមួយដែលកុមារត្រូវតែធ្វើការរួមគ្នាដើម្បីសម្រេចកិច្ចការ។ ការសហការបានមកជំនួស ការប្រកួតប្រជែង)* |
| **២.** តើការសិក្សាបែបសហការជម្រុញលើកទឹកចិត្តដល់សិស្សដែលរៀនយឺតយ៉ាងដូចម្ដេច? |
| *(ចម្លើយៈ តាមរយៈការបង្អាក់ស្ថានភាពប្រកួតប្រជែង ដូចនោះសិស្សដែលរៀនយឺតត្រូវបានទុកឱ្យមានឱកាសក្នុងការបន្ថយនូវបរិយាកាសអវិជ្ជមាន នៅពេលដែលពួកគេឆ្លើយចម្លើយខុស។ សិស្សដែលរៀនយឺតមានបទពិសោធន៍នឹងភាពជោគជ័យជាញឹកញាប់ក្នុងកិច្ចការសិក្សាដោះស្រាយបញ្ហានៅក្នុងក្រុម ដែលនេះធ្វើឱ្យការសិក្សាមានភាពវិជ្ជមាន ជាជាងសិស្សនោះទទួលបានបទពិសោធន៍អវិជ្ជមាន។)* |
| **៣.** ចូរបង្កើតបញ្ជីកត់ត្រាវិធីសាស្ត្រមួយចំនួនដែលបានប្រើក្នុងការអនុវត្តវិធីសាស្ត្រសិក្សាបែបសហការ |
| *(ចម្លើយៈការរៀបចំកន្លែងអង្គុយសម្រាប់ក្រុម កំណត់កិច្ចការឱ្យបានច្បាស់លាស់ បង្កើតបំណែងចែកការងារនៅក្នុងក្រុម រក្សាសមាជិកក្នុងក្រុមត្រឹម៨-៩នាក់ រៀបចំក្រុមចម្រុះសមត្ថភាពសិស្សក្នុងក្រុម ផ្លាស់ប្ដូរទៅមុខទៅក្រោយរវាងការឡើងរាយការណ៍របស់ក្រុមតូចនិងក្រុមធំ ត្រួតពិនិត្យការងារក្រុម និងផ្ដល់ការគាំទ្រ ប្រសិនបើចាំបាច់ឱ្យសិស្សជួយគ្នាទៅវិញទៅមក ត្រូវប្រាកដថាសិស្សមានការទទួលខុសត្រូវសម្រាប់* |

*ការសិក្សាផ្ទាល់ខ្លួនរបស់ពួកគេ) ។*

## ការបញ្ចប់ និងការសង្ខេប

- មធ្យោបាយដ៏ល្អសម្រាប់បញ្ចប់ការពិភាក្សានេះគឺថា អ្នកសម្របសម្រួលធ្វើការសង្ខេបនូវចំណុចខុសប្លែកគ្នាខ្លះៗរវាងវិធីសាស្ត្របង្រៀនតាមបែបបុរាណ និងវិធីសាស្ត្រការសិក្សាបែបសហការ។ មុនពេលធ្វើសកម្មភាពនេះអ្នកសម្របសម្រួលផ្តល់ជូនសិក្ខាកាមនូវ ឯកសារចែក គ ដើម្បីបំពេញនៅក្នុងក្រុម។ តារាង ឯកសារចែក គ គឺមានរាងដូចបង្ហាញនៅខាងក្រោម។ ទុកពេលឱ្យសិក្ខាកាមចំនួន ១០នាទី។
- នៅពេលដែលក្រុមនីមួយៗបានបញ្ចប់ការងាររបស់ពួកគេហើយ អ្នកសម្របសម្រួលដឹកនាំការពិភាក្សាក្រុមធំ ដោយយកតារាងដូចខាងក្រោម (ប៉ុន្តែសរសេរពង្រីកឱ្យធំនៅលើក្រដាសរ៉ាមធំ) មកបិទនៅលើក្តារខៀនដើម្បីងាយស្រួលបំពេញ។ សួរទៅកាន់ក្រុមនីមួយៗថាតើពួកគេបំពេញក្នុងតារាងយ៉ាងដូចម្តេច។ បន្ទាប់មកអ្នកសម្របសម្រួលបំពេញនៅក្នុងតារាងដែលបិទនៅលើក្តារខៀនដោយផ្អែកលើចម្លើយរបស់ក្រុមនីមួយៗ។

**ការប្រៀបធៀបវិធីសាស្ត្រសិក្សាបែបសហការ និងវិធីសាស្ត្របង្រៀនបែបបុរាណ**

| ប៉ារ៉ាម៉ែត្រ/លក្ខណៈ | ការបង្រៀនបែបបុរាណ | ការសិក្សាបែបសហការ |
|---|---|---|
| ១. វិធីរៀនសូត្ររបស់កុមារ | | |
| ២. សិស្សទទួលផលជាងគេ<br>៣. ប្រសិទ្ធភាពនៃការធ្វើឱ្យសិស្សធ្វើសកម្មភាព | | |
| ៤. ប្រើទំហំថ្នាក់ | | |
| ៥. លទ្ធភាពដែលបង្កឱ្យមានទទម្លាប់ជួយគ្នាទៅវិញទៅមក | | |
| ៦. ប្រភេទនៃការវាយតម្លៃដែលប្រើញឹកញាប់ | | |
| ៧. តួនាទីរបស់គ្រូ | | |

## ផ្ទេរ៉ិស

- អ្នកសម្របសម្រួលអាចរៀបចំប័ណ្ណចម្លើយទៅតាមតារាងខាងក្រោម ហើយចែកជូនក្រុមនីមួយៗនូវប័ណ្ណចម្លើយនោះ។
- បន្ទាប់មកក្រុមនីមួយៗត្រូវធ្វើកិច្ចការរួមគ្នាដើម្បីផ្ទៀងផ្ទាត់ប័ណ្ណចម្លើយនោះ ជាមួយនឹងតារាងក្នុងឯកសារខាងក្រោម។

| ចម្លើយរំពឹងទុក | | |
|---|---|---|
| **ប៉ារ៉ាម៉ែត្រ/ លក្ខណៈ** | **ការបង្រៀនបែបបុរាណ** | **ការសិក្សាបែបសហការ** |
| វិធីរៀនសូត្ររបស់កុមារ | ▪ *បុគ្គល និងប្រកួតប្រជែង* | ▪ *រៀនជាក្រុម និង សហការ* |
| សិស្សទទួលផលជាងគេ | ▪ *សិស្សពូកែ* | ▪ *សិស្សបង្គួរ និងសិស្សខ្សោយ* |
| ប្រសិទ្ធភាពនៃការធ្វើឱ្យសិស្សធ្វើសកម្មភាព | ▪ *កម្រិតទាប និងមានសិស្សចំនួនតិចដែលធ្វើសកម្មភាពព្រមគ្នា* | ▪ *កម្រិតខ្ពស់ និងមានសិស្សជាច្រើនដែលធ្វើសកម្មភាពព្រមគ្នា* |
| ប្រើទំហំថ្នាក់ | ▪ *ល្អសម្រាប់ថ្នាក់សិស្សច្រើន* | ▪ *ល្អសម្រាប់ថ្នាក់មានសិស្សចំនួនតិច ឬមធ្យម* |
| លទ្ធភាពដែលបង្កឱ្យមានទម្លាប់ជួយគ្នា ទៅវិញទៅមក | ▪ *ទាប ឬ គ្មាន* | ▪ *ខ្ពស់* |
| ប្រភេទនៃការវាយតម្លៃដែលប្រើញឹកញាប់ | ▪ *ការវាយតម្លៃសរុប* | ▪ *ការវាយតម្លៃជាដំណាក់ៗ និងការវាយតម្លៃសរុប* |
| តួនាទីរបស់គ្រូ | ▪ *អ្នកផ្សព្វផ្សាយព័ត៌មាន/ចំណេះដឹង*<br>▪ *អ្នកផ្តាច់ការ* | ▪ *សម្របសម្រួលការសិក្សា*<br>▪ *តាមដានការរៀនរបស់ក្រុមសិស្ស* |

- បន្ទាប់មកអ្នកសម្របសម្រួលត្រូតពិនិត្យចម្លើយ ហើយពិភាក្សាជាមួយក្រុមធំ។

# ឯកសារចែក គ

## ការប្រៀបធៀបការបង្រៀនតាមបែបបុរាណ និងការសិក្សាបែបសហការ

*ការណែនាំៈ អ្នកសម្របសម្រួលនឹងសួរអ្នកឱ្យប្រៀបធៀបវិធីសាស្ត្របង្រៀនបែបបុរាណ និងវិធីសាស្ត្រការសិក្សាបែបសហការទៅតាមប៉ារ៉ាម៉ែត្រដែលមាននៅក្នុងតារាងខាងក្រោម។ ដោយផ្អែកទៅលើប៉ារ៉ាម៉ែត្រដែលបង្ហាញនៅក្នុងតារាងខាងឆ្វេង ចូរធ្វើការប្រៀបធៀបនៅក្នុងតារាងខាងក្រោម តាមរយៈការពិភាក្សាជាមួយសមាជិកនៅក្នុងក្រុមរបស់អ្នក។*

**ការប្រៀបធៀបវិធីសាស្ត្រសិក្សាបែបសហការ និងវិធីសាស្ត្របង្រៀនបែបបុរាណ**

| ប៉ារ៉ាម៉ែត្រ/លក្ខណៈ | ការបង្រៀនបែបបុរាណ | ការសិក្សាបែបសហការ |
|---|---|---|
| ១. វិធីរៀនសូត្ររបស់កុមារ | | |
| ២. សិស្សទទួលផលជាងគេ | | |
| ៣. ប្រសិទ្ធភាពនៃការធ្វើឱ្យសិស្សធ្វើសកម្មភាព | | |
| ៤. ប្រើទំហំថ្នាក់ | | |
| ៥. លទ្ធភាពដែលបង្កឱ្យមានទម្លាប់ជួយគ្នាទៅវិញទៅមក | | |

| ការប្រៀបធៀបវិធីសាស្ត្រសិក្សាបែបសហការ និងវិធីសាស្ត្របង្រៀនបែបបុរាណ | | |
|---|---|---|
| ប៉ារ៉ាម៉ែត្រ/លក្ខណៈ | ការបង្រៀនបែបបុរាណ | ការសិក្សាបែបសហការ |
| ៦. ប្រភេទនៃការវាយតម្លៃដែលប្រើញឹកញាប់ | | |
| ៨. តួនាទីរបស់គ្រូ | | |

# សកម្មភាពបំប៉នទី៤

## បច្ចេកទេសការសិក្សាបែបសហការក្នុងការអនុវត្តជាក់ស្តែង ( ១ម៉ោង៣០នាទី )

### ១. វត្ថុបំណង

- ដើម្បីបង្កើនការយល់ដឹងរបស់សិក្ខាកាមអំពីវិធីសាស្ត្រការសិក្សាបែបសហការ តាមរយៈការសង្កេតនិងការពិភាក្សាទៅលើឌីវីឌីបំប៉នគ្រូ។
- ដើម្បីពិចារណាអំពីរបៀបដែលគេបញ្ជ្រាបវិធីសាស្ត្រការសិក្សាបែបសហការ ទៅក្នុងការអនុវត្តវិធីសាស្ត្របង្រៀនជាក់ស្តែងក្នុងថ្នាក់រៀន។

### ២. លំនាំបង្រៀន

- ប្រធានបទនេះទាមទារឱ្យមានការទស្សនាឌីវីឌី ដែលបង្ហាញជាឧទាហរណ៍នៃវិធីសាស្ត្រសិក្សាបែបសហការ។ ឌីវីឌីនេះគួរត្រូវបានភ្ជាប់ជាមួយនឹងឯកសារបំប៉ន។
- អ្នកសម្របសម្រួលគួរតែរៀបសិក្ខាកាមជាក្រុម ហើយផ្តល់ជូនឯកសារចែក ឃ ដែលដកស្រង់ចេញពីឯកសារស្វ័យសិក្សាដែលពិពណ៌នាក្នុងផ្នែកទី១។
- បន្ទាប់មកសិក្ខាកាមត្រូវបានស្នើឱ្យអាន ឯកសារចែក ឃ ហើយរំលឹកការយល់ដឹងរបស់ពួកគាត់អំពីទិដ្ឋភាពមួយចំនួននៃការសិក្សាបែបសហការ។
- ចែកសិក្ខាកាមជាក្រុម។
- ប្រសិនបើអ្នកសម្របសម្រួលជឿជាក់លើខ្លួនឯងក្នុងការអនុវត្តប្រធានបទនេះ ហើយចំនួនសិក្ខាកាមមិនសូវច្រើនទេនោះ យុទ្ធសាស្ត្រនៃការសិក្សាបែបសហការគួរតែត្រូវបានអនុវត្តនៅក្នុងមេរៀននេះ ក៏ដូចត្រូវបានប្រើនៅក្នុងថ្នាក់រៀន ដូចខាងក្រោមៈ

  *១. បង្កើតក្រុមចម្រុះ-ក្នុងក្រុមអាចមានសមាជិកចម្រុះដែលមកពីសាលា/ស្រុកខុសៗគ្នាឬក្រុមសមាជិកដែលមានការងារខុសគ្នា។*

  *២. ឱ្យសិក្ខាកាមជ្រើសរើសឈ្មោះសម្រាប់ក្រុមរបស់គេ។*

  *៣. កំណត់តួនាទី និងភារកិច្ចនៅក្នុងក្រុម (បំណែកចែកការងារ)*
- ក្រុមនីមួយៗត្រូវបានផ្តល់ជូននូវទិដ្ឋភាពមួយនៃការសិក្សាបែបសហការ ដើម្បីប្រើប្រាស់អំឡុងពេលទស្សនាឌីវីឌី-ប្រសិនបើមានក្រុមលើសពី៥ អ្នកសម្របសម្រួលអាចបែងចែកផ្នែកទិដ្ឋភាពទី១ជាពីរសម្រាប់ក្រុមពីរទៀត (ឧ. ១.១ និង ១.២)។

- ក្រុមនីមួយៗធ្វើការកត់ត្រានូវឧទាហរណ៍ ឬសកម្មភាពនៃទិដ្ឋភាពការសិក្សាបែបសហការដែលបានកើតឡើងនៅក្នុងឌីវីឌីដែលពួកគេកំពុងទស្សនា។
- បន្ទាប់មកក្រុមនីមួយៗពិភាក្សាគ្នាអំពីអ្វីដែលពួកគេបានកត់ត្រា។
- អ្នករាយការណ៍នៅក្នុងក្រុមនីមួយៗឡើងផ្តល់ពតិមានត្រឡប់ទៅកាន់ក្រុមធំ។
- បន្ទាប់មកនៅក្នុងក្រុមធំអ្នកសម្របសម្រួលគួរដឹកនាំការពិភាក្សាដោយប្រើសំណួរដូចខាងក្រោមៈ

    ១. តើគ្រូបានប្រើសម្ភារអ្វីខ្លះនៅក្នុងមេរៀន?

    ២. តើមេរៀននេះកើតឡើងនៅកន្លែងណាខ្លះ?

    ៣. តើសិស្សមានប្រតិកម្មបែបណាខ្លះចំពោះមេរៀន?

# ឯកសារចែក យ

### *វិធីសាស្ត្រការសិក្សាបែបសហការនៅក្នុងការអនុវត្តជាក់ស្តែង*

*ការណែនាំៈ អានទូវទិដ្ឋភាពនៃការសិក្សាបែបសហការដូចខាងក្រោម។ បន្ទាប់មកទស្សនាឌីវីឌីដែលបង្ហាញអំពីវិធីសាស្ត្រសិក្សាបែបសហការក្នុងបរិបទផ្សេងៗគ្នារួមមានថ្នាក់ទី២ ទី៥ និងទី៨។ នៅពេលទស្សនាឌីវីឌី សូមធ្វើការកត់ត្រានៅក្នុងតារាងដែលបានផ្តល់ជូនក្នុងឯកសារ។*

| **ទិដ្ឋភាពនៃការសិក្សាបែបសហការ** |
|---|
| ១. ការពឹងពាក់អាស្រ័យគ្នាទៅវិញទៅមកប្រកបដោយភាពវិជ្ជមាន |
| ២. បំណិនសហការ (បំណិនសង្គម) |
| ៣. ដំណើរការអន្តរកម្មរវាងក្រុម |
| ៤. ការរៀបចំក្រុមចម្រុះ (សមត្ថភាព ភេទ...) |
| ៥. ទំនួលខុសត្រូវបុគ្គល |

**<u>ការពន្យល់សង្ខេបអំពីទិដ្ឋភាពសំខាន់ៗនៃការសិក្សាបែបសហការ</u>**

#### ១. ការពឹងពាក់អាស្រ័យគ្នាទៅវិញទៅមកប្រកបដោយភាពវិជ្ជមាន

សិស្សដឹងថាពួកគេត្រូវការគ្នាទៅវិញទៅមកដើម្បីបំពេញកិច្ចការក្រុម។ ចំណុចសំខាន់ដើម្បីសម្រេចកិច្ចការនេះឱ្យបានជោគជ័យគឺត្រូវបង្កើតរចនាសម្ព័ន្ធក្រុម ដើម្បីឱ្យសមាជិកក្រុមម្នាក់ៗដឹងថា "ខ្ញុំអាចទទួលជោគជ័យនិងធ្វើកិច្ចការឱ្យល្អបានដោយសារសមាជិកផ្សេងៗទៀតក្នុងក្រុមរបស់ខ្ញុំទទួលបានជោគជ័យ និងធ្វើកិច្ចការបានល្អផងដែរ"។

#### ១.១. គ្រូអាចលើកកម្ពស់ការពឹងពាក់អាស្រ័យគ្នាទៅវិញទៅមកប្រកបដោយភាពវិជ្ជមាន តាមរយៈ

- បង្កើតគោលបំណងការសិក្សាសមស្រប (ការសិក្សានិងការធានាថាសមាជិកក្រុមផ្សេងៗទៀតក៏ទទួលបានការសិក្សាផងដែរ)។
- ប្រើប្រាស់វិធីផ្តល់រង្វាន់រួមគ្នា (បើសិនសមាជិកក្នុងក្រុមទាំងអស់ទទួលបានលទ្ធផលល្អលើសលក្ខណៈវិនិច្ឆ័យសមាជិកម្នាក់ៗក៏ត្រូវទទួលបានពិន្ទុបន្ថែមស្មើៗគ្នាផងដែរ)។
- ផ្តល់នូវធនធានដែលសមាជិកម្នាក់ៗត្រូវធ្វើការរួមគ្នា

- បង្កើតតួនាទីសម្រាប់សមាជិកម្នាក់ៗ
- ពង្រឹងនូវចំណាប់អារម្មណ៍នៃ "ការដាក់ឈ្មោះក្រុមរួមគ្នា" (ដោយសុំឱ្យក្រុមនីមួយៗដាក់ឈ្មោះក្រុមដោយខ្លួនឯង)។
- ការខិតខំប្រឹងប្រែងពីសមាជិកក្រុមនីមួយៗ គឺត្រូវតែមាន និងមិនអាចខ្វះបានសម្រាប់ភាពជោគជ័យរបស់ក្រុម។
- សមាជិកក្រុមនីមួយៗផ្តល់នូវការរួមចំណែកដើម្បីធ្វើការខិតខំរួមគ្នាដោយប្រើប្រាស់ធនធាន តួនាទី និងការទទួលខុសត្រូវលើកិច្ចការរៀងៗខ្លួន។

## ១.២. ការបង្កើតតួនាទីក្នុងក្រុម

*តួនាទីរបស់ក្រុម នឹងមានលក្ខណៈផ្សេងៗគ្នាទៅតាមប្រភេទកិច្ចការ។ ខាងក្រោមនេះបង្ហាញនូវតួនាទីមួយចំនួនដែលអាចកើតមានៈ*

- អ្នកសម្របសម្រួលៈ ជាអ្នកដឹកនាំការពិភាក្សា និងលើកទឹកចិត្តសមាជិកគ្រប់គ្នាក្នុងក្រុមឱ្យចូលរួមធ្វើកិច្ចការ
- អ្នកសរសេរ/កត់ត្រាៈ កត់ត្រារាល់ការពិភាក្សារបស់ក្រុម។
- អ្នកផ្ទៀងផ្ទាត់/រក្សា ពេលវេលាៈ ត្រូវធានាថាក្រុមនឹងបញ្ចប់ការងារទាន់ពេលវេលាដែលកំណត់ដោយគ្រូ។
- អ្នករាយការណ៍ៈ រាយការណ៍គំនិតរបស់ក្រុមទៅកាន់សិស្សផ្សេងៗទៀតនៅក្នុងថ្នាក់ដោយប្រើប្រាស់កំណត់ត្រារបស់អ្នកសរសេរ។
- អ្នកបកស្រាយបង្ហាញៈ គូសរូបភាព ឬដ្យាក្រាមដែលចាំបាច់។
- អ្នកនាំសារ/អ្នកប្រមូលៈ ការបញ្ជូន ឬការរត់បណ្តាក់ព័ត៌មានជាមួយគ្រូទៅកាន់សិស្សក្រុមផ្សេងៗ និងទុកដាក់ ឬប្រគល់សម្ភារទាំងនោះទៅកាន់គ្រូវិញ។

## ២. បំណិនសហការ (បំណិនសង្គម)

- ការលើកសរសើរគ្នា ការជម្រុញឱ្យអ្នកដទៃទទួលបានជោគជ័យ
- ការចេះស្តាប់គ្នា
- ការបង្ហាញភាពអត់ធ្មត់
- ការចេះរក្សាឱ្យអ្នកគ្រប់គ្នាផ្តោតលើកិច្ចការ
- ការពន្យល់ដោយផ្ទាល់មាត់អំពីរបៀបដោះស្រាយបញ្ហា
- ការបង្រៀនចំណេះដឹងរបស់ខ្លួនទៅឱ្យអ្នកដទៃ
- ចេះសាកសួរដើម្បីឱ្យដឹងថាខ្លួនបានយល់ដឹង

- ការពិភាក្សាលើបញ្ញតិដែលបានរៀន
- ចេះផ្សារភ្ជាប់ការសិក្សានាពេលបច្ចុប្បន្នជាមួយការសិក្សានាពេលអតីតកាល

## ៣. ដំណើរការអន្តរកម្មរវាងក្រុម

- អនុញ្ញាតឱ្យកុមារឆ្លុះបញ្ចាំងលើដំណើរការ (តើល្អកម្រិតណា បញ្ហា ...) ដែលពួកគេបានធ្វើការជាមួយគ្នា
- សមាជិកក្រុមពិភាក្សាលើរបៀបដែលពួកគេសម្រេចបាននូវគោលបំណង និងការរក្សាបាននូវទំនាក់ទំនងការងារប្រកបដោយប្រសិទ្ធភាព។
- សមាជិកក្រុមពិភាក្សាសកម្មភាពដែលធ្វើឱ្យមានប្រយោជន៍ និងគ្មានប្រយោជន៍។
- ឱ្យសិស្សធ្វើការសម្រេចចិត្តលើសកម្មភាពក្នុងក្រុម (អាកប្បកិរិយា) អ្វីខ្លះដែលត្រូវបន្តអនុវត្ត ឬអ្វីខ្លះដែលត្រូវផ្លាស់ប្តូរ។

## ៤. ការរៀបចំក្រុមចម្រុះ (សមត្ថភាព ភេទ...)

- ស្នាដៃដែលធ្លាប់មានពីមុន
- ភាពឧស្សាហ៍/ព្យាយាម
- ភេទ
- សាសនា
- ជនជាតិ

## ៥. ទំនួលខុសត្រូវបុគ្គល

- សិស្សម្នាក់ៗបង្កើតសំណួរ (ចេះសួរ) បំពេញកិច្ចការ ឬសរសេរបទនិពន្ធខ្លីៗ នៅពេលសិក្សាលើអ្វីមួយ។
- សមាជិកក្រុមត្រូវបានគ្រូហៅឈ្មោះដោយចៃដន្យដើម្បីឆ្លើយសំណួរ។
- សមាជិកក្រុមនីមួយៗទទួលបាននូវតួនាទីជាក់លាក់ដើម្បីអនុវត្តហើយតួនាទីទាំងនេះអាចធ្វើការផ្លាស់ប្តូរគ្នាបាន។
- សមាជិកនីមួយៗមានការទទួលខុសត្រូវខុសៗគ្នាដើម្បីបំពេញចំណែកកិច្ចការផ្សេងៗគ្នាក្នុងគម្រោងផែនការរបស់ក្រុម។

## *ដោយផ្អែកលើការទស្សនាវីដេអូ សូមបំពេញក្នុងតារាងខាងក្រោមនូវឧទាហរណ៍ជាក់លាក់មួយចំនួននៃទិដ្ឋភាពរបស់ការសិក្សាបែបសហការដែលបានលើកឡើងក្នុងវីដេអូ*

*តារាងកំណត់ត្រាសម្រាប់ការទស្សនាទៅលើឌីវីឌី*

| ទិដ្ឋភាពនៃការសិក្សាបែបសហការ | | | |
|---|---|---|---|
| | ថ្នាក់ទី ២ | ថ្នាក់ទី ៥ | ថ្នាក់ទី ៨ |
| ១. ការពឹងពាក់អាស្រ័យគ្នាទៅវិញទៅមកប្រកបដោយភាពវិជ្ជមាន | | | |
| ២. បំណិនសហការ (បំណិនសង្គម) | | | |
| ៣. ដំណើរការអន្តរកម្មរវាងក្រុម | | | |
| ៤. ការរៀបចំក្រុមចម្រុះ (សមត្ថភាព ភេទ...) | | | |
| ៥. ទំនួលខុសត្រូវបុគ្គល | | | |

# សកម្មភាពបំប៉នទី៥

## បច្ចេកទេសការសិក្សាបែបសហការនៅក្នុងការសរសេរកិច្ចតែងការបង្រៀន ( ១ម៉ោង១៥នាទី )

### ១. វត្ថុបំណង

- សិក្ខាកាមកំណត់បាននូវទិដ្ឋភាពរបស់ការសិក្សាបែបសហការ។
- សិក្ខាកាមរៀនបានអំពីរបៀបបញ្ចូលវិធីសាស្ត្រការសិក្សាបែបសហការទៅក្នុងកិច្ចតែងការបង្រៀន។

### ២. លំនាំបង្រៀន

- អ្នកសម្របសម្រួលគួររៀបសិក្ខាកាមជាក្រុម ហើយផ្តល់ជូននូវឯកសារចែក ង
- សម្រាប់សកម្មភាពនេះ សិក្ខាកាមក៏ត្រូវការឯកសារចែក ឃ ឬ ព័តិមាននៅផ្នែកទី១នៃសៀវភៅណែនាំនេះ។
- **ប្រសិនបើអ្នកសម្របសម្រួលជឿជាក់លើខ្លួនឯងក្នុងការអនុវត្តសកម្មភាពនេះ ហើយចំនួនសិក្ខា កាមមិនសូវច្រើនទេនោះ យុទ្ធសាស្ត្រនៃការសិក្សាបែបសហការគួរតែត្រូវបានអនុវត្តនៅក្នុងមេរៀននេះ ឱ្យដូចនឹងអ្វីដែលត្រូវ ប្រើនៅក្នុងថ្នាក់រៀន ដូចខាងក្រោមៈ**
  1. *បង្កើតក្រុមចម្រុះ-ក្នុងក្រុមអាចមានសមាជិកចម្រុះដែលមកពីសាលារៀន/ស្រុកខុសៗគ្នាឬក្រុមសមា-ជិកដែលមានការងារខុសគ្នា។*
  2. *ឱ្យសិក្ខាកាមជ្រើសរើសឈ្មោះសម្រាប់ក្រុមរបស់គេ។*
  3. *កំណត់តួនាទី និងភារកិច្ចនៅក្នុងក្រុម (បំណែងចែកការងារ)*
- អ្នកសម្របសម្រួលពន្យល់ថា ឯកសារចែក ង  គឺជាកិច្ចតែងការបង្រៀនសម្រាប់សិស្សថ្នាក់ទី១ហើយសូមអាននូវខ្លឹមសារនីមួយៗ  ហើយត្រូវប្រាកដថាសិក្ខាកាមយល់ច្បាស់អំពីដំណើរការក្នុងកិច្ចតែងការបង្រៀននេះ។
- សិក្ខាកាមពិភាក្សាមេរៀននៅក្នុងក្រុម ហើយព្យាយាមស្វែងរកឱ្យឃើញថាតើវិធីសាស្ត្របែបសហការត្រូវបានប្រើនៅត្រង់ផ្នែកណាខ្លះ ដោយប្រើតារាងដូចខាងក្រោមៈ

*លំហាត់ទី១ៈ ចម្លើយរំពឹងទុកនៃសកម្មភាពនៃទិដ្ឋភាពការសិក្សាបែបសហការនៅក្នុងមេរៀនថ្នាក់ទី១*

| ទិដ្ឋភាពនៃការសិក្សាបែបសហការដែលបានពិព័ណនាក្នុងមេរៀន | តើមានសកម្មភាពអ្វីខ្លះ? *(ចម្លើយរំពឹងទុក)* |
|---|---|
| ការពឹងពាក់អាស្រ័យគ្នាទៅវិញទៅមកប្រកបដោយភាពវិជ្ជមាន | • *រៀបសិស្សជាក្រុម*<br>• *សិស្សម្នាក់ៗដាក់រូបភាពនៅក្នុងប្រអប់* |

| | |
|---|---|
| បំណិនសហការ (បំណិនសង្គម) | • *ការរៀបចំរូបភាពដាក់នៅជុំវិញប្រអប់ដែលបានគូរនៅលើតុ ។* |
| ដំណើរការអន្តរកម្មរវាងក្រុម | • *សិស្សរៀបចំរូបភាពតាមលំដាប់លំដោយ* |
| ការរៀបចំក្រុមចម្រុះ (សមត្ថភាព ភេទ...) | • -- |
| ទំនួលខុសត្រូវបុគ្គល | • *សិស្សម្នាក់ៗក្នុងក្រុមនិយាយរឿង* |

- អ្នកសម្របសម្រួលគួរចងចាំថា ចម្លើយដែលមាននៅក្នុងកូឡោនខាងស្តាំគ្រាន់តែជាចម្លើយរំពឹងទុកតែប៉ុណ្ណោះ ។ ក្រុមនីមួយៗប្រហែលជាអាចឆ្លើយនូវចម្លើយផ្សេងទៀតដែលស្រដៀងនេះ ។
- បន្ទាប់មកក្រុមមួយត្រូវបានជ្រើសរើសឱ្យផ្តល់ព័ត៌មានត្រឡប់ និងចម្លើយរបស់ក្រុមទៅកាន់សិក្ខាកាមក្នុងថ្នាក់ទាំងអស់ ។
- បន្ទាប់មកអ្នកសម្របសម្រួលដឹកនាំការពិភាក្សាលើកទឹកចិត្តឱ្យធ្វើការគិតរប៉ស (Brainstorming) អំពីវិធីសាស្រ្តសិក្សាបែបសហការដទៃផ្សេងទៀត ដែលអាចបញ្ចូលទៅក្នុងមេរៀនក្រៅពីវិធីសាស្រ្តដែលមាននៅក្នុងកិច្ចតែងការបង្រៀន ។
- អ្នកសម្របសម្រួលត្រូវបញ្ជាក់ថាឱកាសនៃការរៀបចំសិស្សចម្រុះ កើតមាននៅក្នុងថ្នាក់កម្រិតខ្ពស់ច្រើនជាងថ្នាក់កម្រិតទាប ជាពិសេសទាក់ទងនឹងភាពចាស់ទុំ និងការអភិវឌ្ឍអាកប្បកិរិយារបស់សិស្ស ពីព្រោះសិស្សខ្លះប្រហែលជាអាចអភិវឌ្ឍលឿនជាងសិស្សដទៃទៀត ចាប់តាំងពីពួកគេនៅថ្នាក់ទី១ ។
- បន្ទាប់មកអ្នកសម្របសម្រួល អនុវត្តនូវសកម្មភាពដដែលដោយប្រើឯកសារចែក ច ដែលជាកិច្ចតែងការបង្រៀនសម្រាប់ថ្នាក់ទី៥ ។

### *លំហាត់ទី២: ចម្លើយរំពឹងទុកនៃសកម្មភាពនៃទិដ្ឋភាពការសិក្សាបែបសហការនៅក្នុងមេរៀនថ្នាក់ទី៥*

| ទិដ្ឋភាពនៃការសិក្សាបែបសហការដែលបានពិព័ណនាក្នុងមេរៀន | តើមានសកម្មភាពអ្វីខ្លះ? *(ចម្លើយរំពឹងទុក)* |
|---|---|
| ការពឹងពាក់អាស្រ័យគ្នាទៅវិញទៅមកប្រកបដោយភាពវិជ្ជមាន | • *កុមារសម្រេចចិត្តដាក់ឈ្មោះក្រុម*<br>• *បែងចែកតួនាទីក្នុងក្រុម*<br>• *ពិន្ទុនឹងត្រូវបានផ្តល់ជូនដល់ក្រុមណាដែលទទួល* |

| | |
|---|---|
| | សម្រេចការងារ ។ |
| បំណិនសហការ (បំណិនសង្គម) | • ធ្វើការរួមគ្នាដោយប្រើប័ណ្ណដើម្បីស្វែងរកចម្លើយ<br>• ចែករំលែកនូវសម្ភារ<br>• ការពិភាក្សា |
| ដំណើរការអន្តរកម្មរវាងក្រុម | • ការធ្វើឱ្យប្រាកដថាសមាជិកក្រុមយល់ពីសកម្មភាព |
| ការរៀបចំក្រុមចម្រុះ (សមត្ថភាព ភេទ...) | • ចំនួនសិស្សប្រុស និងស្រីមានចំនួនស្មើគ្នា |
| ទំនួលខុសត្រូវបុគ្គល | • ការអនុវត្តជាបុគ្គល ដោយធ្វើការចែកប្រភាគដោយប្រើរូបមន្ត ។ |

# ឯកសារចែក ខ

### បច្ចេកទេសការសិក្សាបែបសហការនៅក្នុងការធ្វើកិច្ចតែងការបង្រៀន

### ការរៀបចំគំនិតតាមលំដាប់លំដោយ

*សេចក្តីណែនាំៈ ចូរអានកិច្ចតែងការបង្រៀនថ្នាក់ទី១ជាបុគ្គល បន្ទាប់មកធ្វើការជាក្រុមដើម្បីកំណត់សកម្មភាពជាក់លាក់ ឬលក្ខណៈនៃមេរៀនដោយលើកជាឧទាហរណ៍អំពីប៉ារ៉ាម៉ែត្រដែលចង្អុលបង្ហាញនៅក្នុងចុងសន្លឹកឯកសារនេះ ។*

**ការរៀបចំគំនិតតាមលំដាប់លំដោយ និងកិច្ចការអំពីការស្តាប់ (ថ្នាក់ទី១)**

**I.វត្ថុបំណង**

- សិស្សអាចកំណត់រូបភាពតាមរយៈការពិពណ៌នាផ្ទាល់មាត់ដែលគេបានឮ ។
- សិស្សអាចរៀបចំព្រឹត្តិការណ៍ ឬគំនិតតាមលំដាប់លំដោយដោយប្រើរូបភាព ។
- សិស្សអាចពន្យល់ព្រឹត្តិការណ៍តាមលំដាប់លំដោយដោយផ្ទាល់មាត់ ។

**II.រយៈពេល**

- ១ ម៉ោង

**III.សម្ភារ**

រូបភាពខ្សែរឿង (ឧទាហរណ៍ទន្សាយស៊ីចេក) សម្រាប់រៀបតាមលំដាប់លំដោយរឿង (មាន៥ឈុត សម្រាប់៥ក្រុម)

**IV.លំនាំបង្រៀន**

**១. ធ្វើសេចក្តីផ្តើមមេរៀនថ្មីៈ តើអ្វីជាកិច្ចការ?**

- រៀបចំថ្នាក់ដោយយកជីសគូសប្រអប់ការេនៅចំកណ្តាលតុរបស់ក្រុមនីមួយៗ ។ ធ្វើដូចនេះដើម្បីជួយធានាថាសិស្សទាំងអស់ត្រូវធ្វើការងារជាក្រុម ។
- ចាប់ផ្តើមមេរៀនដោយប្រាប់សិស្សថា គ្រូនឹងនិទានរឿងមួយឱ្យសិស្សស្តាប់សូមឱ្យសិស្សយកចិត្តទុកដាក់ស្តាប់ ។ ហើយរឿងនោះពិពណ៌នាដោយរូបភាពខ្សែរឿងដែលគេនឹងទទួលបាននៅពេលបន្តិចទៀត ។
- ចែករូបភាពទៅឱ្យក្រុមនីមួយៗ (មើលរូបខាងក្រោម) ។ ហើយឱ្យសិស្សដាក់តំរៀនរូបភាពនៅជុំវិញប្រអប់ដែលបានគូសនៅលើតុ ។ ត្រួតពិនិត្យមើលកុំឱ្យសិស្សតែម្នាក់កាន់រូបភាពតែឯង ។




## ២. ពន្យល់ព្រឹត្តិការណ៍នៅក្នុងរូបភាពនីមួយៗតាមរយៈការស្តាប់

- ចូរប្រាប់សិស្សថាមុនពេលដែលគ្រូនិទានរឿងទាំងមូលប្រាប់ តំបូងគ្រូនឹងពិពណ៌នាព្រឹត្តិការណ៍ និងរូបភាពវត្ថុនានា ដែលបង្ហាញនៅក្នុងផ្ទាំងរូបភាពនេះសិន ។ គ្រូបង្ហាញរូប រួចពិពណ៌នាមួយម្តងៗ សិស្សណាដែលកាន់រូបដែលគ្រូ បង្ហាញរូបឱ្យគេដាក់ចូលក្នុងប្រអប់ដែលគូស ។ ចូរកត់សំគាល់ថា គ្រូមិនចាំបាច់ពិពណ៌នារូបភាពតាមលំដាប់ លំដោយទេ ។ ខាងក្រោមនេះជាឃ្លាខ្លះៗដែលអាចប្រើក្នុងលំហាត់នេះ:
    - យាយរើសបានទន្សាយងាប់មួយ
    - ទន្សាយស៊ីចេក
    - យាយដាក់ទន្សាយនៅក្នុងកញ្ជើ
    - យាយភ្ញាក់ព្រើតនៅពេលដែលឃើញនៅក្នុងកញ្ជើសុទ្ធតែសំបកចេក
    - ទន្សាយងាប់នៅតាមផ្លូវ
    - យាយត្រឡប់ពីចំការមកផ្ទះវិញ
    - ទន្សាយកំពុងអង្គុយនៅក្នុងកញ្ជើរបស់យាយ
- ត្រួតពិនិត្យផ្ទាំងរូបភាពដែលជ្រើសរើសដោយសិស្សក្នុងក្រុមនីមួយៗបន្ទាប់ពីការពិពណ៌នា ។

## ៣.រៀបចំផ្ទាំងរូបភាពខ្សែរឿងតាមលំដាប់លំដោយ

- នៅពេលដែលសិស្សអាចផ្គូរផ្គងតាមរយៈការពិពណ៌នាបានហើយនោះ សូមគ្រូនិយាយរឿងទន្សាយស៊ីចេកពីដើម ដល់ចប់ឱ្យសិស្សស្តាប់ ។
- និយាយរឿងចប់  សូមសរសេរលេខ១ដល់លេខ៤ នៅក្នុងប្រអប់លើតុសិស្ស ។

| ១ | ២ | ៣ | ៤ |
|---|---|---|---|

- គ្រូឱ្យសិស្សរៀបរូបភាពតាមលំដាប់លេខ តាមរយៈរឿងដែលគេបានឮ។ ផ្ទាំងរូបដែលបង្ហាញព្រឹត្តិការណ៍ទី១ ដាក់នៅក្នុងលេខ ១ ព្រឹត្តិការណ៍ទី ២ ដាក់នៅក្នុងលេខ ២ ហើយនឹងបន្តបន្ទាប់មក។
- គ្រូតពិនិត្យសកម្មភាពតាមក្រុមនីមួយៗ។ ហើយបើក្រុមណារៀបចំផ្សេងមិនត្រូវតាមលំដាប់ ព្យាយាមឱ្យសិស្សពន្យល់មកវិញនូវអ្វីដែលគេបានឃើញកើតឡើងនៅក្នុងរូបភាព ហើយបើការពន្យល់របស់គេស៊ីទៅនឹងរឿងដែលគេបានឮ សូមអនុញ្ញាតឱ្យក្រុមនោះរក្សាផ្ទាំងរូបភាពតាមលំដាប់លំដោយនៃការបកស្រាយរបស់គេចុះ។

*៤.និទានរឿង (ជម្រើស)*

- នៅពេលដែលសិស្សបញ្ចប់ការរៀបរូបភាពតាមលំដាប់មកសុំឱ្យតំណាងក្រុមនីមួយៗ និទានរឿងឡើងវិញតាមរយៈរូបភាពរបស់គេ។ អាចសួរក្រុមមួយថា អ្វីដែលកើតឡើងមុនគេ ហើយសួរក្រុមបន្ទាប់ថា អ្វីកើតឡើងបន្ទាប់ នឹងសួរបែបនេះជាបន្តបន្ទាប់មកទៀត។
- សិស្សក្នុងក្រុមនីមួយៗអាចនិទានរឿងប្រាប់សមាជិកក្រុមរបស់គេម្តងម្នាក់ៗ ដោយចង្អុលរូបភាពដែលនៅក្នុងប្រអប់។ នៅពេលដែលសិស្សកំពុងធ្វើការងារនោះ គ្រូគួរតែដើរត្រួតពិនិត្យមើលតាមក្រុមនីមួយៗ។

*តើអ្នកអាចធ្វើវាបានឬទេ?!!*

*លំហាត់ទី១: ចូរបំពេញតារាងខាងក្រោមដោយផ្អែកលើអំណានកិច្ចតែងការបង្រៀនថ្នាក់ទី១*

| *ទិដ្ឋភាពនៃការសិក្សាបែបសហការ ដែលបានពិពណ៌នានៅក្នុងកិច្ចតែងការបង្រៀន* | *តើមានសកម្មភាពអ្វីខ្លះ?* |
|---|---|
| *ការពឹងពាក់អាស្រ័យគ្នាទៅវិញទៅមកដោយភាពវិជ្ជមាន* | |
| *បំណិនសហការ (បំណិនសង្គម)* | |
| *ដំណើរការអន្តរកម្មរវាងក្រុម* | |
| *ការរៀបចំក្រុមចម្រុះ* | |
| *ទំនួលខុសត្រូវបុគ្គល* | |

# ឯកសារចែក ច

## បច្ចេកទេសការសិក្សាបែបសហការនៅក្នុងការសរសេរកិច្ចតែងការបង្រៀន

## ការចែកប្រភាគ

*សេចក្តីណែនាំៈ ចូរអានកិច្ចតែងការបង្រៀនថ្នាក់ទី៥ជាបុគ្គល បន្ទាប់មកធ្វើការជាក្រុមដើម្បីកំណត់សកម្មភាពជាក់លាក់ ឬលក្ខណៈនៃមេរៀនដោយលើកជាឧទាហរណ៍អំពីប៉ារ៉ាម៉ែត្រដែលចង្អុលបង្ហាញនៅក្នុងចុងសន្លឹកឯកសារនេះ ។*

**ការចែកប្រភាគ**

**I.** វត្ថុបំណង

- *សិស្សអាចចែកប្រភាគដោយប្រើសម្ភារូបី ។*
- *សិស្សអាចចែកប្រភាគដោយប្រើរូបមន្ត ។*
- *សិស្សអាចដោះស្រាយចំណោទពាក្យដោយចែកប្រភាគ ។*

**II.** រយៈពេល

- *១ ម៉ោង*

**III.** សម្ភារ

- *ប័ណ្ណចែកប្រភាគ (ចំនួន៥ឈុត)*
- *ចំណោទពាក្យមួយចំនួនដែលទាក់ទងដល់ការចែកប្រភាគ (សរសេរលើប័ណ្ណឬលើក្តារខៀន) ។*

**IV.** លំនាំបង្រៀន

*១. ធ្វើសេចក្តីផ្តើមមេរៀនថ្មីៈ ការចែកប្រភាគ*

- *រៀបចំសិស្សអង្គុយជា៥ក្រុមដែលមានចំនួនតុល្យភាពគ្នារវាងសិស្សស្រី និងប្រុស ។ បន្ទាប់មកក្រុមនីមួយៗកំណត់ឈ្មោះក្រុមដោយខ្លួនឯង ។ គ្រូពន្យល់ថា ក្រុមសិស្សទាំងអស់ត្រូវធ្វើការរួមគ្នាដើម្បីធានាថាសមាជិកគ្រប់គ្នាក្នុងក្រុមយល់ដឹង សមាជិកម្នាក់គួរធ្វើជាអ្នកកត់ត្រានិងម្នាក់ទៀតធ្វើជាអ្នករាយការណ៍ ។ គ្រូនឹងផ្តល់ពិន្ទុដល់ក្រុមទាំងអស់ដោយផ្អែកលើលទ្ធផលសម្រេចបានរបស់ក្រុមរៀងៗខ្លួន ។*
- *សរសេរបញ្ហាងាយៗនៅលើក្តារខៀនដែលទាក់ទងដល់ការចែកប្រភាគនៅលើក្តារខៀនដូចជា $6 \div 3$ ។ សួរសិស្សឱ្យឆ្លើយបញ្ហានេះ ។ រួចសរសេរចម្លើយនៅលើក្តារខៀន $6 \div 3 = 2$ ។ បន្ទាប់មកសួរសិស្សបន្ថែមទៀតថាតើ*

*អត្ថន័យពិតប្រាកដនៃចម្លើយនេះជាអ្វី។ ហើយនេះជារបៀបដែលអ្នកពន្យល់អត្ថន័យរបស់ចំនួននេះឱ្យទៅជាប្រយោគភាសារសាមញ្ញ។ វិធីមួយដែលយើងអាចនិយាយបានដូចជា : $6 \div 3 = 2$ មានន័យថា: មាន២សម្រាប់៣ដង នៅក្នុង៦។*

*2. ត្រឡប់ចំណោទចែកប្រភាគទៅជាភាសាសាមញ្ញ*

- *នៅពេលគ្រូបានបញ្ចេក់ពីការធ្វើសេចក្តីផ្តើមខាងលើនេះ សូមព្យាយាមអនុវត្តន៏ទំនាក់ទំនងស្រដៀងគ្នានេះទៅនឹងការចែកប្រភាគ។ ឧទាហរណ៍ : តើប្រភាគ $\frac{1}{2} \div \frac{1}{4} = ?$ ហើយមានន័យដូចម្តេចនៅក្នុងភាសាសាមញ្ញ ?*

- សរសេរការផ្លាស់ប្តូរទាំងនេះនៅលើក្តារខៀនៈ $\frac{1}{2} \div \frac{1}{4} = ?$ មានន័យថា "តើមានមួយភាគបួនប៉ុន្មានដងនៅក្នុងមួយភាគពីរ?"

- សរសេរលេខចែកផ្សេងៗទៀតនៅលើក្តារខៀន ហើយឱ្យសិស្សផ្លាស់ប្តូរទៅជាសំណួរជាពាក្យ តាមរបៀបដូចខាងលើ។

*៣.ការចែកប្រភាគប្រើប្រាស់សម្ភាររូបី*

- *បន្ទាប់ពីគ្រូបានបញ្ចប់ការផ្លាស់ប្តូរការចែកប្រភាគជាលេខឱ្យទៅជាសំណួរភាសា ឬពាក្យរួចមក។ សុំចែកប័ណ្ណចែកប្រភាគទៅឱ្យក្រុមសិស្សនីមួយៗ។ ឱ្យសិស្សចែកប័ណ្ណទាំងនោះឱ្យសមាជិកក្នុងក្រុមរបស់គេកាន់ស្មើៗគ្នាដែលប័ណ្ណទាំងអស់នោះមានសរសេរ $\frac{1}{2}$ , សរសេរ $\frac{1}{4}$ ។ល។*

- ចូរកត់សម្គាល់ថា ប័ណ្ណនីមួយៗតំណាងឱ្យចំណែកប្រភាគដែលមានសរសេរ "១" ឧទាហរណ៍ ប័ណ្ណដែលសរសេរ $\frac{1}{2}$ គឺពិតជាមួយភាគពីរនៃប័ណ្ណដែលសរសេរលេខ "១" ហើយប័ណ្ណដែលមានសរសេរ $\frac{1}{4}$ គឺមួយភាគពីរនៃប័ណ្ណដែលសរសេរ $\frac{1}{2}$ ។ល។

- សុំត្រឡប់មកបញ្ហាចែកប្រភាគដែលបានផ្លាស់ប្តូរឱ្យទៅជាសំណួរភាសាខាងលើ ឧទាហរណ៍ $\frac{1}{2} \div \frac{1}{4} = ?$ គ្រូសួរសិស្សដែលកាន់ប័ណ្ណមួយភាគពីរ ឱ្យដាក់នៅចំកណ្តាលតុ បន្ទាប់មកសួរសិស្សដែលកាន់ប័ណ្ណមួយភាគបួនដាក់ប័ណ្ណនៅខាងក្រោមប័ណ្ណដែលតំណាងប័ណ្ណមួយភាគពីរឱ្យស្មើគ្នាដូចបង្ហាញខាងក្រោមៈ




- ដូចនេះធ្វើឱ្យឃើញថា : $\frac{1}{2} \div \frac{1}{4} = ?$ មានន័យថា "តើមានមួយភាគបួនប៉ុន្មានដងនៅក្នុងមួយភាគពីរ?" សិស្សអាចផ្តល់ចម្លើយបានស្រេចតាមរយៈមើលសម្ភារគឺ២។ ដូចនេះ $\frac{1}{2} \div \frac{1}{4} =$ ២។ ចូរសរសេរការចែកប្រភាគស្រដៀងគ្នានៅលើក្តារខៀនដែលប្រភាគទាំងនោះអាចដោះស្រាយបានដោយប្រើប័ណ្ណ ដែលបានចែកឱ្យក្រុមនីមួយៗដូចជា:

$$\frac{1}{2} \div \frac{1}{6} = ? \;/\; \frac{1}{3} \div \frac{1}{6} = ? \;/\; \frac{1}{4} \div \frac{1}{8} = ? \;/\; \frac{2}{3} \div \frac{1}{6} = ? \;/\; 1\frac{1}{2} \div \frac{3}{4} = ?$$

- ឱ្យសិស្សដោះស្រាយការចែកប្រភាគនេះមួយម្តងៗ ដោយប្រើប័ណ្ណដែលចែកឱ្យទៅក្រុមនីមួយៗ។
- សិស្សពិភាក្សារួមគ្នាដើម្បីដោះស្រាយប្រភាគ ចំណែកគ្រូនឹងដើរត្រួតពិនិត្យជួយក្រែងសិស្សជួបបញ្ហា។
- សិស្សម្នាក់កត់ត្រានូវចំលើយ ដែលបានឯកភាពគ្នាថាជាចំលើយសមស្រប ។
- បន្ទាប់មកគ្រូត្រួតពិនិត្យចម្លើយទាំងនោះនៅលើក្តារខៀន និងផ្តល់ពិន្ទុដល់ក្រុមនីមួយៗដោយផ្អែកលើចម្លើយដែលពួកគេរកឃើញ។

4. ការចែកប្រភាគដោយប្រើរូបមន្ត

- នៅពេលដែលគ្រូយល់ថាសិស្សអាចចែកប្រភាគដោយប្រើសម្ភាររួចមកសូមត្រឡប់ទៅបញ្ហាដើមវិញ

$$\frac{1}{2} \div \frac{1}{4} = 2$$

- សួរសិស្សតើមានអ្វីកើតឡើងប្រសិនបើគេត្រឡប់ប្រភាគ $\frac{1}{4}$ ហើយគុណ។ ដោះស្រាយចម្លើយជាក្រុមធំដូចតទៅ

$$\frac{1}{2} \quad X \quad \frac{4}{1} \quad = \quad \frac{4}{2} \quad = \quad \frac{2}{1}$$

- នៅពេលនោះសិស្សឃើញថារូបមន្តនេះចេញលទ្ធផលដូចគ្នានៅពេលដែលគេប្រើសម្ភាររូបី

បន្ទាប់មកគ្រូអាចពន្យល់រូបមន្តនៃការចែកប្រភាគដល់សិស្សថា ដើម្បីចែកប្រភាគត្រូវយកប្រភាគទី១គុណនឹងចម្រាស់នៃប្រភាគទី ២ ។

- ឱ្យសិស្សអនុវត្តដោះស្រាយប្រភាគខាងក្រោមជាបុគ្គលដោយប្រើប្រាស់រូបមន្ត ហើយគ្រូត្រួតពិនិត្យមើល ។

$$\frac{1}{2} \div \frac{1}{6} = ? \ / \ \frac{1}{3} \div \frac{1}{6} = ? \ / \ \frac{1}{4} \div \frac{1}{8} = ? \ / \ \frac{2}{3} \div \frac{1}{6} = ? \ / \ 1\frac{1}{2} \div \frac{3}{4} = ?$$

5. ដោះស្រាយចំណោទពាក្យដោយចែកប្រភាគ

- សរសេរលំហាត់ដូចតទៅនេះនៅលើក្តារខៀនៈ

" លោកគ្រូលីមានសាំង $\frac{3}{4}$ ធុងនៅក្នុងម៉ូតូរបស់គាត់ ។ បើគាត់ប្រើអស់ $\frac{1}{8}$ ធុងក្នុងមួយថ្ងៃៗ សម្រាប់ទៅបង្រៀន និងត្រឡប់មកផ្ទះវិញរាល់ថ្ងៃ ។ តើសាំងដែលគាត់មានទាំងអស់អាចប្រើបានប៉ុន្មានថ្ងៃ ?"

- ឱ្យសិស្សតាមក្រុមនីមួយៗដោះស្រាយបញ្ហានេះ តំបូងឱ្យគេប្រើប្រាស់សម្ភាររូបីដែលចែកឱ្យរួចហើយនោះ បន្ទាប់មកទៀតប្រើរូបមន្តដែលបានពន្យល់ខាងលើ ។ គ្រូត្រួតពិនិត្យតាមក្រុម ។

- សូមឱ្យតំណាងក្រុមនីមួយៗរាយការណ៍មកក្រុមធំអំពីចម្លើយដែលគេបានរកឃើញ ។ គ្រូត្រួតពិនិត្យនិងកែតម្រូវបើចាំបាច់ ។

- គ្រូត្រួតពិនិត្យចម្លើយតបរបស់សិស្ស និងដាក់ពិន្ទុតាមក្រុមនីមួយៗ ។

***តើអ្នកអាចធ្វើវាបានឬទេ?!!***

**<u>លំហាត់ទី២:</u>** ចូរបំពេញតារាងខាងក្រោម ដោយផ្អែកលើអំណានកិច្ចតែងការបង្រៀនថ្នាក់ទី៥

| ទិដ្ឋភាពនៃការសិក្សាបែបសហការ ដែលបានពិពណ៌នានៅក្នុងកិច្ចតែងការបង្រៀន | តើមានសកម្មភាពអ្វីខ្លះ? |
|---|---|
| ការពឹងពាក់អាស្រ័យគ្នាទៅវិញទៅមកដោយភាពវិជ្ជមាន | |
| បំណិនសហការ (បំណិនសង្គម) | |
| ដំណើរការអន្តរកម្មរវាងក្រុម | |
| ការរៀបចំក្រុមចម្រុះ | |
| ទំនួលខុសត្រូវបុគ្គល | |

# សកម្មភាពបំប៉នទី៦

## បច្ចេកទេសការសិក្សាបែបសហការផ្សេងទៀត-យុទ្ធវិធីៈគិត-ដៃគូ-ចែករំលែក( ១ម៉ោង១០នាទី)

### ១. វត្ថុបំណង

- សិក្ខាកាមត្រូវបានណែនាំអំពីវិធីសាស្រ្តដទៃទៀត ដែលអាចជួយដល់វិធីសាស្រ្តការសិក្សាបែបសហការ។

### ២. លំនាំបង្រៀន

*តើអ្វីជាយុទ្ធវិធី គិត-ដៃគូ -ចែករំលែក? ( ១០ នាទី)*

- អ្នកសម្របសម្រួលណែនាំប្រធានបទនេះដោយពន្យល់ថាយុទ្ធវិធី *គិត-ដៃគូ-ចែករំលែក* គឺជាយុទ្ធវិធីដែលបង្កើតឡើងដើម្បីផ្តល់ឱ្យសិស្សនូវ "វិធីគិត" ទៅលើប្រធានបទដែលបានផ្តល់ជូននិងជួយឱ្យពួកគេចងក្រងនូវគំនិតជាបុគ្គល និងចែករំលែកគំនិតនេះជាមួយអ្នកដទៃ។វាគឺជាយុទ្ធវិធីសិក្សាមួយដែលបានបង្កើតឡើងដើម្បីលើកទឹកចិត្តការចូលរួមរបស់សិស្សក្នុងថ្នាក់រៀន។ ជាជាងការប្រើវិធីសាស្រ្តបង្រៀនបែបឧទ្ទេសដែលគ្រូដាក់សំណួរហើយឱ្យសិស្សម្នាក់ឡើងឆ្លើយអំពីយុទ្ធវិធី *គិត-ដៃគូ-ចែករំលែក* លើកទឹកចិត្តឱ្យចម្លើយរបស់សិស្សកាន់តែមានកម្រិតខ្ពស់ហើយអាចជួយសិស្សផ្តោតលើកិច្ចការដែលគ្រូដាក់ឱ្យ។ គំនិតចម្បងនៅក្នុងផ្នែកទាំង៣នៃយុទ្ធវិធីនេះត្រូវបានសង្ខេបដូចខាងក្រោមៈ

| | |
|---|---|
| *គិត* | ក្នុងអំឡុងពេលបង្រៀន គ្រូនឹងផ្តល់សំណួរហើយប្រាប់ទៅសិស្សឱ្យគិតអំពីចម្លើយយ៉ាងស្ងៀមស្ងាត់ដោយខ្លួនពួកគេផ្ទាល់...។ |
| *ដៃគូ* | បន្ទាប់មកពិភាក្សាចម្លើយជាដៃគូ |
| *ចែករំលែក* | ហើយជាចុងក្រោយ គ្រូនឹងឱ្យសិស្សផ្តល់នូវចម្លើយសម្រាប់សិស្សទាំងអស់ក្នុងថ្នាក់។ |

*គោលបំណងនៃយុទ្ធវិធី គិត-ដៃគូ-ចែករំលែក (១៥នាទី))*

- អ្នកសម្របសម្រួលគូសបញ្ជាក់និង ពិភាក្សាអំពីគោលបំណងសំខាន់ៗនៃយុទ្ធវិធី **គិត-ដៃគូ-ចែករំលែក** ដោយប្រើប៉ូស្ទ័រដែលបានរៀបចំទុកជាមុន ដែលប៉ូស្ទ័រត្រូវបានបង្ហាញនៅខាងស្តាំដៃនេះ។

**<u>ប៉ូស្ទ័រៈ គោលបំណងនៃយុទ្ធវិធី គិត-ដៃគូ-ចែករំលែក</u>**

- ផ្តល់ឱ្យសិស្សនូវ "ពេលវេលាសម្រាប់គិត" ដែលជួយបង្កើនគុណភាពនៃការឆ្លើយតបរបស់សិស្ស។
- ផ្តល់ពេលវេលាឱ្យសិស្ស "ធ្វើដំណើរការខួរក្បាល" ដើម្បីបង្កើតគំនិតថ្មីរួចយកទៅស្តុកទុកនៅក្នុងអង្គចងចាំ។ នៅពេលគ្រូ បង្រៀនផ្តល់ព័ត៌មានច្រើនពេកក្នុងពេលតែមួយ ព័ត៌មានជាច្រើននឹងបាត់បង់ទៅវិញ។ បើយើងផ្តល់ពេលវេលាឱ្យសិស្សប្រើយុទ្ធវិធី "គិត -ដៃគូ-ចែក រំលែក" ក្នុងពេលបង្រៀននឹងនាំឱ្យយើងរក្សាបាននូវព័ត៌មានយ៉ាងល្អិតល្អន់។
- ផ្តល់ឱកាសឱ្យសិស្សពិភាក្សាលើគំនិតថ្មីៗ ដើម្បីជាការលើកទឹកចិត្តឱ្យពួកគេចេះបង្កើតហេតុផលចំពោះគំនិតថ្មីនោះហើយផ្សារភ្ជាប់ នឹងចំណេះដឹងដែលមានស្រាប់។ ការយល់ខុសរបស់ពួកគេអំពីប្រធានបទតែងតែបញ្ចេញឱ្យឃើញ (និងមកជាយល់ដឹង) ក្នុងអំឡុងនៃការពិភាក្សានេះ។

- អ្នកសម្របសម្រួលអាចផ្តល់ជូនសិក្ខាកាមនូវគោលការណ៍នេះនៅក្នុង**ឯកសារចែក ឆ** ផងដែរ ។

- នៅពេលពន្យល់ផ្នែកនេះ ត្រូវផ្តល់នូវឧទាហរណ៍ដែលត្រឹមត្រូវ ដូចជាៈ
  - *តើចំណុចណាដែលអ្នកគិតថាសិស្សទំនងជាអាចចងចាំបាន-ការចម្លងនូវបញ្ជីគោលការណ៍វិទ្យាសាស្ត្រអំពីសីតុណ្ហភាព ឬការធ្វើពិសោធន៍ដែលពួកគេមានឱកាសពិភាក្សា អំពីគោលការណ៍ទាំងនោះជាមួយមិត្តភ័ក្ត្ររបស់ពួកគេ?*

**ប៉ូស្ទ័រៈ គោលការណ៍ក្នុងការប្រើយុទ្ធវិធី គិត-ដៃគូ-ចែករំលែក**

- ផ្តល់ឱ្យសិស្សនូវ "ពេលវេលាសម្រាប់គិត"-ត្រូវប្រាកដថាអ្នកបានផ្តល់ "ពេលវេលាសម្រាប់គិត" សមស្របដល់សិស្ស ។ ឱ្យសិស្សប្រាប់នៅពេលដែលពួកគេត្រៀមរួចជាស្រេចដើម្បី "ចែករំលែក" ។
- កំណត់ដៃគូ-អ្នកត្រូវកំណត់សិស្សដែលត្រូវពិភាកសាដៃគូ ជាជាងនិយាយថាបែរទៅរកដៃគូហើយពិភាក្សាគ្នា" ។ នៅពេលដែលអ្នកមិនបានកំណត់ដៃគូឱ្យសិស្សទេ សិស្សភាគច្រើននិងទៅចាប់អ្នកណាដែលពូកែ ហើយទុកឱ្យសិស្សណាដែលខ្សោយនៅតែឯង ។
- ផ្លាស់ប្តូរដៃគូ-ប្តូរដៃគូពិភាក្សាឱ្យបានញឹកញាប់ ។ បើសិស្សនៅក្នុងក្រុម គេអាចចាប់ដៃគូជាមួយសិស្សនៅក្បែរគ្នាសម្រាប់ធ្វើកិច្ចការពិភាក្សាមួយ និងចាប់ដៃគូជាមួយសិស្សឆ្លងគ្នា (សិស្សផ្សេងៗគ្នា) សម្រាប់ការពិភាក្សាបន្ទាប់ ។
- ការត្រួតពិនិត្យលើការពិភាក្សា- ដើរជុំវិញ និងពិនិត្យមើល ដំណាក់កាលពិភាក្សា ។ ជាញឹកញាប់អ្នកនឹងអាចឮនូវអ្វីដែលជាកំហុសកើតឡើងនៅពេលសិស្សពិភាក្សាក្រុម ដូច្នោះអ្នកអាចជួយកែតម្រូវបានទាន់ពេល ។

- *គោលការណ៍ក្នុងការប្រើប្រាស់យុទ្ធវិធី គិត- ដៃគូ-ចែករំលែក (១៥ នាទី)*

- អ្នកសម្របសម្រួលប្រើប៉ូស្ទ័រខាងស្តាំដៃដើម្បីពន្យល់គោលការណ៍នៃការប្រើប្រាស់យុទ្ធវិធីនេះ ។
- អ្នកសម្របសម្រួលផ្តល់ជូនសិក្ខាកាមនូវគោលការណ៍នេះ ដែលមានបង្ហាញនៅក្នុង**ឯកសារចែក ឆ** ។

*អត្ថប្រយោជន៍ចំពោះសិស្ស (៣០នាទី)*

- បន្ទាប់មកអ្នកសម្របសម្រួលចែកសិក្ខាកាមជាក្រុមដើម្បីពិភាក្សាអំពីអត្ថប្រយោជន៍ចំពោះសិស្សក្នុងការប្រើយុទ្ធវិធី គិត-ដៃគូ-ចែករំលែក ។
- បន្ទាប់ពីបានពិភាក្សាអស់រយៈពេល១៥នាទីរួមមក ក្រុមនីមួយៗឡើងបង្ហាញនូវចម្លើយរបស់ក្រុម ។ ចម្លើយរំពឹងទុកមួយចំនួនអាចមានដូចខាងក្រោមៈ

| **អត្ថប្រយោជន៍ងាយៗនៃយុទ្ធវិធី *គិត -ដៃគូ -ចែករំលែក*** |
|---|
| ▪ ផ្តល់ឱកាសដល់សិស្សក្នុងការគិតរកចម្លើយដោយខ្លួនឯង មុនពេលចម្លើយត្រូវបានឆ្លើយដោយមិត្តរបស់គេ ហើយការពិភាក្សានៅតែបន្ត ។ |
| ▪ វិធីនេះផ្តល់ឱកាសដល់សិស្សគ្រប់ៗគ្នាក្នុងការចែករំលែកនូវគំនិតរបស់ពួកគេ យ៉ាងហោចណាស់ជាមួយមិត្តម្នាក់ ហេតុនេះវាបង្កើនឱ្យមានការចូលរួមក្នុងការសិក្សាក្នុងថ្នាក់ ។. |
| ▪ ផ្តល់អត្ថប្រយោជន៍ដល់សិស្សក្នុងការរាប់អាន និងទទួលគំនិតពីមិត្តភ័ក្ត្រ-សិស្សនឹងប្រសើរឡើងទាំងអស់គ្នា ។ |

- ការជួយគាំទ្រគ្នាក្នុងភាពជាមិត្តភក្តិ ។
- សិស្សដែលរៀនខ្សោយអាចត្រូវបានជួយ ដូចនេះធ្វើឱ្យមានការកើនឡើងនៃចំនួនសិស្ស ។
- សិស្សចំណាយពេលច្រើនទៅលើការងារ ហើយស្តាប់ចម្លើយគ្នាទៅវិញទៅមកកាន់តែច្រើន។
- សិស្សក៏មានឱកាសផងដែរក្នុងការគិតដោយសេរីជាមួយសិស្សដទៃទៀត អំពីចម្លើយគ្នាទៅវិញទៅមក មុនពេលដែលគ្រូឱ្យឡើងរាយការណ៍ទៅកាន់ក្រុមធំ។
- សិស្សភាគច្រើនហ៊ានឡើងឆ្លើយទៅកាន់ក្រុមធំ បន្ទាប់ពីពួកគេបានចែករំលែកគំនិតនៅក្នុងក្រុមរួច។
- គុណភាពនៃចម្លើយរបស់សិស្សក៏កាន់តែរីកចម្រើន។

# ឯកសារចែក ឆ

## គោលបំណងនៃយុទ្ធវិធី គិត-ដៃគូ-ចែករំលែក និងគោលការណ៍សំខាន់ៗក្នុងការប្រើប្រាស់យុទ្ធវិធីនេះ

### គោលបំណងនៃយុទ្ធវិធី គិត-ដៃគូ-ចែករំលែក

- ផ្តល់ឱ្យសិស្សនូវ "ពេលវេលាសម្រាប់គិត" ដែលជួយបង្កើនគុណភាពនៃការឆ្លើយតបរបស់សិស្ស។
- ផ្តល់ពេលវេលាឱ្យសិស្ស "ធ្វើដំណើរការខួរក្បាល" ដើម្បីបង្កើតគំនិតថ្មីរួចយកទៅស្តុកទុកនៅក្នុងអង្គចងចាំ។ នៅពេលគ្រូបង្រៀនផ្តល់ព័ត៌មានច្រើនពេកក្នុងពេលតែមួយ ព័ត៌មានជាច្រើននឹងបាត់បង់ទៅវិញ។ បើយើងផ្តល់ពេលវេលាឱ្យសិស្សប្រើយុទ្ធវិធី "គិត- ដៃគូ-ចែករំលែក" ក្នុងពេលបង្រៀន នឹងនាំឱ្យយើងរក្សាបាននូវព័ត៌មានយ៉ាងល្អិតល្អន់។
- ផ្តល់ឱកាសឱ្យសិស្សពិភាក្សាលើគំនិតថ្មីៗដើម្បីជាការលើកទឹកចិត្តឱ្យពួកគេចេះបង្កើតហេតុផលចំពោះគំនិតថ្មីនោះ ហើយផ្សារភ្ជាប់នឹងចំណេះដឹងដែលមានស្រាប់។ ការយល់ខុសរបស់ពួកគេអំពីប្រធានបទតែងតែបញ្ចេញឱ្យឃើញ (និងមកជាយល់ដឹង) ក្នុងអំឡុងនៃការពិភាក្សានេះ។

### គោលការណ៍នៃការប្រើប្រាស់យុទ្ធវិធី គិត-ដៃគូ-ចែករំលែក

- ផ្តល់ឱ្យសិស្សនូវ "ពេលវេលាសម្រាប់គិត"-ត្រូវប្រាកដថាអ្នកបានផ្តល់ "ពេលវេលាសម្រាប់គិត" សមស្របដល់សិស្ស។ ឱ្យសិស្សប្រាប់ នៅពេលដែលពួកគេត្រៀមរួចជាស្រេចដើម្បី "ចែករំលែក"។
- កំណត់ដៃគូ-អ្នកត្រូវកំណត់សិស្សដែលត្រូវពិភាក្សាដៃគូ ជាជាងនិយាយថា "បែរទៅរកដៃគូហើយពិភាក្សាគ្នា"។ នៅពេលដែលអ្នកមិនបានកំណត់ដៃគូឱ្យសិស្សទេ សិស្សភាគច្រើននិងទៅចាប់អ្នកណាដែលពូកែ ហើយទុកឱ្យសិស្សណាដែលខ្សោយនៅតែឯង។
- ផ្លាស់ប្តូរដៃគូ-ប្តូរដៃគូពិភាក្សាឱ្យបានញឹកញាប់។ បើសិស្សនៅក្នុងក្រុម គេអាចចាប់ដៃគូជាមួយសិស្សនៅក្បែរគ្នាសម្រាប់ធ្វើកិច្ចការពិភាក្សាមួយ និងចាប់ដៃគូជាមួយសិស្សឆ្លងគ្នា (សិស្សផ្សេងៗគ្នា) សម្រាប់ការពិភាក្សាបន្ទាប់។
- ការត្រួតពិនិត្យលើការពិភាក្សា- ដើរជុំវិញ និងពិនិត្យមើល ដំណាក់កាលពិភាក្សា។ ជាញឹកញាប់អ្នកនឹងអាចឮនូវអ្វីដែលជាកំហុសកើតឡើងនៅពេលសិស្សពិភាក្សាក្រុម ដូច្នេះអ្នកអាចជួយកែតម្រូវបានទាន់ពេល។

# សកម្មភាពបំប៉នទី៧

## បញ្ហាទូទៅដែលកើតមានឡើងនៅពេលប្រើប្រាស់ការសិក្សាបែបសហការ ( ១ម៉ោង)

### ១. វត្ថុបំណង

- សិក្ខាកាមអាចកំណត់បានបញ្ហាសំខាន់ៗនៅពេលប្រើប្រាស់វិធីសាស្ត្រសិក្សាបែបសហការ។
- សិក្ខាកាមអាចកំណត់បានដំណោះស្រាយជាក់ស្តែងចំពោះបញ្ហាដែលកើតឡើងនៅពេលប្រើប្រាស់វិធីសាស្ត្រសិក្សាបែបសហការ។

### ២. លំនាំបង្រៀន

- ដឹកនាំការពិភាក្សាជាក្រុមធំជាមួយសិក្ខាកាមដើម្បីកំណត់បញ្ហាមួយចំនួនដែលកើតមានជាទូទៅនៅពេលប្រើប្រាស់វិធីសាស្ត្រសិក្សាបែបសហការនៅក្នុងថ្នាក់រៀន។ ធ្វើបញ្ជីបញ្ហាទាំងនេះនៅលើក្តារខៀន។
- តាមរយៈការប្រើប្រាស់តារាងខាងក្រោម អ្នកសម្របសម្រួលត្រូវធានាថាបញ្ហាទាំងអស់ត្រូវបានលើកទៅក្នុងការពិភាក្សាក្រុមធំ ក្នុងករណីសិក្ខាកាមភ្លេច។

| បញ្ហាទូទៅដែលបានកើតឡើងនៅពេលប្រើប្រាស់វិធីសាស្ត្រការសិក្សាបែបសហការ | ដំណោះស្រាយដែលអាចធ្វើបាន |
|---|---|
| ១. ទំហំក្រុមធំពេក ( មានចំនួនសិស្សច្រើនពេកនៅក្នុងក្រុម) | *វាត្រូវការជំនាញច្រើនសម្រាប់សិស្សក្នុងការគ្រប់គ្រងក្រុមមួយ ដែលមានសមាជិកលើសពីប្រាំនាក់។* |
| ២. សិស្សមិនដឹងថាត្រូវធ្វើអ្វីខ្លះនៅក្នុងក្រុម។ សិស្សមួយចំនួនមិនបានចូលរួមធ្វើសកម្មភាពក្នុងក្រុម។ | *ពន្យល់ដល់សិស្សអំពីមូលហេតុដែលអ្នកកំពុងប្រើប្រាស់វិធីសាស្ត្រសិក្សាបែបសហការ។ធ្វើសកម្មភាពខ្លីៗអំពីការសិក្សាបែបសហការ ដោយបង្កប់នូវភាពសប្បាយរីករាយ។ ឱ្យសិស្សពន្យល់ពីរបៀបដែលការសិក្សាបែបសហការផ្តល់ផលប្រយោជន៍ដល់ពួកគេ។ ពេលចាប់ផ្តើមមេរៀនម៉ោងដំបូង គ្រូធ្វើសកម្មភាពត្រួតពិនិត្យ និងសកម្មភាពធ្វើឱ្យមានការយល់ដឹងខ្លីៗ-មើលសកម្មភាពបែបសហការនៅខាងក្រោម។* |
| ៣. សិស្សខ្វះបំណិនសមស្របសម្រាប់ទំនាក់ទំនងគ្នា។ | *ឱ្យសិស្សចូលរួមបង្កើតបទវិន័យសម្រាប់ថ្នាក់រៀន និងរបៀបធ្វើការក្នុងក្រុម។ ឧទាហរណ៍ៈ ចូលរួមធ្វើកិច្ចការ ចូលរួមផ្តល់គំនិតយោបល់ ជួយបង្រៀនដល់សមាជិកដទៃ លើកទឹកចិត្តឱ្យសមាជិកគ្រប់គ្នាចូលរួមស្តាប់* |

| បញ្ហាទូទៅដែលបានកើតឡើងនៅពេលប្រើប្រាស់វិធីសាស្ត្រការសិក្សាបែបសហការ | ដំណោះស្រាយដែលអាចធ្វើបាន |
| --- | --- |
| | ដោយយកចិត្តទុកដាក់ ផ្តល់ការគោរពដល់អ្នកដទៃ។ បង្ហាញបញ្ជីវិន័យ និងរំលឹកសិស្សឱ្យចេះប្រើប្រាស់។ បញ្ចូលបទវិន័យថ្មីៗទៅក្នុងបញ្ជីបើសិនជាចាំបាច់។ |
| ៤. សិស្សមិនចូលចិត្តផ្លាស់ប្តូរក្រុម | យើងទាំងអស់គ្នាពេញចិត្តធ្វើការជាមួយមិត្តរបស់យើង ប៉ុន្តែពេលខ្លះវាមិនមែនជាការរៀបចំដែលល្អទេ សម្រាប់ការសិក្សាក្នុងក្រុម។ សិស្សត្រូវទទួលការអភិវឌ្ឍទំនាក់ទំនងធ្វើការងារប្រកបដោយភាពវិជ្ជមានជាមួយសិស្សទាំងអស់នៅក្នុងថ្នាក់រៀន។ ការផ្លាស់ប្តូរក្រុមឱ្យបានញឹកញាប់ល្មមមានប្រយោជន៍ណាស់ ដើម្បីកុំឱ្យសិស្សគ្រប់គ្នាស្ថិតនៅក្បែរសិស្សដែលមានចរិតលំបាករយៈពេលយូរពេក។ ប្រើប្រាស់ក្រុមសិស្សឱ្យចេះលើកទឹកចិត្តមិត្តភក្តិគ្នាឯង ដោយការដាក់សិស្សដែលមានសមត្ថភាពខុសៗគ្នានៅក្នុងក្រុមតែមួយ។ |
| ៥. ការសិក្សាបែបសហការមិនបានកើតឡើងឱ្យសមល្មមសម្រាប់សិស្សដើម្បីអភិវឌ្ឍបំណិនសហការ។ | ព្យាយាមដាក់សកម្មភាពសិក្សា ដែលតម្រូវឱ្យសិស្សធ្វើការសហការគ្នាដើម្បីបណ្តុះទម្លាប់សហការបែបវិជ្ជមាន។ បើសិនមិនមានសកម្មភាពផ្សេងទេ គ្រូអាចឱ្យពួកគេចែករំលែកអ្វីដែលបានរៀនជាមួយដៃគូ។ ចូរមើលវិធីសិក្សាបែប-ដៃគូ-ពិភាក្សា-ចែករំលែក។ |
| ៦. គ្រូបង្រៀនមិនបានធ្វើផែនការមេរៀនបែបសហការដោយយកចិត្តទុកដាក់។ | វាមិនមែនជាការគ្រប់គ្រាន់ទេ ដែលគ្រូគ្រាន់តែដាក់ឱ្យសិស្សធ្វើការជាក្រុម ហើយសង្ឃឹមថាពួកគេនឹងធ្វើការបានល្អជាមួយគ្នានោះ។ ចូរចាំថាវិធីសាស្ត្រសិក្សាបែបសហការមានធាតុសំខាន់ៗចំនួន៥ ( ការពឹងពាក់អាស្រ័យគ្នាដោយភាពវិជ្ជមាន បំណិនសហការ (បំណិនសង្គម) ដំណើរការអន្តរកម្មរវាងក្រុម ការរៀបចំក្រុមចម្រុះ ទំនួលខុសត្រូវបុគ្គល) ដែលត្រូវបញ្ចូល ដោយយកចិត្តទុកដាក់ទៅក្នុងគ្រប់កិច្ចតែងការបង្រៀនដើម្បីបង្រៀនសិស្សឱ្យចេះរៀនពីគ្នាទៅវិញទៅមកបានល្អ។ ចូររៀនពីរបៀបបញ្ចូលធាតុទាំងនេះទៅក្នុងមេរៀនបែបសហការ។ |
| ៧. គ្រូបង្រៀនភាគច្រើនចាប់ផ្តើមដាក់ | គ្រូត្រូវបង្រៀនសិស្សពីរបៀបរៀនជាមួយគ្នា។ គ្រូចាប់ផ្តើមដាក់សកម្ម |

| បញ្ហាទូទៅដែលបានកើតឡើងនៅពេលប្រើប្រាស់វិធីសាស្ត្រការសិក្សាបែបសហការ | ដំណោះស្រាយដែលអាចធ្វើបាន |
|---|---|
| កិច្ចការដែលស្មុគ្រ ស្មាញមុននឹងសិស្សចេះពីរបៀបបំពេញកិច្ចការងាយៗឱ្យបានជោគជ័យ ។ | ភាពងាយសាមញ្ញ និងអាចផ្តល់ពេលវេលាឱ្យបានវែងល្មម ព្រមទាំងជាកិច្ចការដែលពួកគេគិតថាមានសារៈសំខាន់ នៅពេលដែលគេធ្វើបានជោគជ័យ ។ មានការពិភាក្សាក្នុងថ្នាក់ឱ្យញឹកញាប់អំពីអ្វីដែលបានជួយឱ្យពួកគេធ្វើការរួមគ្នាបានល្អ ។ |
| ៨. មិនមានទំនួលខុសត្រូវជាបុគ្គលចំពោះកិច្ចការនៅក្នុងថ្នាក់រៀន ។ | ជាញឹកញាប់គ្រូឱ្យក្រុមសិស្សបំពេញកិច្ចការគម្រោង ឬធ្វើការលើសកម្មភាពអ្វីមួយដើម្បីសម្រេចគោលបំណងក្រុម ។ ប៉ុន្តែក្នុងការធ្វើសកម្មភាពទាំងនេះមានតែសិស្សម្នាក់ឬពីរនាក់ប៉ុណ្ណោះដែលធ្វើកិច្ចការនេះ ចំណែកអ្នកដទៃទៀតអង្គុយស្ងៀម ។នៅក្នុងពេលបង្រៀនគ្រូនៅតែអាចឱ្យសិស្សធ្វើការងារជាបុគ្គល ។ ឧទាហរណ៍ៈ ការធ្វើតេស្តជាបុគ្គល គ្រូសួរសំណួរទៅកាន់សិស្សបែបចៃដន្យការឡើង បង្ហាញនៅក្នុងថ្នាក់ ឬការធ្វើកិច្ចការពង្រឹងចំណេះដឹងដែលត្រូវបំពេញដោយសិស្សម្នាក់ៗ ។ |
| ៩. ក្រុមសិស្សមិនយល់ច្បាស់អំពីវត្ថុបំណងសិក្សា ។ | គ្រូត្រូវធានាថាក្រុមសិស្សដឹង និងយល់ពីវត្ថុបំណងសិក្សា និងដែលវត្ថុបំណង នោះអាចវាស់វែងបាន ។ ឧទាហរណ៍ៈ អ្នកនឹងបានសម្រេចវត្ថុបំណងហើយ នៅពេលសមាជិកសិស្សគ្រប់ក្រុមអាចពន្យល់កិច្ចការ ឬអាចឆ្លើយសំណួរបានត្រឹមត្រូវ ។ |
| ១០. សិស្សខ្វះបំណិនចាំបាច់សម្រាប់ធ្វើទំនាក់ទំនងបែបសង្គម ។ | អ្នកត្រូវបង្រៀនសិស្ស អំពីរបៀបសម្របសម្រួលការងាររបស់ពួកគេជាមួយអ្នកដទៃទៀត និងរក្សាឱ្យអ្នកគ្រប់គ្នាចូលរួមក្នុងសកម្មភាពសិក្សា ។ ធ្វើកិច្ចការនេះ ដោយជួយឱ្យពួកគេយល់ឃើញពីតម្រូវការបំណិនផ្នែកសង្គម បង្ហាញពួកគេពិតប្រាកដនៅអ្វីដែលត្រូវធ្វើ និងអ្វីដែលត្រូវឱ្យពួកគេអនុវត្ត ។ ប្រើប្រាស់សកម្មភាពបែបសប្បាយៗ នៅក្នុងកាលៈទេសៈខ្លះ និងបង្ហើក ព្រមទាំងផ្តល់ព័ត៌មានត្រឡប់ ប្រកបដោយការលើកទឹកចិត្ត នោះការសហការគ្នានឹងកើតមានឡើងដោយស្វ័យប្រវត្តិ ។ |
| ១១. គ្រូមិនយកចិត្តទុកដាក់ត្រួតពិនិត្យ | នេះជាពេលដែលត្រូវបង្រៀន ។ សូមស្ថិតនៅជាមួយក្រុមសិស្សដើម្បីជួយកែការយល់ខុសរបស់សិស្ស ជួយឱ្យពួកគេបានយល់ និងជួយជម្រុញ |

| បញ្ហាទូទៅដែលបានកើតឡើងនៅពេលប្រើប្រាស់វិធីសាស្ត្រការសិក្សាបែបសហការ | ដំណោះស្រាយដែលអាចធ្វើបាន |
|---|---|
| សិស្សខណៈដែលពួកគេកំពុងធ្វើកិច្ចការក្នុងក្រុម ។ | *បំណិនល្អៗក្នុងការងារក្រុម ។ ត្រូតពិនិត្យក្រុមសិស្សដោយយកចិត្តទុកដាក់ដោយការសង្កេតទៅលើអាកប្បកិរិយាទំនាក់ទំនង និងលើកទឹកចិត្តការសិក្សា និងបំណិនការងារក្រុម ។ ជួយក្រុមសិស្ស និងធានាថាសិស្សគ្រប់រូបទទួលបានចំណេះដឹង ។ រក្សាឱ្យសិស្សម្នាក់ៗចេះប្រយ័ត្នប្រយែងប្រុងស្មារតីជានិច្ចតាមរយៈការសួរ សំណួរពួកគេបែបថៃដន្យដើម្បីឱ្យពន្យល់ការងារក្រុម ។* |

- នៅពេលអ្នកសម្របសម្រួលបញ្ចប់ការពិភាក្សា ត្រូវផ្តល់**ឯកសារចែក ជ** ដែលសង្ខេបបញ្ហាដែលទើបបានពិភាក្សា។ ឱ្យសិក្ខាកាមពិភាក្សាបញ្ហានៅក្នុងក្រុម និងកំណត់ឱ្យបាននូវដំណោះស្រាយសមស្រប ។ សិក្ខាកាមអាចបន្ថែមចំណុចផ្សេងៗទៅក្នុងបញ្ជីផងដែរ បើសិនពួកគេគិតឃើញបញ្ហាផ្សេងទៀត ។
- នៅពេលក្រុមសិក្ខាកាមបានបំពេញដំណោះស្រាយខ្លីៗរួចហើយ អ្នកសម្របសម្រួលត្រួតពិនិត្យដំណោះស្រាយទាំងអស់ជាក្រុមធំ ។ ចូរប្រើដំណោះស្រាយនៅក្នុងបញ្ជីតារាងខាងលើដើម្បីជួយដឹកនាំការពិភាក្សា ។

# ឯកសារចែក ៨

## *បញ្ហារួមទូទៅដែលបានកើតឡើងនៅពេលប្រើប្រាស់វិធីសាស្ត្រការសិក្សាបែបសហការ*

*សេចក្តីណែនាំៈ ចូរធ្វើការជាក្រុម ហើយកំណត់ឱ្យបាននូវដំណោះស្រាយដែលអាចយកមកដោះស្រាយបញ្ហានីមួយៗ ខាងឆ្វេងដៃក្នុងតារាងខាងក្រោម ។ បើសិនជាអ្នកគិតឃើញបញ្ហាផ្សេងៗទៀតដែលមិនមាននៅក្នុងតារាងនេះ សូមបញ្ចូលបន្ថែមនៅក្នុងបញ្ជីខាងចុងឯកសារនេះ ព្រមទាំងបង្ហាញពីដំណោះស្រាយសមស្របផង ។*

| បញ្ហាទូទៅដែលបានកើតឡើងនៅពេលប្រើប្រាស់វិធីសាស្ត្រការសិក្សាបែបសហការ | ដំណោះស្រាយដែលអាចធ្វើបាន |
|---|---|
| ១. ទំហំក្រុមធំពេក (មានចំនួនសិស្សច្រើនពេកនៅក្នុងក្រុម) | |
| ២. សិស្សមិនដឹងថាត្រូវធ្វើអ្វីខ្លះនៅក្នុងក្រុម ។ សិស្សមួយចំនួនមិនបានចូលរួមធ្វើសកម្មភាពក្នុងក្រុម ។ | |
| ៣. សិស្សខ្វះបំណិនសមស្របសម្រាប់ទំនាក់ទំនងគ្នា ។ | |
| ៤. សិស្សមិនចូលចិត្តផ្លាស់ប្តូរក្រុម | |
| ៥. ការសិក្សាបែបសហការមិនបានកើតឡើងឱ្យសមល្មមសម្រាប់សិស្សដើម្បីអភិវឌ្ឍបំណិនសហការ ។ | |
| ៦. គ្រូបង្រៀនមិនបានធ្វើផែនការមេរៀន | |

| បញ្ហាទូទៅដែលបានកើតឡើងនៅពេលប្រើប្រាស់វិធីសាស្ត្រការសិក្សាបែបសហការ | ដំណោះស្រាយដែលអាចធ្វើបាន |
|---|---|
| បែបសហការដោយយកចិត្តទុកដាក់ ។ | |
| ៧. គ្រូបង្រៀនភាគច្រើនចាប់ផ្តើមដាក់កិច្ចការដែលស្មុគស្មាញ មុននឹងសិស្សចេះពីរបៀបបំពេញកិច្ចការងាយៗឱ្យបានជោគជ័យ ។ | |
| ៨. មិនមានទំនួលខុសត្រូវជាបុគ្គលចំពោះកិច្ចការនៅក្នុងថ្នាក់រៀន ។ | |
| ៩. ក្រុមសិស្សមិនយល់ច្បាស់អំពីវត្ថុបំណងសិក្សា ។ | |
| ១០. សិស្សខ្វះបំណិនចាំបាច់សម្រាប់ធ្វើទំនាក់ទំនងបែបសង្គម ។ | |
| ១១. គ្រូមិនយកចិត្តទុកដាក់ត្រួតពិនិត្យសិស្សខណៈដែលពួកគេកំពុងធ្វើកិច្ចការក្នុងក្រុម ។ | |
| ១២. | |
| ១៣. | |

# ឯកសារយោង


1. Cottel, Phillip G & Millis, Barbara J, (1998) *Cooperative Learning for Higher Education Faculty*, Phoenix, Arizona: Oryx Press,
2. Johnson, David W & Johnson, Roger T, (1994) *Learning together and alone. Cooperative, Competitive and Individualistic Learning*, Needham Heights, MA: Ally & Bacon Inc.
3. Slavin, R.E., (1990), *Cooperative Learning, Theory, Research, and Practice,* Englewood Cliffs, N.J.: Prentice Hall.
4. Vygotsky, L.S (1962), *Thought and Language*, Cambridge MA: MIT Press
5. King, Alison, (1993) *Sage on the Stage*, Journal Article, College Teaching Vol. 41.